ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ឯកសារណែនាំទី១

# ស្តីពី

# វិធីសាស្ត្របង្រៀន និងរៀន

# ដែលឆ្លើយតបនឹងសមភាពយេនឌ័រ

ខែកញ្ញា ឆ្នាំ២០២០


រៀបចំដោយ

ក្រសួងកិច្ចការនារី
MINISTRY OF WOMEN'S AFFAIRS

ដោយជំនួយឧបត្ថម្ភរបស់

សហភាពអឺរ៉ុប

Belgium
partner in development

Flanders
State of the Art

# មាតិកា


បញ្ជីរូបភាព.....7

បុព្វកថា.....9

អារម្ភកថា.....11

សេចក្ដីផ្ដើម.....13

គណៈកម្មការនិពន្ធ.....14

ជំពូកទី១៖ សេចក្ដីផ្ដើមអំពីយេនឌ័រ នឹងភាពឆ្លើយតបនឹងសមភាពយេនឌ័រ.....17

មេរៀនទី១៖ ភាពខុសគ្នារវាងភេទ និងយេនឌ័រ.....18

មេរៀនទី២៖ គោលនយោបាយលើកកម្ពស់សមភាពយេនឌ័រនៅកម្ពុជា.....25

មេរៀនទី៣៖ ផ្នត់គំនិតយេនឌ័រក្នុងវិស័យអប់រំ.....32

មេរៀនទី៤៖ ការបង្រៀន និងរៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ.....38

មេរៀនទី៥៖ អំពើហិង្សាទាក់ទងនឹងយេនឌ័រនៅក្នុងសាលារៀន.....45

ជំពូកទី២៖ វិធីសាស្ត្របង្រៀន និងរៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រសម្រាប់គ្រូ.....59

មេរៀនទី១៖ ការធ្វើកិច្ចតែងការបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ.....62

មេរៀនទី២៖ សម្ភារឧបទេសដែលឆ្លើយតបនឹងសមភាពយេនឌ័រ.....67

មេរៀនទី៣៖ ការប្រើប្រាស់ភាសា និងអន្តរកម្មដែលឆ្លើយតបនឹងសមភាពយេនឌ័រ.....74

មេរៀនទី៤៖ ការរៀបចំថ្នាក់រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ.....83

មេរៀនទី៥៖ វិន័យបែបវិជ្ជមាន.....91

មេរៀនទី៦៖ ការវាយតម្លៃអន្តរកម្ម និងផ្នត់គំនិតយេនឌ័រនៅក្នុងថ្នាក់រៀន.....100

មេរៀនទី៧៖ ការឆ្លុះបញ្ចាំងពីគ្រូបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ.....106

ឧបសម្ព័ន្ធ ក.....113

ឧបសម្ព័ន្ធ ខ៖ កិច្ចតែងការដែលឆ្លើយតបនឹងសមភាពយេនឌ័រ ....................................................114

ឧបសម្ព័ន្ធ គ៖ ឯកសារយោង ............................................................................................118

បោះពុម្ពផ្សាយដោយ៖

**© 2020 VVOB -** ការអប់រំដើម្បីការអភិវឌ្ឍន៍

Julien Dillensplein 1 bus 2A, 1060 Brussels, Belgium

ទូរស័ព្ទ៖ +32 2 209 07 99; គេហទំព័រ៖ www.vvob.org

**សិទ្ធិ និងការអនុញ្ញាត**

អ្នកនិពន្ធដែលទទួលខុសត្រូវ៖

Sven Rooms

© 2020 VVOB vzw

BY NC SA

កែសម្រួល និងរចនាដោយ GIM Publishing

រាល់ការបោះពុម្ពផ្សាយឯកសារត្រូវបានធ្វើឡើងដោយអនុលោមតាមអាជ្ញាប័ណ្ណ:

Creative Commons Attribution-Non Commercial-Share Alike 4.0 International License

(CC BY-NC-SA 4.0)

ក្រោមអាជ្ញាបណ្ណនេះ អ្នកអាចថតចម្លង ចែកចាយ បញ្ជូន និងប្រែសម្រួលឯកសារនេះក្នុងន័យមិនរកកម្រៃ។ រាល់សំណួរដែលពាក់ព័ន្ធនឹងសិទ្ធិ និងអាជ្ញាបណ្ណខាងលើ សូមទំនាក់ទំនងសួរមកកាន់ការិយាល័យ VVOB - ការអប់រំដើម្បីការអភិវឌ្ឍន៍ តាមរយ:អាសយដ្ឋាន Julien Dillensplein 1 bus 2A, 1060 Brussels, Belgium - ទូរស័ព្ទ៖ +32 2 209 07 99; អ៊ីមែល៖ info@vvob.org; គេហទំព័រ៖ www.vvob.org

**ឯកសារមិនរាប់បញ្ចូល និងរក្សាសិទ្ធិ**

ឯកសារនេះមានយោងភ្ជាប់ជាមួយឯកសារ និងគេហទំព័រផ្សេងៗទៀត។ ជាពិសេស មានដកស្រង់ព័ត៌មានពីឯកសាររបស់ VVOB - ការអប់រំដើម្បីការអភិវឌ្ឍន៍ និងវេទិកាសម្រាប់អ្នកអប់រំជាស្ត្រីអាហ្វ្រិក ហៅកាត់ថា FAWE នៅប្រទេស Zambia (VVOB & FAWE, 2019) និងនៅប្រទេសកេនយ៉ា (FAWE, 2005, 2020)។ ការប្រើប្រាស់ និងប្រែសម្រួលដោយភាគីទី៣ មិនទទួលបានការអនុញ្ញាតិពីអ្នកនិពន្ធដើមនោះទេ។ ហេតុនេះ អ្នកនិពន្ធដើមមិនទទួលខុសត្រូវចំពោះទស្សនៈ និងយោបល់ដែលបានបង្ហាញនៅក្នុងឯកសារណែនាំនេះទេ។

ឯកសារនេះ ត្រូវបានផលិតឡើងក្រោមជំនួយថវិការបស់សហភាពអឺរ៉ុប រដ្ឋាភិបាលប៊ែលហ្ស៊ិក និងរដ្ឋាភិបាលហ្លែមីស។ ខ្លឹមសារនៃឯកសារនេះស្ថិតក្រោមការទទួលខុសត្រូវរបស់ VVOB - ការអប់រំដើម្បីការអភិវឌ្ឍន៍ ហើយមិនបានឆ្លុះបញ្ចាំងពីទស្សនៈរបស់ដៃគូអភិវឌ្ឍន៍ទាំងនេះទេ។

សហភាពអឺរ៉ុប រដ្ឋាភិបាលប៊ែលហ្ស៊ិក និងរដ្ឋាភិបាលហ្លែមីស៍មិនទទួលខុសត្រូវចំពោះខ្លឹមសារនៅក្នុងសៀវភៅណែនាំនេះទេ។

សហការឧបត្ថម្ភថវិកាដោយ៖

THIS PROJECT IS CO-FUNDED BY THE EUROPEAN UNION

Belgium partner in development

Flanders State of the Art

ឯកសារនេះជាសមិទ្ធផលដែលចូលរួមសហការចងក្រងដោយ៖

vvob education for development

GADC Gender and Development for Cambodia

PUTHI KOMAR ORGANISATION

## បញ្ជីរូបភាព

### ជំពូកទី១


រូបភាពទី១៖ ដំណើរការទំនាក់ទំនងសង្គម ....................34
រូបភាពទី២៖ វិធីបង្រៀន និងរៀនឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការអនុវត្តជាក់ស្តែង ....................43
រូបភាពទី៣៖ អំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រនៅក្នុង និងជុំវិញបរិវេណសាលារៀន ....................47
រូបភាពទី៤៖ អំពើហិង្សាផ្លូវអារម្មណ៍ ផ្លូវកាយ និងផ្លូវភេទ ....................48
រូបភាពទី៥៖ វិធីធានាចន្លោះសុវត្ថិភាពនៅក្នុងសាលារៀន ....................53
រូបភាពទី៦៖ មធ្យោបាយបញ្ជូនបន្តនូវជនរងគ្រោះជាកុមារដោយសារអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ ....................56


### ជំពូកទី២


រូបភាពទី៧៖ វិធីបង្រៀន និងរៀនឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការអនុវត្តជាក់ស្តែង ....................61
រូបភាពទី៨៖ សៀវភៅវិទ្យាសាស្ត្រថ្នាក់ទី៧ ទំព័រទី១២៨ បោះពុម្ពឆ្នាំ២០១៣ ....................71
រូបភាពទី៩៖ សៀវភៅសិក្សាសង្គម ថ្នាក់ទី៩ ទំព័រទី១៦២ បោះពុម្ពឆ្នាំ២០១៨ ....................72
រូបភាពទី១០៖ សៀវភៅគណិតវិទ្យាថ្នាក់ទី១ ទំព័រទី១១ បោះពុម្ពឆ្នាំ២០១៨ ....................72
រូបភាពទី១១៖ ឧទាហរណ៍នៃការរៀបចំប្លង់អង្គុយ ....................86
រូបភាពទី១២៖ ករណីសិក្សាអំពីការរៀបចំប្លង់អង្គុយ ....................89
រូបភាពទី១៣៖ វិធីដោះស្រាយចំពោះអាកប្បកិរិយាដែលមិនសមរម្យក្នុងថ្នាក់រៀន ....................96

# បុព្វកថា

ក្រសួងអប់រំ យុវជន និងកីឡាបានសហការជាមួយក្រសួងកិច្ចការនារី និងដៃគូអភិវឌ្ឍ កសាងបាននូវ **ឯកសារណែនាំស្ដីពី វិធីសាស្រ្តបង្រៀន និងរៀន និងការដឹកនាំសាលារៀនឱ្យឆ្លើយតបនឹងសមភាពយេនឌ័រ**។ ឯកសារណែនាំនេះមានប្រយោជន៍ចំពោះគ្រូបង្រៀន ដើម្បីប្រើប្រាស់សម្រាប់ជាការផ្ដល់ព័ត៌មាន និងជាឧបករណ៍សំខាន់ ដែលជួយជំរុញដល់ការបង្រៀន និងរៀនកាន់តែមានភាពឆ្លើយតបនឹងសមភាពយេនឌ័រ ដោយផ្ដោតលើទិដ្ឋភាពមួយចំនួនដូចជាកិច្ចតែងការបង្រៀន ការផលិតសម្ភារឧបទេស ឧបករណ៍សម្រាប់វាយតម្លៃ ។ល។ សម្រាប់គណៈគ្រប់គ្រងវិទ្យាស្ថានគរុកោសល្យ និងគណៈគ្រប់គ្រងសាលារៀន ឯកសារនេះជួយដល់ការប្រែក្លាយវិទ្យាស្ថានគរុកោសល្យ ឬសាលារៀនឱ្យមានលក្ខណៈឆ្លើយតបនឹងសមភាពយេនឌ័រ តាមរយៈការបញ្ចូលទស្សនាទាននៃសមភាពយេនឌ័រទៅក្នុងការងារគ្រប់គ្រងប្រចាំថ្ងៃ។ ឯកសារណែនាំនេះ ក៏នឹងផ្ដល់ជាព័ត៌មាន និងជាឧបករណ៍សម្រាប់គណៈគ្រប់គ្រងសាលារៀន អំពីលក្ខណៈសម្បត្តិរបស់សាលារៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ អំពើហិង្សាទាក់ទងនឹងយេនឌ័រនៅក្នុងសាលារៀន ការបង្កើនភាពឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការធ្វើផែនការសកម្មភាព ផែនការថវិកា និងការអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំ ជាដើម។ មិនតែប៉ុណ្ណោះ ឯកសារណែនាំនេះក៏បានបញ្ចូលខ្លឹមសារស្ដីពី សារៈសំខាន់នៃការចូលរួមរបស់មាតាបិតាសិស្ស និងសហគមន៍ ដើម្បីលើកកម្ពស់ការឆ្លើយតបសមភាពយេនឌ័រនៅក្នុងសាលារៀន ព្រមទាំងផ្ដល់ជាឧបករណ៍សម្រាប់បង្កើនការចូលរួមរបស់មាតាបិតាសិស្ស និងសហគមន៍ផងដែរ។

ការកសាងឯកសារណែនាំនេះ និងការអភិវឌ្ឍសមត្ថភាពក្រុមគោលដៅ ត្រូវបានធ្វើឡើងដោយក្រុមការងាររបស់ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងកិច្ចការនារី, អង្គការ VVOB, អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (KAPE), អង្គការពុទ្ធិកុមារ (PKO), និងអង្គការយេនឌ័រនិងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC) ក្រោមជំនួយឧបត្ថម្ភរបស់សហភាពអឺរ៉ុប និងរដ្ឋាភិបាលប្រទេសប៊ែលហ្ស៊ិក។

ក្រសួងអប់រំ យុវជន និងកីឡាមានក្ដីសង្ឃឹមយ៉ាងមុតមាំថា គណៈគ្រប់គ្រងសាលារៀន គ្រូឧទ្ទេសនៅវិទ្យាស្ថានគរុកោសល្យ និងលោកគ្រូ អ្នកគ្រូ នឹងប្រើឯកសារណែនាំនេះជាជំនួយក្នុងការដឹកនាំវិទ្យាស្ថានគរុកោសល្យ សាលារៀន និងក្នុងការបង្រៀន និងរៀន ដើម្បីចូលរួមលើកកម្ពស់ភាពឆ្លើយតបសមភាពយេនឌ័រក្នុងវិស័យអប់រំ។

តាងនាមក្រសួងអប់រំ យុវជន និងកីឡា ខ្ញុំសូមថ្លែងអំណរគុណដោយស្មោះចំពោះប្រតិភូសហភាពអឺរ៉ុបប្រចាំនៅកម្ពុជា និងរដ្ឋាភិបាលប៊ែលហ្ស៊ិក ដែលបានផ្ដល់ការគាំទ្រ ក៏ដូចជាជំនួយបច្ចេកទេសដល់ក្រុមការងារ ដើម្បីកសាងឯកសារណែនាំដ៏មានសារៈសំខាន់នេះ។

ថ្ងៃចន្ទ ១០រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០២០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# អារម្ភកថា

ឯកសារណែនាំស្តីការឆ្លើយតបនឹងសមភាពយេនឌ័រត្រូវបានរៀបចំឡើង ដោយមានកិច្ចសហការ រវាងក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងកិច្ចការនារីជាមួយអង្គការ VVOB - ការអប់រំដើម្បីការអភិវឌ្ឍន៍ អង្គការ KAPE អង្គការពុទ្ធិកុមារ និងអង្គការ GADC។

ឯកសារណែនាំនេះនឹងក្លាយជាផែនទីបង្ហាញផ្លូវដើម្បីសម្របសម្រួលដំណើរការកសាងសមត្ថភាព គណៈគ្រប់គ្រងវិទ្យាស្ថានគរុកោសល្យ គណៈគ្រប់គ្រងសាលារៀន និងលោកគ្រូ អ្នកគ្រូនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាដើម្បីចូលរួមប្រែក្លាយស្ថាប័នរបស់គាត់ទៅជាបរិស្ថានមួយដែលគ្មានអំពើហិង្សាយេនឌ័រ។

នៅក្នុងដំណើរការនៃការរៀបចំឯកសារនេះ អ្នកនិពន្ធយើងខ្ញុំបានសិក្សាឯកសារពាក់ព័ន្ធ និងបានធ្វើការស្ទង់មតិជាមួយគ្រូឧទ្ទេសនៅវិទ្យាស្ថានគរុកោសល្យ គ្រូបឋមសិក្សា និងមធ្យមសិក្សា។ ការស្ទង់មតិនេះផ្តោតលើរបៀបដែលគ្រូឧទ្ទេសនៅវិទ្យាស្ថានគរុកោសល្យ គ្រូបង្រៀននៅសាលាបឋមសិក្សា និងមធ្យមសិក្សាដោះស្រាយបញ្ហាដែលកើតមានពាក់ព័ន្ធនឹងការសម្លុតគំរាម អំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រវត្តមាន បទដ្ឋាន និងការរំពឹងទុកពាក់ព័ន្ធនឹងយេនឌ័រនៅក្នុងបរិស្ថានសាលារៀន។ ផ្អែកលើលទ្ធផលនៃការស្ទង់មតិនេះ ក្រុមការងារយើងបានរៀបចំចងក្រងជាឯកសារណែនាំនេះឡើងដើម្បីជាជំនួយដល់ការងារបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន ផ្តោតលើការអប់រំដែលឆ្លើយតបនឹងសមភាពយេនឌ័រ។ ឯកសារនេះចែកចេញជា ២ផ្នែកសំខាន់ៗ គឺ៖

1. ផ្នែកទី១ សម្រាប់គ្រូបង្រៀន៖ វិធីបង្រៀន និងរៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ។ ផ្នែកនេះផ្តល់ព័ត៌មាន និងឧបករណ៍សំខាន់ៗសម្រាប់គ្រូយកទៅប្រើប្រាស់ញ៉ាំងឱ្យការបង្រៀន និងរៀនរបស់គាត់កាន់តែមានភាពឆ្លើយតបនឹងសមភាពយេនឌ័រ (ឧ. ការរៀបចំកិច្ចតែងការបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ ការប្រើសម្ភារឧបទេសដែលឆ្លើយតបនឹងសមភាពយេនឌ័រ និងការប្រើឧបករណ៍វាយតម្លៃដែលឆ្លើយតបនឹងសមភាពយេនឌ័រជាដើម។ល។)
2. ផ្នែកទី២ សម្រាប់គណៈគ្រប់គ្រងសាលារៀន៖ ភាពជាអ្នកដឹកនាំសាលារៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ។ ផ្នែកនេះ ផ្តល់ព័ត៌មាន អំពី លក្ខណៈសម្បត្តិរបស់សាលារៀន និងវិទ្យាស្ថានគរុកោសល្យដែលឆ្លើយតបនឹងសមភាពយេនឌ័រ និងផ្តល់ឧបករណ៍ដើម្បីជំនួយដល់គណៈគ្រប់គ្រងវិទ្យាស្ថានគរុកោសល្យ និងសាលារៀនក្នុងការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រនៅក្នុងសាលារៀន ភាពឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការធ្វើផែនការសកម្មភាព ផែនការថវិកា និងការអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំអំពីភាពឆ្លើយតបនឹងសមភាពយេនឌ័រជាដើម។ ផ្នែកទី២នៃឯកសារណែនាំនេះក៏បានដាក់បញ្ចូលខ្លឹមសារស្តីពីសារសំខាន់នៃការចូលរួមរបស់មាតាបិតាសិស្ស និងសហគមន៍ ដើម្បីលើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រនៅក្នុងសាលារៀន និងវិធីបង្កើនការចូលរួមរបស់មាតាបិតាសិស្ស និងសហគមន៍ផងដែរ។

ផ្នែកទាំងពីរនេះមានសេចក្តីផ្តើមដូចគ្នាដែលផ្តល់ព័ត៌មានមូលដ្ឋានពាក់ព័ន្ធនឹងយេនឌ័រ (ឧ. ភាពខុសគ្នារវាងភេទ និងយេនឌ័រ ផ្នត់គំនិតយេនឌ័រក្នុងវិស័យអប់រំ។ល។)

យើងសង្ឃឹមយ៉ាងមុតមាំថាសៀវភៅនេះនឹងជា ជំនួយដល់គណៈគ្រប់គ្រងវិទ្យាស្ថានគរុកោសល្យ គណៈគ្រប់គ្រងសាលារៀន គ្រូឧទ្ទេស គរុសិស្ស គរុនិស្សិតរួមទាំងលោកគ្រូ អ្នកគ្រូក្នុងដំណើរការប្រែក្លាយវិទ្យាស្ថានគរុកោសល្យ និងសាលារៀនជាស្ថាប័នដែលឆ្លើយតបនឹងសមភាពយេនឌ័រ និងដើម្បីលើកកម្ពស់ការបង្រៀន និងរៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រដែលអាចចូលរួមទប់ស្កាត់ អំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រក្នុងវិទ្យាស្ថានគរុកោសល្យ និងក្នុងសាលារៀន។

ដើម្បីបន្តកែលម្អឯកសារណែនាំនេះឱ្យកាន់តែមានភាពសុក្រឹត ក្រុមការងារយើងខ្ញុំរង់ចាំទទួលនូវរាល់ការរិះគន់កែលម្អស្ថាបនាពីសំណាក់អ្នកប្រើប្រាស់ និងមិត្តអ្នកអានគ្រប់មជ្ឈដ្ឋាន។

គណៈកម្មការនិពន្ធ

# សេចក្តីផ្តើម

ក្នុងអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ព្រះរាជាណាចក្រកម្ពុជាសម្រេចបានការបន្ថយគម្លាតយេនឌ័រក្នុងការចុះឈ្មោះចូលរៀននៅបឋមសិក្សា។ ក្នុងឆ្នាំសិក្សា២០១៨-២០១៩ អត្រាចុះឈ្មោះចូលរៀនរបស់សិស្សស្រីមាន ៤៩% បើប្រៀបធៀបទៅនឹងអត្រាចុះឈ្មោះចូលរៀនរបស់សិស្សប្រុសដែលមាន ៥១%។ ប៉ុន្តែ បន្ទាប់ពីចុះឈ្មោះចូលរៀនរួច មានសិស្សមួយចំនួនបានបោះបង់ចោលការសិក្សា ជាពិសេសសិស្សមកពីគ្រួសារក្រីក្រ ដើម្បីរកការងារធ្វើយកប្រាក់ចំណូលមកឧបត្ថម្ភជីវភាពគ្រួសារ។ អត្រាឆ្លងភូមិសិក្សាទៅកម្រិតមធ្យមសិក្សាក៏នៅតែបន្តជាបញ្ហាដដែល ជាពិសេសសម្រាប់ក្មេងស្រី។ សម្រាប់ក្មេងស្រីវ័យជំទង់ សាលារៀនជាទីកន្លែងដែលមិនទាន់មានសុវត្ថិភាពគ្រប់គ្រាន់សម្រាប់ពួកគេនៅឡើយ។ មាតាបិតាសិស្ស និង សិស្សស្រីខ្លួនឯងផ្ទាល់មានការព្រួយបារម្ភពីការបៀតបៀននៅសាលារៀន និង នៅតាមផ្លូវទៅសាលារៀន។ សិស្សស្រីផ្សេងៗទៀតមិនមានលទ្ធភាពទិញផលិតផលសុខភាពស្ត្រី ឬ សាលារៀនរបស់ពួកគេមិនមានហេដ្ឋារចនាសម្ព័ន្ធ ដូចជាបន្ទប់ទឹកស្រីដែលមានលក្ខខណ្ឌគ្រប់គ្រាន់[1]។ បរិបទវប្បធម៌ទាក់ទងនឹងយេនឌ័រនៅតែជាឧបសគ្គចំពោះការអប់រំមធ្យមសិក្សាសម្រាប់សិស្សស្រី។ គ្រួសារមួយចំនួនបានផ្តល់អាទិភាពក្នុងការបញ្ជូនកូនប្រុសទៅរៀនមុនកូនស្រី ដោយជឿថាកូនស្រីរបស់ពួកគេនឹងក្លាយជាស្ត្រីមេផ្ទះក្រោយពេលរៀបការរួច មិនអាចទ្រាំនឹងការសិក្សាបាន ត្រូវទទួលខុសត្រូវមើលថែទាំកូន កិច្ចការផ្ទះ និងការចម្អិនម្ហូបអាហារជាដើម។ ជាក់ស្តែង បញ្ហាពាក់ព័ន្ធនឹងទំនាក់ទំនង និងឥរិយាបថយេនឌ័រចាំបាច់ត្រូវការដំណោះស្រាយ។ ការអប់រំគឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយដើម្បីកែប្រែការយល់ឃើញ និងការរំពឹងទុកមិនសមហេតុផល តាមរយៈការបង្កើនការយល់ដឹង ស្មារតី និងបំណិនសម្រាប់កុមារដើម្បីលើកកម្ពស់សមភាពយេនឌ័រនិងចូលរួមក្នុងការអភិវឌ្ឍប្រកបដោយចីរភាព។ សៀវភៅណែនាំនេះនឹងត្រួសត្រាយផ្លូវដើម្បីឈានទៅរកបរិស្ថានមួយដែលឆ្លើយតបទៅនឹងសមភាពយេនឌ័រ ហើយឯកសារនេះក៏រួមបញ្ចូលគ្នានូវគំនិត យុទ្ធសាស្ត្រ និងឧបករណ៍ផ្សេងៗសម្រាប់គ្រូ នាយកសាលា គ្រូឧទ្ទេស និងសមាជិកសហគមន៍សាលារៀនផងដែរ។

[1] VVOB vzw (Ed.). (2019). *Putting SDG4 into practice: Enhancing adolescent wellbeing, learning and opportunities* (1st ed.). Brussels: VVOB vzw.

## គណៈកម្មការនិពន្ធ

## គណៈគ្រប់គ្រង

១. ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន — រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

២. ឯកឧត្តមបណ្ឌិតសភាចារ្យ ណាត ប៊ុនរឿន — រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា

## គណៈកម្មការប្រឹក្សាយោបល់

១. ឯកឧត្តម អ៊ុង បូរាត — នាយកខុទ្ទកាល័យក្រសួងអប់រំ យុវជន និងកីឡា

២. លោក ម៉ៅ សំរិទ្ធី — អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ

៣. លោក ឈុន វ៉ាមី — អនុប្រធាននាយកដ្ឋានបឋមសិក្សា

៤. លោក ទិត្យ សាខន — អនុប្រធាននាយកដ្ឋានសុខភាពសិក្សា

៥. លោកស្រី វង គឹមលាង — អនុប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

៦. លោកស្រី តែ ដាលីន — អនុប្រធាននាយកដ្ឋានស្ត្រី និងការអប់រំ នៃក្រសួងកិច្ចការនារី

៧. លោកស្រី គង់ ចាន់បុស្សិបា — អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកណ្តាល

៨. លោកស្រី មាស ភិរុណ — អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តបាត់ដំបង

៩. កញ្ញា ណុប ពុទ្ធាវី — មន្ត្រីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

១០. លោក ទ្រី ហាក់ — ប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុងបាត់ដំបង

១១. លោក ស៊ីវ សុខវណ្ណា — ប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុកសង្កែ

១២. លោកស្រី យុន ចាន់ធុន — អនុប្រធានការិយាល័យស្ត្រីនិងសុខភាពស្ត្រីនិងការអប់រំ

១៣. លោកស្រី យឹម សុភី — អនុប្រធានការិយាល័យសមភាពយេនឌ័រនៃមន្ទីរកិច្ចការនារី ខេត្តបាត់ដំបង

១៤. លោកស្រី រ៉ន ហៃមសុជាតា — ប្រធានការិយាល័យកិច្ចការនារី ក្រុងបាត់ដំបង

**គណៈកម្មការនិពន្ធ និងរៀបរៀង**

| | |
|---|---|
| ១. លោក សយ សំផុន | ប្រធានគម្រោងអង្គការ VVOB |
| ២. លោក ហៀង សារីម | ប្រធានគម្រោងអង្គការ VVOB |
| ៣. កញ្ញា Karolina Rutkowska | ទីប្រឹក្សាអភិវឌ្ឍន៍សមត្ថភាព អង្គការ VVOB |
| ៤. កញ្ញា Lotte Van Praet | ទីប្រឹក្សាអប់រំ អង្គការ VVOB |
| ៥. កញ្ញា Line Kuppens | ទីប្រឹក្សាអប់រំជាន់ខ្ពស់ អង្គការ VVOB |
| ៦. លោកស្រី ស៊ុន ម៉ាលី | អ្នកសម្របសម្រួលគម្រោង អង្គការ VVOB |
| ៧. លោក កែវ មនោ | ទីប្រឹក្សាអប់រំ អង្គការ VVOB |
| ៨. លោកស្រី អ៊ុក សុធីរ៉ា | ទីប្រឹក្សាផ្នែកយេនឌ័រ អង្គការ KAPE |
| ៩. លោក រឿន សត្យា | មន្ត្រីជាន់ខ្ពស់ផ្នែកយេនឌ័រ អង្គការ GADC |
| ១០. លោក ឈួន ចំរើន | មន្ត្រីគម្រោង អង្គការ PKO |
| ១១.លោក កយ លីវឿត | មន្ត្រីអប់រំផ្នែកយេនឌ័រ អង្គការ KAPE |

# ជំពូកទី១

# សេចក្តីផ្តើមអំពីយេនឌ័រ នឹងភាពឆ្លើយតបនឹងសមភាពយេនឌ័រ

# មេរៀនទី១

## ភាពខុសគ្នារវាងភេទ និងយេនឌ័រ

### I. សេចក្ដីផ្ដើម

រហូតមកទល់នឹងពេលនេះ ពាក្យថា "ភេទ" និង "យេនឌ័រ" ត្រូវបានប្រើជំនួសគ្នាទៅវិញទៅមក។ នៅពេលនិយាយពីយេនឌ័រ អ្នកខ្លះគិតថាវាជាពាក្យមួយផ្សេងទៀតសម្រាប់ "ភេទ" ឬសូម្បីតែប្រើពាក្យនេះសំដៅលើ "ស្ត្រី" និង "ក្មេងស្រី"។ នៅក្នុងមេរៀននេះ យើងនឹងយល់កាន់តែច្បាស់ពីអត្ថន័យ នៃពាក្យថា "ភេទ" និង "យេនឌ័រ" បន្ទាប់មក យើងនឹងបង្ហាញអំពីខ្លឹមសារនៃបញ្ញត្តិតួនាទីយេនឌ័រ និងសមភាពយេនឌ័រ។ ចំណេះដឹងទាំងនេះមានសារៈសំខាន់ដើម្បីដោះស្រាយការយល់ច្រឡំ អំពីភេទ និងយេនឌ័រក្នុងន័យជួយកាត់បន្ថយគម្លាតយេនឌ័រនៅក្នុងការអប់រំ។

### II. វត្ថុបំណង

- ពន្យល់ពីអត្ថន័យពាក្យថា "ភេទ" និង "យេនឌ័រ" ឱ្យបានច្បាស់លាស់
- កំណត់អត្ថន័យ "ភេទ" និង "យេនឌ័រ" ដោយពុំមានការភាន់ច្រឡំ
- ពន្យល់បញ្ញត្តិតួនាទីយេនឌ័រ និងសមភាពយេនឌ័រ
- បណ្ដុះគំនិត និងឥរិយាបទ ដើម្បីលើកកម្ពស់សមធម៌ និងសមភាពយេនឌ័រ។

### III. ខ្លឹមសារ

#### ក. និយមន័យ

អ្នកឯកទេសផ្នែកយេនឌ័រ បានកំណត់និយមន័យពីភេទ[2]ថាជាលក្ខណៈខុសគ្នាផ្នែកជីវសាស្ត្ររវាងមនុស្សស្រី និងមនុស្សប្រុស ដែលបានកំណត់ជាសកលពីកំណើត និងមិនអាចកែប្រែបានដោយធម្មជាតិនោះទេ។ ពេលចាប់កំណើតមក ទារកត្រូវបានគេកំណត់ថាមានភេទជា "ស្រី ប្រុស" អាស្រ័យលើសរីរាង្គភេទរបស់ពួកគេ។ ជួនកាល ទារកកើតមកមានបុគ្គលិកលក្ខណៈ បែបជាស្រីផង និងជាប្រុសផង ឬពួកគេមិនមានលក្ខណៈជាក់លាក់ថាជាភេទប្រុស ឬស្រីនោះទេ។ កុមារទាំងនេះមិនមែនជាភេទស្រី ក៏មិនមែនជាភេទប្រុសដែរ ប៉ុន្តែជាអន្តរភេទ។ ករណីនេះកម្រនឹងកើតមានណាស់។

[2] Training Manual on Gender Principles and Gender Mainstreaming (Department of Gender Equality, the Ministry of Women's Affairs)

**យេនឌ័រ**[3] គឺជាការបង្កើតឡើងរបស់សង្គម ប៉ុន្តែមិនមែនជាកត្តាជីវសាស្ត្រនោះទេ។ យេនឌ័រគឺជាទំនាក់ទំនងរវាងក្មេងស្រី និងក្មេងប្រុស ទំនាក់ទំនងរវាងស្ត្រី និងបុរសនៅក្នុងគ្រួសារ សហគមន៍ និងសង្គម។ ទំនាក់ទំនងទាំងនេះកើតចេញពីការបែងចែកសិទ្ធិអំណាច ឋានៈ តួនាទី ការងារ ភារកិច្ច នៅក្នុងសង្គមមួយ។ ដោយសារមូលហេតុនេះ ទំនាក់ទំនងយេនឌ័រអាស្រ័យទៅលើបរិបទ។ យេនឌ័រក៏អាស្រ័យទៅលើពេលវេលាដែរ។ យេនឌ័រមិនរក្សានៅដដែលជានិច្ចនោះទេ ប៉ុន្តែអាចប្រែប្រួលទៅតាមពេលវេលា និងស្រប ទៅតាមកាលៈទេសៈ។

នៅផ្នែកទ្រឹស្តី អ្នកឯកទេសយេនឌ័រ បានកំណត់និយមន័យថា "យេនឌ័រសំដៅទៅលើ ឥរិយាបថ និងអាកប្បកិរិយារបស់មនុស្សប្រុស ឬមនុស្សស្រី ដែលមានលក្ខណៈខុសគ្នាទៅតាមសង្គម និងវប្បធម៌ ហើយវាអាចប្រែប្រួលទៅតាមកាលៈទេសៈ"។ និយាយម្យ៉ាងទៀត បទដ្ឋាន និងការរំពឹងទុកអំពីយេនឌ័រ ជះឥទ្ធិពលលើអាកប្បកិរិយា អន្តរកម្ម និងបំណងប្រាថ្នារបស់ ក្មេងស្រី និងក្មេងប្រុស មនុស្សស្រី និងមនុស្សប្រុស។

**ខ. ភាពខុសគ្នារវាងភេទ និងយេនឌ័រ**

នៅក្នុងសង្គមនីមួយៗ មានផ្នត់គំនិត និងការរំពឹងទុកជាច្រើនពាក់ព័ន្ធនឹងយេនឌ័រដែលជះឥទ្ធិពលលើទំនាក់ទំនងយេនឌ័រចាប់តាំងពីវ័យកុមារ។ នៅកម្ពុជា ឪពុកម្តាយរំពឹងទុកថាកូនស្រីត្រូវតែស្អាត និងទន់ភ្លន់ ចំណែកឯកូនប្រុសវិញ ត្រូវតែខ្លាំង និងរឹងមាំ។ កូនស្រីត្រូវបានបង្រៀនឱ្យចេះដាំស្ល ចេះសម្អាត និងតម្រូវឱ្យមើលថែទាំប្អូន ខណៈដែលក្មេងប្រុសត្រូវបានលើកទឹកចិត្តឱ្យគិតស្រមៃធ្វើជាវិស្វករ ឬវេជ្ជបណ្ឌិត។ សម្លៀកបំពាក់ ប្រដាប់លេង និងសម្ភារៈសិក្សារបស់ក្មេងស្រី ភាគច្រើនមានពណ៌ផ្កាឈូក ចំពោះក្មេងប្រុសវិញ សម្ភារៈរបស់ពួកគេ ជានិច្ចកាល មានពណ៌ខៀវ។ ភាពខុសគ្នាទាំងនេះមិនមែនកើតមកពី ធម្មជាតិនោះទេ ប៉ុន្តែបណ្តាលមកពីបទដ្ឋាន ប្រពៃណី និងផ្នត់គំនិតយេនឌ័រ។

| **ភេទ និងយេនឌ័រ**[4] | |
|---|---|
| **ភេទ** | **យេនឌ័រ** |
| កត្តា និងលក្ខខណ្ឌជីវសាស្ត្រពីកំណើត | កត្តា និងលក្ខខណ្ឌសង្គម មិនមែនពីកំណើត |
| មិនអាចកែប្រែបាន | អាចកែប្រែបាន |
| **ឧទាហរណ៍:** | |
| ១. មានតែស្ត្រីទេដែលមានរដូវ<br>២. មានតែស្ត្រីទេដែលអាចមានគភ៌បាន | ១. "ក្មេងស្រីគួរតែទន់ភ្លន់ ក្មេងប្រុសគួរតែរឹងប៉ឹង"<br>២. "ស្ត្រីនៅផ្ទះ ហើយបុរសចេញទៅធ្វើការរក |

[3] បំណិនជីវិតយេនឌ័រសម្រាប់បឋមសិក្សា "ការយល់ដឹងពីយេនឌ័រ"

[4] ចំណេះដឹងយេនឌ័រ ការបញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ ឆ្នាំ២០១១

| | |
|---|---|
| ៣. មេជីវិតឈ្មោលរបស់បុរស (ស្ពែមម៉ាតូសូអ៊ីត) អាចធ្វើឱ្យស្ត្រីមានផ្ទៃពោះបាន<br>៤. បុរសដុះពុកមាត់ និងពុកចង្ការ ស្ត្រីមានរោមមុខតិច ។ | ប្រាក់ចំណូល"<br>៣. "ស្ត្រីសិក្សាដើម្បីក្លាយជាគ្រូបង្រៀន ហើយបុរសសិក្សាដើម្បីក្លាយជាវិស្វករ។ |

**ទី៖ យេនឌ័រ**

យេនឌ័រមិនត្រឹមតែមានតួនាទីសំខាន់នៅក្នុងការរស់នៅរបស់មនុស្សប៉ុណ្ណោះទេ ថែមទាំងមានគុណតម្លៃសំខាន់ចំពោះសង្គមទៀតផង។ មានការរំពឹងទុកជាក់លាក់មួយចំនួនរបស់សង្គមពាក់ព័ន្ធនឹងតួនាទី និងអាកប្បកិរិយារបស់ស្ត្រី និងបុរស។ តួនាទីយេនឌ័រជាអាកប្បកិរិយាមួយចំនួនដែលអាចរៀនសូត្របាននៅក្នុងសង្គម ឬសហគមន៍មួយដែលបានរំលេចឡើងតាមរយៈសកម្មភាព កិច្ចការ និងការទទួលខុសត្រូវដែលត្រូវបានផ្សារភ្ជាប់ទៅនឹងស្ត្រី និងបុរស ក្មេងស្រី និងក្មេងប្រុសផ្អែកទៅលើការយល់ឃើញពីភាពខុសគ្នារវាងពួកគេ។

ដោយសារការរំពឹងទុកពាក់ព័ន្ធនឹងយេនឌ័រ ជាញឹកញាប់ស្ត្រីត្រូវទទួលបន្ទុកកិច្ចការដែលគ្មានប្រាក់កម្រៃ ហើយបុរសធ្វើការងារដែលមានប្រាក់កម្រៃ ដែលប្រការនេះក៏ប៉ះពាល់ដល់ទំនាក់ទំនងសិទ្ធិអំណាចរវាងបុរស និងស្ត្រីដែរ។ យើងអាចបែងចែកការងារជា ៣ប្រភេទដូចខាងក្រោម[5]៖

- **ការងារមានកម្រៃ** គឺជាការងារទទួលបានប្រាក់ចំណូល។ ការងារមានកម្រៃសំដៅលើការងារផលិត ឬសេវារកប្រាក់ចំណូលសម្រាប់គ្រួសារ។
- **ការងារគ្មានកម្រៃ** គឺជាការងារដែលមិនបានទទួលប្រាក់ចំណូល។ ការងារគ្មានកម្រៃសំដៅលើការងារមើលថែទាំកូន និងការងារផ្ទះផ្សេងៗ ។
- **ការងារសហគមន៍** គឺជាការងារស្ម័គ្រចិត្ត ដើម្បីផលប្រយោជន៍រួមក្នុងសហគមន៍។ ការងារសហគមន៍សំដៅលើការងារចូលរួមផ្សព្វផ្សាយសេវាអប់រំ ការអភិវឌ្ឍភូមិឃុំ និងការងាររៀបចំពិធីបុណ្យទានផ្សេងៗជាដើម។

ពាក្យថា**ការបែងចែកការងារផ្អែកលើយេនឌ័រ**សំដៅលើការផ្តល់តួនាទីផ្សេងគ្នាទៅឱ្យស្ត្រី និងបុរសនៅក្នុងសង្គម និងដោយសង្គម។ តួនាទីទាំងនេះមាននិន្នាការរើសអើងខ្លាំង។ ទោះបីជាមានភាពខុសប្លែកគ្នាផ្នែកសង្គម និងវប្បធម៌ក្តី ស្ត្រីមានទំនោរទទួលបានមួយភាគធំនៃការងារផ្ទះដែលមិនទទួលបានប្រាក់ចំណូល។ ដោយសារតែមានផ្នត់គំនិតយេនឌ័រនៅក្នុងកម្លាំងពលកម្ម និងប្រព័ន្ធអប់រំបានបង្ហាញឱ្យឃើញថាមានស្ត្រីជាច្រើនកំពុងជាប់ជាមួយនឹងការងារដែលមិនសូវទាមទារជំនាញ មិនសូវត្រូវ

[5] ឯកសារបណ្តុះបណ្តាលស្តីពីគោលគំនិតយេនឌ័រ និងការបញ្ជ្រាបយេនឌ័រ (នាយកដ្ឋានសមភាពយេនឌ័រ-ក្រសួងកិច្ចការនារី)

បានគេឱ្យតម្លៃ ហើយទទួលបានប្រាក់កម្រៃទាប ខណៈដែលបុរសមានទំនោរទទួលបានការងារដែលត្រូវបានគេឱ្យតម្លៃខ្ពស់ និងទទួលបានកម្រៃខ្ពស់ជាង។

លើសពីនេះទៅទៀត ការរើសអើងដែលកើតមាននៅក្នុងផ្ទះ ត្រូវបានពាំនាំទៅក្នុងមជ្ឈដ្ឋានសាធារណៈ ដែលការងារមួយចំនួនត្រូវការបំណិនដែលគេយល់ថាជាបុគ្គលិកលក្ខណៈរបស់ស្ត្រីមិនសូវត្រូវបានគេឱ្យតម្លៃនោះទេ។

បញ្ហានេះមិនមែនដោះស្រាយដោយរៀបចំឱ្យស្ត្រី និងបុរសផ្លាស់ប្តូរការងារគ្នាទៅវិញទៅមក ឬឱ្យស្ត្រីរៀនសូត្រតាមបុគ្គលិកលក្ខណៈរបស់បុរសហួតធ្វើឱ្យប៉ះពាល់ដល់វដ្តជីវសាស្ត្រពីធម្មជាតិរបស់ពួកគេនោះទេ។ ផ្ទុយទៅវិញ បញ្ហានេះអាចដោះស្រាយបាននៅពេលដែលទាំងបុរស និងស្ត្រីទទួលបានឱកាសស្មើគ្នាក្នុងការទទួលបានការអប់រំ បណ្តុះបណ្តាល និងប្រភេទការងារដូចគ្នា ដើម្បីឱ្យពួកគេទទួលបានតម្លៃស្មើគ្នាចំពោះការចូលរួមក្នុងផ្នែកសេដ្ឋកិច្ចគ្រួសារ និងការអភិវឌ្ឍជាតិ។

### ឃ. សមភាពយេនឌ័រ

*សុកញ្ញាជាក្មេងស្រីម្នាក់ដ៏ឆ្លាតវៃ ហើយពូកែគណិតវិទ្យា។ នាងសុបិនចង់ក្លាយជាវិស្វករម្នាក់ ប៉ុន្តែឪពុកម្តាយរបស់នាងចង់ឱ្យបងប្រុសនាងចូលរៀនច្រើនជាង។ តើអ្នកយល់ឃើញដូចម្តេចដែរ? តើមិនគួរលើកចិត្តសុកញ្ញាឱ្យក្លាយជាវិស្វករមួយរូបទេឬ?*

សមភាពយេនឌ័រ ឬភាពស្មើគ្នារវាងស្ត្រី និងបុរសសំដៅលើការទទួលបានស្មើគ្នាដោយស្ត្រី និងបុរសនូវសម្ភារដែលត្រូវបានសង្គមឱ្យតម្លៃ ឱកាស ធនធាន និងរង្វាន់ផ្សេងៗដោយមិនប្រកាន់វ័យ ហើយមិនប្រកាន់ទំនោរភេទ។

សមភាពមិនមែនមានន័យថាស្ត្រី និងបុរសដូចគ្នានោះទេ ប៉ុន្តែមានន័យថាសិទ្ធិ និងឱកាសរបស់ពួកគេមិនត្រូវបានដាក់កំហិតដោយសារតែពួកគេបានកើតមកមានភេទប្រុស ឬភេទស្រីនោះទេ។

សមភាពយេនឌ័រៈ

- សំដៅលើសិទ្ធិ ការទទួលខុសត្រូវ និងឱកាសស្មើគ្នារបស់ស្ត្រី និងបុរស ក្មេងស្រី និងក្មេងប្រុស ដើម្បីទទួលបាន និងគ្រប់គ្រងសម្ភារ និងធនធានរបស់សង្គម
- បង្ហាញថាផលប្រយោជន៍ តម្រូវការ និងអាទិភាពរបស់ស្ត្រី និងបុរសត្រូវបានយកមកពិចារណា
- មិនមែនផ្តោតតែទៅលើស្ត្រីតែមួយមុខនោះទេ ប៉ុន្តែរាប់បញ្ចូលការចូលរួមពេញលេញទាំងស្ត្រី និងបុរស
- ត្រូវបានចាត់ទុកជាបញ្ហាសិទ្ធិមនុស្ស និងជាលក្ខខណ្ឌ និងសូចនាករនៃការអភិវឌ្ឍដោយចីរភាពដែលផ្តោតទៅលើមនុស្ស។

### ង.សមធម៌យេនឌ័រ

សមធម៌យេនឌ័រគឺជាបញ្ញត្តិមួយដែលឃ្លាតមិនឆ្ងាយពីសមភាពយេនឌ័រនោះទេ។ បើនិយាយឱ្យកាន់តែជាក់លាក់ជាងនេះ សមធម៌យេនឌ័រផ្តោតលើលក្ខខណ្ឌ ឬមធ្យោបាយដែលចាំបាច់ដើម្បីសម្រេចឱ្យបានសមភាពយេនឌ័រ។ កញ្ចប់ឧបករណ៍របស់អង្គការយូនីស្កូអំពីយេនឌ័រក្នុងបណ្តាញអប់រំអាស៊ីប៉ាស៊ីភិច ដែលមានពាក្យពេញថា Gender in Education Network in Asia-Pacific (GENIA) Toolkit កំណត់និយមន័យសមធម៌យេនឌ័រក្នុងវិស័យអប់រំ ថាជាវិធានការពិសេសដើម្បីទប់ទល់នឹងឧបសគ្គដែលបានរាំងស្ទះសិស្សប្រុស និងសិស្សស្រីមិនឱ្យទទួលបានឱកាសអប់រំស្មើៗគ្នា។ ឧទាហរណ៍ វិធានការសមធម៌អាចលម្អៀងទៅខាងក្មេងស្រីដើម្បីពង្រឹងអំណាចពួកគេ ជួយឱ្យពួកគេអាចទម្លុះឧបសគ្គនៃការរើសអើងដើម្បីអាចតាមទាន់ក្មេងប្រុស។ វិធានការសមធម៌ក៏ត្រូវបានគេហៅផងដែរថាជាការរើសអើងបែបវិជ្ជមាន ឬសកម្មភាពវិជ្ជមាន។ វិធានការសមធម៌អាចមិនមានលក្ខណៈស្មើភាពនោះទេ ប៉ុន្តែត្រូវបានគេអនុវត្តដើម្បីសម្រេចលទ្ធផលដែលមានភាពយុត្តិធម៌ និងសមភាព។ ឧទាហរណ៍ ការផ្តល់ប្រាក់អាហារូបករណ៍ ឬបៀវត្សរ៍ឱ្យសិស្សស្រីមានគោលបំណងបង្កើនលទ្ធភាពទទួលបានការអប់រំរបស់ពួកគេ។

## IV. សកម្មភាព

### សកម្មភាព ក៖ តើជាភេទ ឬយេនឌ័រ?

សូមអានប្រយោគខាងក្រោម ហើយបញ្ជាក់ថាតើប្រយោគនោះផ្តោតលើភេទ ឬយេនឌ័រ។ បន្ទាប់មក សូមពិភាក្សាចម្លើយរបស់អ្នកជាមួយមិត្តរួមការងារ ឬសិក្ខាកាមផ្សេងទៀត។

| ល.រ | ខ្លឹមសារ | យេនឌ័រ | ភេទ |
|---|---|---|---|
| ១ | បុរសចូលចិត្តលេងបាល់ទាត់ | | |
| ២ | ស្ត្រីបំបៅដោះកូនដោយទឹកដោះម្តាយ | | |
| ៣ | ស្ត្រីមានស្បូន មានគភ៌ និងបង្កើតកូនបាន បុរសមិនអាច | | |
| ៤ | ស្ត្រីទន់ភ្លន់ បុរសគំរោះគំរើយ | | |
| ៥ | ការបង្រៀននៅសាលាមត្តេយ្យជាមុខរបររបស់ស្ត្រី | | |
| ៦ | នៅក្នុងប្រទេសខ្លះ ស្ត្រីមិនអនុញ្ញាតឱ្យបើកបររថយន្តបានទេ | | |
| ៧ | សំឡេងរបស់បុរសផ្លាស់ប្តូរបាន ចំណែកស្ត្រីមិនប្តូរសំឡេងទេ | | |
| ៨ | ស្ត្រីប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ ពេលដែលស្វាមីរបស់ពួកគាត់មានដៃគូរួមភេទច្រើន | | |

| | | | |
|---|---|---|---|
| ៩ | នៅប្រទេសកម្ពុជា បុរសត្រូវចូលទៅស្ដីដណ្ដឹងស្ត្រីដើម្បីរៀបអាពាហ៍ពិពាហ៍ | | |
| ១០ | នៅកម្ពុជា កម្មករសំណង់ភាគច្រើនជាបុរស | | |
| ១១ | កាលពីសម័យមុន ឪពុកម្ដាយមិនសូវឱ្យកូនស្រី រៀនសូត្របានខ្ពង់ខ្ពស់ដល់កម្រិតឧត្តមសិក្សាទេ | | |
| ១២ | បុរសផលិតមេជីវិតឈ្មោល (ស្ពែមម៉ាតូសូអ៊ីត) | | |
| ១៣ | បុរសភាគច្រើនគិតថាមានកូនគឺបញ្ជាក់ថាគេជាបុរសពិត និងមានមោទកភាពចំពោះខ្លួនឯង | | |
| ១៤ | អ្នកវិទ្យាសាស្ត្រភាគច្រើនជាបុរស | | |
| ១៥ | ក្មេងប្រុសតែងតែខ្លាំង និងរឹងមាំ ចំណែកក្មេងស្រីតែងតែមានភាពទន់ខ្សោយ | | |
| ១៦ | ក្មេងស្រីចូលចិត្តពណ៌ផ្កាឈូក ក្មេងប្រុសចូលចិត្តពណ៌ខៀវ | | |
| ១៧ | ដងខ្លួនស្ត្រីស្រឡូន ចំណែកបុរសមានសាច់ដុំ។ | | |

អ្នកអាចផ្ទៀងផ្ទាត់ចម្លើយនៅក្នុងឧបសម្ពន្ធ ក នៅទំព័រទី១១៣។

## សកម្មភាព ខ៖ ត្រួតពិនិត្យមើលបទពិសោធន៍ និងជំនឿរបស់អ្នក

1. **សូមពិភាក្សាថាតើសមភាពយេនឌ័រកើតមាននៅក្នុងសហគមន៍របស់អ្នកដែរឬទេ៖**

- **តើអ្នកណាដែលជាគោលដៅងាយរងគ្រោះដោយសារអំពើហឹង្សាក្នុងគ្រួសារ និងអំពើហឹង្សាផ្លូវភេទ? ស្ត្រី ឬបុរស?**
- **ចំពោះស្ត្រី និងបុរសដែលធ្វើការងារដូចគ្នា តើអ្នកណាដែលមានទំនោរទទួលបានប្រាក់បៀវត្សរ៍ខ្ពស់ជាង? ស្ត្រី ឬបុរស?**
- **តើ អ្នកណាដែលច្រើនទទួលបានតួនាទី និងសិទ្ធិអំណាចធំជាង? នៅកន្លែងធ្វើការ? នៅផ្ទះ? ក្នុងកិច្ចការនយោបាយ? ក្នុងសហគមន៍? នៅក្នុងសាលារៀន?**
- **តើអ្នកណាដែលត្រូវទទួលបន្ទុកមើលថែទាំសមាជិកគ្រួសារ ជាពិសេសកុមារ និងអ្នកដែលមានជំងឺ?**

2. សូមសរសេរប្រយោគចំនួន៣ ដែលពន្យល់ពីមូលហេតុដែលស្ត្រីមិនទទួលបានឋានៈស្មើគ្នាជាមួយបុរសនៅគ្រប់វិស័យក្នុងសង្គម។
3. សូមកំណត់សកម្មភាពចំនួន២ដែលឆ្លើយតបនឹងសមភាពយេនឌ័រដែលបុរស និងស្ត្រីអាចអនុវត្ត (២សកម្មភាពសម្រាប់បុរស និង ២សកម្មភាពសម្រាប់ស្ត្រី) ដើម្បីចូលរួមបង្កើតសមភាពយេនឌ័រនៅក្នុងសហគមន៍ នៅក្នុងសាលារៀន និងនៅក្នុងគ្រួសារ។

## V. សេចក្តីសន្និដ្ឋាន

នៅក្នុងមេរៀននេះ យើងបានរកឃើញអត្ថន័យនៃយេនឌ័រ និងភេទ និងបានពិភាក្សាអំពីភាពខុសគ្នារវាងបញ្ញត្តិទាំងពីរ។ យេនឌ័រសំដៅលើកត្តា និងឱកាសផ្នែកសង្គមដែលជាប់ពាក់ព័ន្ធនឹងភេទប្រុស និងភេទស្រី និងទំនាក់ទំនងរវាងស្ត្រី និងបុរស ឬរវាងក្មេងស្រី និងក្មេងប្រុស។ វាមានឥទ្ធិពលធំទៅលើជីវភាពរស់នៅប្រចាំថ្ងៃ និងទៅលើសមភាពយេនឌ័រ។

ប្រការដែលគួរធ្វើ និងគួរចៀសវាង៖

- ញែកសម្គាល់ភាពខុសគ្នារវាងភេទ និងយេនឌ័រ
- ពុំគួរធ្វើសេចក្តីសន្និដ្ឋានថាមហាជនដឹងពីភាពខុសគ្នារវាងភេទ និងយេនឌ័រនោះទេ
- ព្យាយាមចោទសួរចំពោះបទដ្ឋានយេនឌ័រដែលមានលក្ខណៈប្រពៃណីដោយអាកប្បកិរិយាសមរម្យ
- ពុំគួរយល់ស្របចំពោះការយល់ឃើញណាមួយអំពីតួនាទី និងអាកប្បកិរិយារបស់ស្ត្រី និងបុរសភ្លាមៗនោះទេ គួរគិតឱ្យបានម៉ត់ចត់សិន
- គាំទ្រឱ្យមានសមភាពរវាងក្មេងស្រី និងក្មេងប្រុស និងរវាងស្ត្រី និងបុរស។

# មេរៀនទី២

## គោលនយោបាយលើកកម្ពស់សមភាពយេនឌ័រនៅកម្ពុជា

### I. សេចក្តីផ្តើម

បទដ្ឋាននិងការរំពឹងទុកអំពីយេនឌ័រជះឥទ្ធិពលដល់គ្រប់ដំណាក់កាលនៃការរស់នៅរបស់សិស្សានុសិស្ស។ ភាពខុសប្លែកគ្នានៃបទដ្ឋាន និងការរំពឹងទុកអំពីយេនឌ័រអាចមានផលប៉ះពាល់អវិជ្ជមានចំពោះលទ្ធភាពទទួលបាន និងចូលរួមក្នុងការអប់រំនៅគ្រប់កម្រិត ជាពិសេសសម្រាប់ក្មេងស្រី។ ក្នុងមេរៀននេះ យើងនឹងពិភាក្សាអំពីការចូលរួមចំណែករបស់គោលនយោបាយជាតិ និងអន្តរជាតិក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់ឱ្យក្មេងប្រុស និងក្មេងស្រីនូវឱកាសស្មើគ្នា ទាំងនៅផ្ទះ និងនៅសាលារៀន។

### II. វត្ថុបំណង

- ពិភាក្សាអំពីការប្តេជ្ញាចិត្តរបស់ស្ថាប័នអន្តរជាតិចំពោះសមភាពយេនឌ័រក្នុងវិស័យអប់រំ
- បង្ហាញទិដ្ឋភាពទូទៅនៃការប្តេជ្ញាចិត្តរបស់កម្ពុជាចំពោះសមភាពយេនឌ័រក្នុងវិស័យអប់រំ។

### III. ខ្លឹមសារ

#### ក. ការប្តេជ្ញាចិត្តរបស់ស្ថាប័នអន្តរជាតិដើម្បីសមភាពយេនឌ័រក្នុងវិស័យអប់រំ

ការអប់រំគឺជាសិទ្ធិមនុស្ស ហើយត្រូវបានគេយកចិត្តទុកដាក់ខ្លាំងនៅក្នុងសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិមួយចំនួន ដែលក្នុងនោះរួមមានសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (ឆ្នាំ១៩៤៨) អនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ និងមតិយោបល់ទូទៅនៃកិច្ចព្រមព្រៀងនេះ (ឆ្នាំ១៩៨៩) អនុសញ្ញារបស់អង្គការយូណេស្កូប្រឆាំងនឹងការរើសអើងក្នុងវិស័យអប់រំ (ឆ្នាំ១៩៦០) អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម និងសិទ្ធិវប្បធម៌ (ICESCR ឆ្នាំ១៩៦៦) និងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW ឆ្នាំ១៩៧៩)។

សមភាពយេនឌ័រក្នុងវិស័យអប់រំត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងកិច្ចព្រមព្រៀងរបស់អង្គការយូណេស្កូប្រឆាំងនឹងការរើសអើងក្នុងវិស័យអប់រំ ដោយបានលើកឡើងថា៖ "រដ្ឋភាគីដែលមានវត្តមានក្នុងកិច្ចព្រមព្រៀងនេះនឹងចូលរួមចំណែកបង្កើត កសាង និងអនុវត្តគោលនយោបាយជាតិដែល, (...) នឹងមានទំនោរលើកកម្ពស់ការទទួលបានឱកាស និងការឱ្យតម្លៃស្មើគ្នាក្នុងវិស័យអប់រំ[6] (...)"។

នៅក្នុងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) ដែលគេនិយមហៅថា Bill of Rights for Women ការរើសអើងត្រូវបានគេពណ៌នាថាជា៖ ... ភាពខុសគ្នាគ្រប់រូបភាព ការមិនរាប់បញ្ចូល ឬការដាក់កំហិតដែលកើតឡើងដោយផ្អែកលើភេទដែលបង្កផលប៉ះពាល់ ឬមានគោលបំណងកាត់បន្ថយ ឬលុបបំបាត់ការទទួលស្គាល់ ភាពសុខដុមរមនារបស់ស្ត្រី ដោយមិនគិតពី

[6] UNESCO. (1960). *Convention against Discrimination in Education*. Retrieved from http://www.unesco.org/education/pdf/DISCRI_E.PDF

ភាពនៅលីវ ឬរៀបការរបស់ពួកគេ ដោយផ្អែកលើមូលដ្ឋានសមភាពរវាងបុរស និងស្ត្រី សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គម វប្បធម៌ ស៊ីវិល ឬវិស័យណាមួយផ្សេងទៀត[7]។

នៅឆ្នាំ២០១៥ ប្រទេសសមាជិកអង្គការសហប្រជាជាតិបានចូលរួមរៀបចំ និងផ្តល់សច្ចាប័ននូវរបៀបវារៈនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍គឺជាផែនការសំខាន់ដើម្បីសម្រេចឱ្យបាននូវអនាគតកាន់តែប្រសើរ និងមាននិរន្តរភាពសម្រាប់ទាំងអស់គ្នា ដោយដោះស្រាយបញ្ហាធំជាសកលដូចជាបញ្ហាភាពក្រីក្រ វិសមភាព ការប្រែប្រួលអាកាសធាតុ ភាពសឹករេចរឹលនៃបរិស្ថាន និងភាពអយុត្តិធម៌ផ្សេងៗ។ សរុបទាំងអស់ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍មានគោលដៅ ១៧ចំណុច ដែលទាក់ទងគ្នាទៅវិញទៅមក ដែលត្រូវសម្រេចឱ្យបានត្រឹមឆ្នាំ២០៣០។ គោលដៅមួយក្នុងចំណោមគោលដៅទាំងនោះ ផ្តោតលើការធានាឱ្យមានការអប់រំប្រកបដោយគុណភាពសម្រាប់ទាំងអស់គ្នាត្រឹមឆ្នាំ២០៣០។ នៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ស្តីពីការអប់រំ គោលដៅចំនួន២ បានលើកឡើងអំពីសមភាពយេនឌ័រ ដូចជា (៤.១)៖ ត្រឹមឆ្នាំ២០៣០ ធានាថាគ្រប់ក្មេងប្រុស និងក្មេងស្រីទាំងអស់បញ្ចប់ការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សាដែលឥតគិតថ្លៃ ប្រកបដោយសមធម៌ និងគុណភាពដែលញ៉ាំងឱ្យពួកគេទទួលបានលទ្ធផលសិក្សាចំតម្រូវការ និងមានប្រសិទ្ធភាព និង (៤.៥)៖ ត្រឹមឆ្នាំ២០៣០ លុបបំបាត់វិសមភាពយេនឌ័រក្នុងវិស័យអប់រំ និងធានាលទ្ធភាពស្មើគ្នាក្នុងការទទួលបានការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈគ្រប់កម្រិតសម្រាប់មនុស្សពេញវ័យដែលងាយរងគ្រោះ ដោយរាប់បញ្ចូលទាំងក្រុមគោលដៅដែលមានពិការភាព និងជនជាតិភាគតិច និងកុមារដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះ[8]
។

### ខ. ការប្តេជ្ញាចិត្តរបស់កម្ពុជាដើម្បីសមភាពយេនឌ័រក្នុងវិស័យអប់រំ

នៅក្នុងផ្នែកនេះ យើងបានដកស្រង់ច្បាប់ គោលនយោបាយ បទបញ្ញត្តិ និងគោលការណ៍នានាដែលរាជរដ្ឋាភិបាលបានរៀបចំចងក្រង និងផ្តល់សច្ចាប័ន សម្រាប់ឱ្យអ្នកពាក់ព័ន្ធយកទៅអនុវត្តក្នុងទិសដៅលើកកម្ពស់សមភាពយេនឌ័រ និងការពារកុមារពីគ្រប់ទម្រង់នៃការរំលោភបំពាន។ ការដកស្រង់នេះសង្ខេបខ្លឹមសារដែលទាក់ទងនឹងយេនឌ័រ។ ប្រសិនបើអ្នកមានបំណងចង់ស្វែងយល់ខ្លឹមសារលម្អិត សូមមេត្តាអានឯកសារទាំងនោះ។

| ចំណងជើងអត្ថបទ | ឆ្នាំ | ខ្លឹមសារលម្អិតពាក់ព័ន្ធនឹងយេនឌ័រ |
|---|---|---|
| **រដ្ឋធម្មនុញ្ញ** | ២០១៤ | • ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាពចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ វប្បធម៌ សង្គមកិច្ច និងសេដ្ឋកិច្ច។ (មាត្រា ៣៥)<br>• ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរសមស្រប ទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា។ (មាត្រា៣៦)<br>• ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រីភេទ ត្រូវបំបាត់ចោល។(មាត្រា៤៥) |

[7] UN Women. *Convention on the Elimination of All Forms of Discrimination against Women*. Retrieved from http://www.un.org/womenwatch/daw/cedaw/
[8] UN. *Sustainable Development Goals*. Retrieved from https://sustainabledevelopment.un.org/sdgs

| ចំណងជើងអត្ថបទ | ឆ្នាំ | ខ្លឹមសារលម្អិតពាក់ព័ន្ធនឹងយេនឌ័រ |
|---|---|---|
| | | • មាតាបិតា មានកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនប្រុស កូនស្រីឱ្យទៅជាពលរដ្ឋល្អ។ កូនប្រុសកូនស្រីមានករណីយកិច្ចចិញ្ចឹម និងបីបាច់ថែរក្សាមាតាបិតាដែលចាស់ជរា តាមទំនៀមទម្លាប់ខ្មែរ។ (មាត្រា៤៧) |
| ព្រះរាជក្រឹត្យស្ដីពីការកែសម្រួលអាយុចូលនិវត្តន៍របស់មន្ត្រីរាជការស៊ីវិលជាស្ត្រី | ២០១២ | ក្នុងការពន្យារអាយុនៃការចូលនិវត្តន៍តាមការស្ម័គ្រចិត្តដល់ស្ត្រីជាមន្ត្រីរាជការដល់អាយុ ៦០ឆ្នាំ។ |
| ច្បាប់ស្រី | សតវត្សទី ១៩ | អ្នកប្រវត្តិវិទូជាច្រើនចាត់ទុកថាច្បាប់ស្រីមានឥទ្ធិពលយ៉ាងខ្លាំងលើសមភាពយេនឌ័រនៅកម្ពុជា។ ស្ត្រីត្រូវបានគេចាត់ទុកជាមនុស្សម្នាក់ដែលមានមុខមាត់កិត្តិយសសម្រាប់រូបនាងផ្ទាល់ គ្រួសារ និងសហគមន៍ ប្រសិនជាអាកប្បកិរិយារបស់នាងសមស្រប។ |
| ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ | ១៩៨៩ | បង្ហាញពីសិទ្ធិស្មើគ្នារវាងសហព័ទ្ធទាំងពីរក្នុងការប្រើប្រាស់ ការអាស្រ័យផល ការចាត់ចែងទ្រព្យសម្បត្តិរួម ដែលសហព័ទ្ធទាំងពីររកបានជាមួយគ្នា ឬសហព័ទ្ធណាម្នាក់រកបានក្នុងរយៈពេលមានចំណងអាពាហ៍ពិពាហ៍។ |
| ច្បាប់នៃការរំលូត កូនប្រុសកូនស្រី | ១៩៩៧ | ធានាសិទ្ធិស្ត្រីក្នុងការរំលូតកូនប្រុស កូនស្រីតាមរយៈនីតិវិធី និងលក្ខខណ្ឌជាក់លាក់ដើម្បីផ្តល់ការថែទាំសុខភាពដល់ស្ត្រី។ |
| ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សា ក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ | ២០០៥ | កាលពីឆ្នាំ២០០៥ បានបង្កើតយន្តការអន្តរាគមន៍ និងការពារពីអាជ្ញាធរមូលដ្ឋានតាមរយៈបទបញ្ញត្តិដែលធ្វើឡើងដោយតុលាការខេត្ត។ |
| ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជ ធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | ២០០៨ | កំណត់អំពីការធានាឱ្យមានតំណាងស្ត្រីនៅក្នុងគណៈកម្មាធិការនានា រួមទាំងតួនាទីប្រធាន និងអនុប្រធាន។ ត្រូវធានាឱ្យមានចំនួនស្ត្រីសមស្របនៅក្នុងមុខតំណែងប្រធាន ឬអនុប្រធានអង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា។ |
| ច្បាប់ស្តីពីការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | ២០១៥ | កំណត់អំពីការធានាឱ្យមានបេក្ខជនស្ត្រីចូលរួម និងមានឈ្មោះនៅលំដាប់លេខរៀងសមស្រប ក្នុងបញ្ជីបេក្ខជន។ |
| ច្បាប់ស្តីពីការអប់រំ | ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ | ជំពូកទី១ បានចែងពីគុណតម្លៃស្មើគ្នាក៏ដូចជាសិទ្ធិរបស់ជនគ្រប់រូបក្នុងការអប់រំមិនថាសិស្សប្រុស ឬសិស្សស្រីទេ និងមាត្រា៣៦ បានបង្ហាញពីសិទ្ធិ និងករណីកិច្ចរបស់មាតាបិតា ឬអ្នកអាណាព្យាបាល ក្នុងការនាំកុមារទៅចុះឈ្មោះចូលសិក្សា ខិតខំគាំទ្រយកចិត្តទុកដាក់ផ្សារភ្ជាប់សាលា គ្រួសារ និងសហគមន៍ ដើម្បីឱ្យកូនប្រុសកូនស្រីខ្លួនទទួលបានការអប់រំ។ |
| យុទ្ធសាស្ត្រចតុកោណ | ដំណាក់កាលទី៣ | “រាជរដ្ឋាភិបាលបន្តលើកស្ទួយស្ថានភាពស្ត្រីដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ” |

| ចំណងជើងអត្ថបទ | ឆ្នាំ | ខ្លឹមសារលម្អិតពាក់ព័ន្ធនឹងយេនឌ័រ |
|---|---|---|
| | ឆ្នាំ២០១៣ | |
| **ផែនការសកម្មភាពអភិបាលកិច្ច** | ២០០១ | ផែនការនេះដាក់បញ្ចូលសមធមិយេនឌ័រ ដែលជាចំណុចមួយក្នុងចំណោមចំណុចរួមទាំងប្រាំដោយមានការចូលរួមដោយក្រសួងកិច្ចការនារី ដៃគូអភិវឌ្ឍន៍ និងម្ចាស់ជំនួយនានា។ |
| **អនុក្រឹតស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន** | ២០០៨ | គ្រូបង្រៀនមិនត្រូវដាក់ទណ្ឌកម្មខាងផ្លូវកាយ និងផ្លូវចិត្តដែលនាំឱ្យមានផលប៉ះពាល់ដល់អ្នកសិក្សាទេ។ (មាត្រា ១២)[9] |
| **សេចក្តីណែនាំក្រសួងមហាផ្ទៃ** | ២០០៦ | កំណត់ជ្រើសរើសថ្នាក់ដឹកនាំភូមិជាស្ត្រីយ៉ាងតិច ១រូប ក្នុងចំណោម ៣រូប។ |
| **សេចក្តីណែនាំរបស់ក្រសួងមុខងារសាធារណៈ** | | ក្នុងការជ្រើសរើសមន្ត្រីថ្មីជានារីក្នុងចំនួនពី២០% ទៅ ៥០%។ |
| **អនុសាសន៍របស់ប្រមុខរាជរដ្ឋាភិបាល** | ២០១៣ | ក្រសួងស្ថាប័នបន្តតែងតាំងស្ត្រី មានឋានៈ តួនាទីនៅក្នុងកម្រិតអគ្គនាយក ប្រធាននាយកដ្ឋាន ឬតួនាទីសមមូលនឹងតួនាទីទាំងពីរនេះ ដោយរាប់បញ្ចូលទាំងអង្គភាពនគរបាលផងដែរ។ ក្រសួងមហាផ្ទៃជំរុញ និងកំណត់ក្នុងការតែងតាំងស្ត្រី ជាអភិបាលរងនៅក្នុងគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ គ្រប់ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់ ក្រសួង ស្ថាប័ន កំណត់ការបង្កើនចំនួនស្ត្រីជាមន្ត្រីរាជការក្នុងតួនាទីធ្វើសេចក្តីសម្រេច។ រាជរដ្ឋាភិបាល តែងតាំងស្ត្រីជារដ្ឋលេខាធិការ និងជាអនុរដ្ឋលេខាធិការនៅគ្រប់ក្រសួង ស្ថាប័ន។ |
| **នារីរតនៈទី៤** | ផែនការយុទ្ធសាស្ត្រ ៥ឆ្នាំ ២០១៤-២០១៨ | "សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី" ដែលដឹកនាំនិងសម្របសម្រួលក្នុងការអនុវត្តន៍ ដោយយន្តការជាតិក្នុងការបញ្ជ្រាបយេនឌ័រ ដូចជាក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្រសួងកិច្ចការនារី និងក្រុមការងារយេនឌ័ររបស់ក្រសួង ស្ថាប័ន។ សេចក្តីណែនាំរបស់ក្រសួងមុខងារ សាធារណៈ បានកំណត់ឱ្យជ្រើសរើសស្ត្រីពី ២០% ទៅ ៥០% ឱ្យចូលបំរើការក្នុងក្រសួងស្ថាប័នសាធារណៈ។ សេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃឱ្យមានការជ្រើសតាំងថ្នាក់ ដឹកនាំភូមិជាស្ត្រី និងតែងតាំងអភិបាលរងជាស្ត្រីទូទាំងប្រទេស។ |
| **ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី** | ២០១៤-២០១៨ | ផែនការសកម្មភាពជាតិ ក្នុងការអនុវត្តច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ព្រមទាំងច្បាប់ និងគោលនយោបាយនានា។ មានយុទ្ធសាស្ត្រ សំខាន់ៗ ៥គឺ:<br>- ការទប់ស្កាត់បឋម<br>- ការការពារផ្នែកច្បាប់ និងសេវាកម្មពហុវិស័យ<br>- ការកសាង និងការអនុវត្តគោលនយោបាយ និងច្បាប់ |

[9] កម្មវិធីសាលាកុមារមេត្រី សមាសភាគទី៣៖ សុខភាព សុវត្ថិភាព និងការការពារកុមារ ការទប់ស្កាត់អំពើហិង្សាលើកុមារ ឆ្នាំ២០១៦ (ទំព័រទី១៣)

| ចំណងជើងអត្ថបទ | ឆ្នាំ | ខ្លឹមសារលម្អិតពាក់ព័ន្ធនឹងយេនឌ័រ |
| --- | --- | --- |
| | | - ការកសាងសមត្ថភាព<br>- ការពិនិត្យ ការតាមដាន និងការវាយតម្លៃ |
| យុទ្ធសាស្ត្រស្តីពីការចិញ្ចឹមកូនប្រុសកូនស្រីបែបវិជ្ជមាន | ២០១៧-២០២១ | **ក្រសួងកិច្ចការនារី៖** បានបង្ហាញពីគោលនយោបាយ និងកម្មវិធីរបស់រាជរដ្ឋាភិបាល ក្នុងការទទួលស្គាល់តួនាទីដ៏សំខាន់របស់មាតាបិតា អ្នកអាណាព្យាបាល ឬអ្នកថែទាំក្នុងការលើកកម្ពស់ការលូតលាស់ និងអភិវឌ្ឍរបស់កុមារ[10]។ |
| គោលការណ៍ ណែនាំអនុវត្តលក្ខខណ្ឌអប្បបរមា | ២០១៦ | ស្តីពីទឹកស្អាត និងអនាម័យតាមសាលារៀន "កំណត់ពិន្ទុផ្កាយនៃការប៉ាន់ប្រមាណពីការប្រើប្រាស់ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្សេងគ្នារវាងសិស្សស្រីនិងសិស្សប្រុស" |
| សេចក្តីប្រកាសទីក្រុង Incheon និងក្របខណ្ឌសម្រាប់សកម្មភាពឆ្ពោះទៅរកការអប់រំមានគុណភាព បរិយាប័ន្ន សមធម៌ និងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា | ២០១៥ | យោងតាមសេចក្តីថ្លែងការណ៍៖ "កុមារទាំងអស់ទទួលបាននូវការអប់រំប្រកបដោយគុណភាព និងការសិក្សាពេញមួយជីវិតរបស់គេដោយគ្មានការរើសអើង"។ |
| សន្និសីទពិភពលោកលើកទី៤ស្តីពីស្ត្រី (ទីក្រុងប៉េកាំង) | ១៩៩៥ | ប្រទេសកម្ពុជាបានជ្រើសរើសចំណុចអាទិភាពមួយចំនួនសម្រាប់អនុវត្តសកម្មភាព និងបានខិតខំប្រឹងប្រែងអស់ពីលទ្ធភាពដែលរួមមាន៖<br>- ស្ត្រីនិងការអប់រំ<br>- ស្ត្រីនិងសុខភាព<br>- ស្ត្រីនិងសេដ្ឋកិច្ច<br>- ស្ត្រីនិងការការពារផ្លូវច្បាប់ និង<br>- ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត។<br>ប្រទេសកម្ពុជាមានកាតព្វកិច្ចអនុវត្តវេទិកាសកម្មភាពទីក្រុងប៉េកាំង និងរាយការណ៍រៀងរាល់ ៥ឆ្នាំម្តង។ |
| ផែនការសកម្មភាពស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ | ២០១៦ | យុទ្ធសាស្ត្រទី៥៖ លើកកម្ពស់តម្លៃ សេចក្តីថ្លៃថ្នូរ និងក្រមសីលធម៌វិជ្ជាជីវៈរបស់បុគ្គលិកអប់រំ "មិនរើសអើង (ជានារី) ក្នុងការចូលបម្រើការងារជាបុគ្គលិកអប់រំ និងទទួល បានអាហាររូបករណ៍" |
| គោលនយោបាយ ស្តីពី "ការលើកកម្ពស់បរិយាប័ន្ន និងសម | | ដើម្បីធានានូវសមធម៌ និងឆ្លើយតបនឹងសមភាពយេនឌ័រក្នុងវិស័យអប់រំ ក្រសួងអប់រំ យុវជន និងកីឡា បានផ្តោតការយកចិត្តទុកដាក់លើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គមទាំងក្នុងការអភិវឌ្ឍន៍សមត្ថភាព ដល់រដ្ឋបាល |

[10] យុទ្ធសាស្ត្រស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន ក្រសួងកិច្ចការនារី ២០១៧-២០២១ (ទំព័រទី១២)

| ចំណងជើងអត្ថបទ | ឆ្នាំ | ខ្លឹមសារលម្អិតពាក់ព័ន្ធនឹងយេនឌ័រ |
| --- | --- | --- |
| ធម៌សង្គម” | | ថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសិក្សាក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្ត មុខងារ និងធានធានដែលបានផ្ទេរ។ |
| ផែនការគោលសម្រាប់ការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ ២០១៥-២០១៩ | ២០១៥ | យុទ្ធសាស្រ្តទី៨៖ “ការបញ្ជ្រាបយេនឌ័រ” នៅពេលស្រ្តី បានក្លាយទៅជាផ្នែកដ៏សំខាន់ក្នុងយុទ្ធសាស្ត្រអប់រំយេនឌ័រត្រូវបានចាត់ទុកថាជាបញ្ហាអន្តរវិស័យ។ |
| គោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា | ២០១៥ | យុទ្ធសាស្រ្ត៥.៣ “លើកកម្ពស់សមភាពយេនឌ័រ”<br>○ ជំរុញ និងលើកទឹកចិត្តស្រ្តីឱ្យចូលរួមសកម្មភាពកីឡា<br>○ ផ្តល់កាលានុវត្តភាពដល់ស្រ្តីដើម្បីឱ្យស្រ្តីក្លាយជាកីឡាករឆ្នើមតំណាងជាតិ<br>○ បង្កើនសមាមាត្រស្រ្តីចូលរួមដឹកនាំក្នុងវិស័យកីឡា និងអភិវឌ្ឍស្រ្តីឱ្យក្លាយជាគ្រូបង្វឹក អាជ្ញាកណ្តាល ចៅក្រមនិងជំនាញផ្សេងៗទៀត |
| គោលនយោបាយស្តីពីកម្មវិធីសមមូលអប់រំក្រៅប្រព័ន្ធ | ២០០៨ | លក្ខខណ្ឌនៃការចូលរៀនរបស់សិស្ស៖ “ដោយកំណត់សិស្សទាំងពីរភេទមានសិទ្ធិចុះឈ្មោះចូលរៀនដូចគ្នា”។ |
| គោលនយោបាយ ស្តីពីការអប់រំបច្ចេកទេស | ២០១៣ | យុទ្ធសាស្រ្តទី៥.៧៖ “លើកកម្ពស់សមភាពយេនឌ័រក្នុងការអប់រំបច្ចេកទេស” |
| ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ ២០១៦-២០២០ | | - យុទ្ធសាស្ត្រទី១៖ ការស្រាវជ្រាវ ការផ្សព្វផ្សាយព័ត៌មាន និងការលើកកម្ពស់ការយល់ដឹងអំពីយេនឌ័រ<br>- យុទ្ធសាស្ត្រទី២៖ ការបញ្ចុះបញ្ចូល និងស្វែងរកការគាំទ្រ<br>- យុទ្ធសាស្ត្រទី៣៖ ការអភិវឌ្ឍសមត្ថភាព<br>- យុទ្ធសាស្ត្រទី៤៖ ការបញ្ជ្រាបយេនឌ័រក្នុងដំណើរការបង្រៀន និងរៀន<br>- យុទ្ធសាស្ត្រទី៥៖ ការលើកកម្ពស់សកម្មភាពឆ្លើយតបនឹងយេនឌ័រ និងការពិនិត្យតាមដាន<br>- យុទ្ធសាស្ត្រទី៦៖ ការបង្កើនភាពជាដៃគូ |
| គោលនយោបាយកិច្ចការពារកុមារ UNICEF ឆ្នាំ២០១៦-២០១៨ | | ដៃគូសំខាន់ៗក្នុងកិច្ចការពារកុមារ អ្នកផ្តល់ជំនួយ ដៃគូអភិវឌ្ឍន៍ និងការងារដែលត្រូវធ្វើមាន៖<br>- កិច្ចការពារកុមារពីអំពើហិង្សា<br>- ការថែរក្សាកុមារនៅជួបជុំគ្រួសារ<br>- ពង្រឹងកិច្ចការពារកុមារ និងសេវាសង្គមទូទៅ<br>- ផ្តល់សិទ្ធិអំណាចដល់សហគមន៍ដើម្បីការពារកុមារ<br>- សកម្មភាពសម្រាប់ក្មេងជំទង់ |

| ចំណងជើងអត្ថបទ | ឆ្នាំ | ខ្លឹមសារលម្អិតពាក់ព័ន្ធនឹងយេនឌ័រ |
|---|---|---|
| **កម្មវិធីសាលាកុមារមេត្រី** | ២០០៤ | សមាសភាគទី៤៖ ការឆ្លើយតបទៅនឹងយេនឌ័រ មានគោលបំណងកសាងឥរិយាបថសង្គមវិជ្ជមានចំពោះការ អប់រំកុមារី យកចិត្តទុកដាក់លើបញ្ហាយេនឌ័រ រៀបចំឱ្យមានទីប្រឹក្សាកុមារីនៅតាមសាលារៀន និងបញ្ជ្រាបទៅក្នុងសមាសភាគផ្សេងទៀតនៃកម្មវិធីសាលាកុមារមេត្រី ដើម្បីឱ្យមានសមធម៌ និងសមភាពយេនឌ័រនៅក្នុងវិស័យអប់រំ។ |
| **គោលដៅអប់រំសម្រាប់ទាំងអស់គ្នាទាំង៦** | | គោលដៅទី២ គោលដៅទី៤ និង គោលដៅទី៥ សំដៅលើការលើកកម្ពស់ការយល់ដឹងអំពីសមភាព សមធម៌ និងគុណភាពយេនឌ័រ[11] ដល់កុមារ យុវជន មនុស្សពេញវ័យដែលបានបញ្ចប់យ៉ាងតិចដល់កម្រិតអប់រំមូលដ្ឋាន ជាពិសេសកុមារី និងស្ត្រី។ |

## IV. សកម្មភាព

សកម្មភាព៖ ស្វែងយល់ពីក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងយេនឌ័រ

បន្ទាប់ពីបានអានអំពីក្របខណ្ឌគោលនយោបាយថ្នាក់ជាតិ និងអន្តរជាតិពាក់ព័ន្ធនឹងយេនឌ័ររួច សូមគិតអំពីសំណួរខាងក្រោម៖

តើអ្នកគិតថាអ្វីជាអត្ថប្រយោជន៍នៃការបញ្ចូលយេនឌ័រនៅក្នុងក្របខណ្ឌគោលនយោបាយជាតិ និងអន្តរជាតិ?

## V. សន្និដ្ឋាន

ការអប់រំគឺជាមធ្យោបាយដ៏មានឥទ្ធិពលក្នុងការផ្លាស់ប្តូរការយល់ឃើញ និងការរំពឹងទុកមិនសមហេតុផលពាក់ព័ន្ធនឹងយេនឌ័រដែលពិបាកផ្លាស់ប្តូរតាមរយៈការបណ្តុះបញ្ញា ស្មារតី និងបំណិនសម្រាប់កុមារដើម្បីឱ្យមានការរីកចម្រើនសមភាពយេនឌ័រ និងរួមចំណែកក្នុងការអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ក្នុងមេរៀននេះ បានរំលេចនូវទិដ្ឋភាពទូទៅនៃការប្តេជ្ញាចិត្តរបស់ស្ថាប័នជាតិ និងអន្តរជាតិចំពោះសមភាពយេនឌ័រក្នុងវិស័យអប់រំ។ សៀវភៅណែនាំនេះ នឹងត្រួសត្រាយផ្លូវដើម្បីឈានឆ្ពោះទៅរកបរិស្ថានសិក្សាដែលឆ្លើយតបនឹងសមភាពយេនឌ័រ ប្រមូលផ្តុំគំនិត យុទ្ធសាស្ត្រ និងឧបករណ៍សម្រាប់គ្រូ គណៈគ្រប់គ្រងសាលារៀន និងសមាជិកគណៈកម្មការគ្រប់គ្រងសាលារៀនផងដែរ។

[11] បុព្វកថា ឯកឧត្តម **ណាត ប៊ុនរឿន** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ក្នុងសៀវភៅកម្មវិធីសាលាកុមារមេត្រី សមាសភាគទី៤

# មេរៀនទី៣

# ផ្នត់គំនិតយេនឌ័រក្នុងវិស័យអប់រំ

## I. សេចក្តីផ្តើម

ផ្នត់គំនិតយេនឌ័រមានបង្ហាញនៅក្នុងឯកសារច្បាប់ស្រី (ក្រមសីលធម៌សម្រាប់ស្ត្រី) និងច្បាប់ប្រុស (ក្រមសីលធម៌សម្រាប់បុរស) ជាឯកសារកំណាព្យដែលមានដើមកំណើតតាំងពីសតវត្សរ៍ទី១៦មកម្ល៉េះ។ កំណាព្យនេះរៀបរាប់អំពីអាកប្បកិរិយាដែលក្មេងស្រី និងក្មេងប្រុស ស្ត្រី និងបុរសគួរប្រតិបត្តិ។ អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺច្បាប់ស្រីទូន្មានឱ្យក្មេងស្រីស្តាប់បង្គាប់ស្វាមី និងញ៉ាំងឱ្យស្ត្រីងាយធ្លាក់ក្នុងស្ថានភាពរងគ្រោះដោយសារអំពើហិង្សា។ កំណាព្យទាំងពីរនេះធ្លាប់ត្រូវបានសិក្សា និងទន្ទេញរត់មាត់នៅសាលារៀន។

ចាប់តាំងពីឆ្នាំ២០០៧មក សិស្សានុសិស្សកម្ពុជាសិក្សាតែមួយផ្នែកតូចនៃកំណាព្យទាំងនេះប៉ុណ្ណោះ ជាការខិតខំប្រឹងប្រែងមួយដើម្បីបញ្ចូលសមភាពយេនឌ័រក្នុងកម្មវិធីសិក្សា ប៉ុន្តែកំណាព្យទាំងពីរនេះនៅតែមានឥទ្ធិពលដដែល។ កាលពីឆ្នាំ១៩៩៧ មានការកែលម្អខ្លឹមសារសៀវភៅសិក្សាដើម្បីឱ្យមានភាពឆ្លើយតបនឹងគោលគំនិតនៃសមភាពយេនឌ័រ៖ សៀវភៅសិក្សានាពេលនេះមានខ្លឹមសារអត្ថបទ និងរូបភាពដែលបង្ហាញចំនួនស្មើគ្នារវាងភេទប្រុស និងភេទស្រី ទោះបីជាក្មេងស្រី និងស្ត្រីនៅតែត្រូវគេបង្ហាញក្នុងតួនាទីប្រពៃណីដូចជាមេផ្ទះ និងមិនមែនជាអ្នកវិទ្យាសាស្ត្រ វេជ្ជបណ្ឌិត ឬអ្នកគណិតវិទូរក៏ដោយ។

ក្នុងមេរៀននេះ នឹងបង្ហាញពីវត្តមាន និងផលប៉ះពាល់នៃផ្នត់គំនិតយេនឌ័រក្នុងវិស័យអប់រំ។ នៅចុងបញ្ចប់នៃមេរៀននេះ នឹងមានលើកឡើងអំពីគំនិតដើម្បីកសាងចំណេះដឹង បំណិន និងឥរិយាបទ ដើម្បីចៀសវាងនូវភាពលម្អៀងយេនឌ័រ ក្នុងការអប់រំមនុស្សជំនាន់ក្រោយ។

## II. វត្ថុបំណង

- កំណត់បានពីផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមាននៃផ្នត់គំនិតយេនឌ័រ នៅក្នុងការអប់រំ
- វិភាគផ្នត់គំនិតយេនឌ័រ ក្នុងការបង្រៀន និងរៀន
- លើកកម្ពស់សមភាព និងការឆ្លើយតបយេនឌ័រ ក្នុងការបង្រៀន និងរៀន ដើម្បីធានានូវឱកាសស្មើគ្នារវាងសិស្សស្រី និងសិស្សប្រុស។

## III. ខ្លឹមសារ

### ១.ផ្នត់គំនិតយេនឌ័រ

ផ្នត់គំនិតយេនឌ័រគឺជាបណ្តុំនៃជំនឿដែលកើតឡើងអំពីកត្តាផ្ទាល់ខ្លួន អាកប្បកិរិយា និងតួនាទីនៃក្រុមមនុស្សជាក់លាក់មួយក្នុងសង្គមដោយផ្អែកទៅលើភេទ។ ជានិច្ចកាល ជំនឿទាំងនេះ នាំឱ្យកើតមានទស្សនៈលម្អៀងចំពោះស្ត្រី និងបុរសដែលត្រូវបានប្រើម្តងហើយម្តងទៀតក្នុងជីវភាពប្រចាំថ្ងៃ។

និយមន័យខាងលើស្របគ្នានឹងនិយមន័យដែលត្រូវបានប្រើដោយក្រសួងអប់រំ យុវជន និងកីឡា ដែលបានលើកឡើងថា៖ "ផ្នត់គំនិតយេនឌ័រគឺជាគំនិតដែលមនុស្សរស់នៅក្នុងសង្គមបានឱ្យតម្លៃលើបុរស និងស្ត្រីថាត្រូវមានអាកប្បកិរិយាបែបនេះ ឬបែបនោះ ថាមានតួនាទីបែបនេះ ឬបែបនោះថាមានសមត្ថភាពអាចធ្វើនេះ ឬធ្វើនោះ"។

ឧទាហរណ៍៖

- ជំនឿមួយដែលជឿថាស្ត្រីគួរមើលថែទាំកូន ខណៈដែលបុរសត្រូវធ្វើការរកប្រាក់មកផ្គត់ផ្គង់ចិញ្ចឹមគ្រួសារ
- ជំនឿមួយដែលជឿថាបុរសអាចដើរលេងពេលយប់បានតែស្ត្រីមិនគួរដើរលេងយប់ទេ
- ជំនឿមួយដែលជឿថាការធ្វើសេចក្តីសម្រេចចិត្តគឺជាតួនាទីរបស់បុរស ស្ត្រីគ្រាន់តែជាអ្នកគាំទ្រប៉ុណ្ណោះ។

### សកម្មភាព ក៖ កិច្ចពិភាក្សាអំពីផ្នត់គំនិតយេនឌ័រ

ប្រយោគខាងក្រោមនេះ ជាផ្នត់គំនិតយេនឌ័រមួយចំនួនដែលតែងកើតមានជាញឹកញាប់នៅក្នុងប្រទេសកម្ពុជា។ សូមអានប្រយោគខាងក្រោម ហើយពិចារណាថាតើប្រយោគនោះជាផ្នត់គំនិតយេនឌ័រដែរឬទេ? បើជាផ្នត់គំនិតយេនឌ័រ តើជាផ្នត់គំនិតយេនឌ័របែបវិជ្ជមាន ឬអវិជ្ជមាន? ហេតុអ្វី?

| ល.រ | ខ្លឹមសារ |
|---|---|
| ១ | នំមិនធំជាងនាឡិ |
| ២ | កុំយកស្រីធ្វើជាគ្រូ កុំយកទ្រូធ្វើជាលប |
| ៣ | សំណាបយោងដី ស្ត្រីយោងបុរស |
| ៤ | បុរសអាចធ្វើជាអ្នកបើកយន្តហោះ ស្ត្រីក៏អាចធ្វើជាអ្នកបើកយន្តហោះបានដែរ |
| ៥ | កុមារទាំងអស់អាចរៀន លើមុខវិជ្ជា វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) |
| ៦ | មេម៉ាយចំណាយមាត់គេ ក្រមុំទំនេរប្តីម៉ាស្រុក |
| ៧ | គ្មានមុខវិជ្ជាណាមួយដែលកុមារី និងកុមារារៀនមិនបាននោះទេ! |
| ៨ | ស្ត្រីបង្វិលចង្ក្រានមិនជុំ |
| ៩ | ស្ត្រីមុជមិនជ្រៅ ទៅមិនឆ្ងាយ |
| ១០ | កូនស្រីមិនត្រូវរៀនឱ្យបានខ្ពស់ទេ |

| | |
|---|---|
| ១១ | សម្លុតឆ្ងាញ់ដោយសារគ្រឿង គ្រួសាររុងរឿងដោយសារភរិយា និងស្វាមី។ |
| ១២ | កិច្ចការផ្ទះជាកម្មសិទ្ធិផ្តាច់មុខរបស់ស្ត្រី |
| ១៣ | ការធ្វើសេចក្តីសម្រេចចិត្តគឺជាតួនាទីរបស់បុរស ។ |

**២.តើហេតុអ្វីបានជាផ្នត់គំនិតយេនឌ័រពិបាកនឹងផ្លាស់ប្តូរ?**

ផ្នត់គំនិតយេនឌ័រពិបាកផ្លាស់ប្តូរដោយសារត្រូវបានផ្ទេរពីមួយជំនាន់ទៅមួយជំនាន់តាមរយៈលំនាំនៃទំនាក់ទំនងក្នុងសង្គម។

**ទំនាក់ទំនងសង្គម**គឺជាលំនាំដែលមនុស្សរៀនសូត្រឱ្យក្លាយជាផ្នែកមួយនៃសង្គម។ លំនាំនេះពណ៌នាអំពីវិធីដែលមនុស្សស្វែងយល់អំពីបទដ្ឋាន និងការរំពឹងទុករបស់សង្គម វិធីដែលពួកគេទទួលយកជំនឿរបស់សង្គម និងយល់ដឹងពីគុណតម្លៃរបស់សង្គម[12]។

អាណាព្យាបាល ឬអ្នកមើលថែទាំក្មេងគឺជាភ្នាក់ងារបឋមនៃទំនាក់ទំនងសង្គម ដោយសារនៅក្នុងបរិបទភាគច្រើន កុមារចំណាយពេលច្រើននៅជាមួយមនុស្សដែលមើលថែពួកគេ។ នៅមិនឆ្ងាយពីបរិស្ថានគ្រួសារ បរិស្ថានសាលារៀនជាបរិស្ថានដ៏សំខាន់មួយនៃទំនាក់ទំនងសង្គម។ នៅក្នុងរូបភាពខាងក្រោម អ្នកនឹងសង្កេតមើលស្រទាប់មួយចំនួនដែលកើតមាននៅក្នុងបរិស្ថានសាលារៀន[13]៖




**រូបភាពទី១៖ ដំណើរការទំនាក់ទំនងសង្គម**

[12] Little, W. (2014). Introduction to Sociology – 1st Canadian Edition. (W. Little, Ed.) (1st ed.). Retrieved from https://opentextbc.ca/introductiontosociology/

[13] Cabus, S., Sok, S., Rutkowska, K., Van Horen, K., & Nicaise, I. (2019). The role of gender-responsive pedagogy to tackle violence against and between children in Cambodian schools. Retrieved from https://cambodia.vvob.org/sites/cambodja/files/the_role_of_genderresponsive_pedagogy_to_0.pdf

កុមារា កុមារីស្ថិតនៅក្នុងចំណុចស្នូលនៃទំនាក់ទំនងនេះ។ ពួកគេមានទំនាក់ទំនងដោយផ្ទាល់ជាមួយគ្រូ និងគណៈគ្រប់គ្រងសាលារៀន។ ដោយប្រយោល ពួកគេចាប់ផ្តើមរងឥទ្ធិពលនៃបទដ្ឋាន និងការរំពឹងទុកតាមរយៈ គោលនយោបាយ និងគោលការណ៍របស់សាលារៀន។ គោលការណ៍ទាំងនោះត្រូវបានកំណត់ដោយ បទដ្ឋាន និងគុណតម្លៃរបស់សង្គម។ សាលារៀនជាកញ្ចក់សម្រាប់ឆ្លុះបញ្ចាំងអំពីសង្គម

ការអនុវត្តពាក់ព័ន្ធនឹងយេនឌ័រ និងរឿងដែលត្រូវបានហាមប្រាម កើតមាននៅក្នុងសង្គមអាស្រ័យលើបទដ្ឋាន និងគុណតម្លៃរបស់សង្គម។ ឧទាហរណ៍ ប្រសិនបើការទាត់ធាក់ ឬវាយដំរាងកាយកុមារដែលមានអាកប្បកិរិយាមិនសមរម្យ ត្រូវបានសង្គមទទួលយក នោះគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀនកាន់តែពិបាកក្នុងការអនុវត្តវិន័យបែបវិជ្ជមាន។

គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀនជាតួអង្គសំខាន់ក្នុងការផ្លាស់ប្តូរការអនុវត្ត ឥរិយាបទ និងគុណតម្លៃ។ គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀនជួយឱ្យសិស្សយល់ដឹង និងអនុវត្តសមភាពយេនឌ័រ និងអាកប្បកិរិយាអហិង្សា និងលើកទឹកចិត្តកុមារឱ្យទទួលយកភាពមិនដូចគ្នា។ ហេតុអ្វីបានជាត្រូវការគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀនជាតួអង្គសំខាន់ដែលត្រូវដើរតួនាទីនេះ? កត្តាចម្បងបំផុតនោះគឺ ពួកគាត់នៅជិតកុមារបំផុត ហើយអាចបង្កើតទំនាក់ទំនងក្នុងនាមជាអ្នកមើលថែកុមារបាន។ លើសពីនេះទៅទៀត គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀនប្រែក្លាយគោលនយោបាយ និងគោលការណ៍សាលារៀន ដែលអាចឆ្លើយតបនឹងសមភាពយេនឌ័រ ទៅជាការអនុវត្តជាក់ស្តែងក្នុងសាលារៀនថ្នាក់រៀន ព្រមទាំងការបង្រៀន និងរៀនផងដែរ។

### ៣.តើគួរផ្លាស់ប្តូរផ្នត់គំនិតយេនឌ័រដោយរបៀបណា?

មុនពេលដែលលោកគ្រូ អ្នកគ្រូប្រើប្រាស់សក្តានុពលរបស់ខ្លួន និងប្រែក្លាយទៅជាភ្នាក់ងារសម្រាប់ការផ្លាស់ប្តូរ ដែលអាចកែប្រែដោយជោគជ័យនូវផ្នត់គំនិតយេនឌ័របាន គាត់ចាំបាច់ត្រូវយល់ដឹងអំពីប្រព័ន្ធជំនឿ និងការយល់ឃើញលម្អៀងអំពីយេនឌ័ររបស់គាត់ខ្លួនឯង និងដោះស្រាយជំនឿទាំងនេះជាមុនសិន។ បន្ទាប់មក គាត់អាចផ្លាស់ប្តូរការអនុវត្តជំនឿទាំងនេះនៅក្នុងថ្នាក់រៀនរបស់គាត់បាន។ នៅក្នុងសៀវភៅណែនាំសម្រាប់គ្រូ យើងពិភាក្សាអំពីវិធីដែលគ្រូអាចប្រែក្លាយថ្នាក់រៀនរបស់គាត់ទៅជាបរិស្ថានសិក្សាដែលឆ្លើយតបនឹងយេនឌ័រ។

ប៉ុន្តែដោយសារជំនឿទាំងនេះបានចាក់ឫសយ៉ាងជ្រៅនៅក្នុងផ្នត់គំនិតរបស់គ្រូ ពួកគាត់ក៏មានទំនោរប្រឆាំងនឹងការផ្លាស់ប្តូរដែរ។ ដើម្បីឱ្យគ្រូអាចផ្លាស់ប្តូរជំនឿរបស់គាត់បាន ទាមទារឱ្យមានលក្ខខណ្ឌសមប្រកបដែលជួយឱ្យគ្រូទទួលបានការយល់ដឹង និងឆ្លុះបញ្ចាំងពីជំនឿដែលពួកគាត់កំពុងតែមានជាមុនសិន។ ប្រការនេះអាចកើតឡើងបានអាស្រ័យលើការគាំទ្ររបស់គណៈគ្រប់គ្រងសាលារៀន។

ដោយមូលហេតុនេះហើយ ទើបគណៈគ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងសាលារៀនក៏ត្រូវដឹងពីផ្នត់គំនិត និងជំនឿផ្ទាល់ខ្លួនរបស់ពួកគាត់ផងដែរ។ លុះត្រាតែគណៈគ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងសាលារៀនដឹងថាមានផ្នត់គំនិតមិនសមហេតុផលនៅក្នុងសាលារៀន នៅផ្ទះនៅក្នុងសហគមន៍។ល។ និងដឹងពីផលប៉ះពាល់អវិជ្ជមាននៃផ្នត់គំនិតទាំងនោះ ទើបពួកគាត់អាចចាប់ផ្តើមកែប្រែផ្នត់គំនិតនៅក្នុងសាលារៀន និងសហគមន៍របស់ពួកគាត់បាន។ នៅក្នុងសៀវភៅណែនាំដាច់ដោយ

ឡែកសម្រាប់នាយកសាលា និងគណៈកម្មការគ្រប់គ្រងសាលារៀន យើងបង្ហាញពីយុទ្ធសាស្ត្រ និងឧបករណ៍ជាក់លាក់ដើម្បីផ្លាស់ប្តូរផ្នត់គំនិតយេនឌ័រ និងដើម្បីបញ្ជ្រាបយេនឌ័រ។

**៤.ផលប៉ះពាល់នៃផ្នត់គំនិតយេនឌ័រក្នុងការអប់រំ**

បទដ្ឋានយេនឌ័របែបប្រពៃណីមួយចំនួន បង្កជាឧបសគ្គដល់ការអប់រំប្រកបដោយសមធម៌ និងបរិយាបន្ន[14] ជាពិសេសសម្រាប់ក្មេងស្រីមកពីគ្រួសារក្រីក្រ និងអនក្ខរជនះ

- គ្រួសារមួយចំនួនបានអប់រំទូន្មានកូនស្រី ឱ្យចេះស្តាប់បង្គាប់ឪពុកម្តាយ និងចាស់ទុំ សុភាពរាបសាទន់ភ្លន់ លើកទឹកចិត្តកូនស្រីឱ្យធ្វើការងារផ្ទះ និងមិនសូវផ្តល់ឱកាសឱ្យរៀនសូត្របានច្រើននោះទេ។ ទង្វើទាំងនេះ បានផ្តល់ផលអវិជ្ជមានដល់ក្មេងស្រី និងស្ត្រី។ ជាលទ្ធផល ក្មេងស្រីទាំងនេះមិនមានឱកាសបំពេញតាមសក្តានុពលរបស់ពួកគេនោះទេ ហើយពួកគេងាយរងគ្រោះនឹងការកេងប្រវ័ញ្ច និងអំពើហិង្សាផ្សេងៗ។
- គ្រូបង្រៀនក៏អាចមានផ្នត់គំនិតយេនឌ័រដែរ។ ឧទាហរណ៍ គ្រូច្រើនតែសរសើរសិស្សស្រីពីការស្លៀកពាក់ រូបសម្រស់ និងការយកចិត្តទុកដាក់របស់ពួកគេចំពោះអ្នកដទៃ។ ផ្ទុយទៅវិញ គ្រូច្រើនសរសើរសិស្សប្រុសពីកម្លាំងកាយ ត្រូវបានដាក់ការងារដែលពិបាកៗឱ្យធ្វើនៅក្នុងថ្នាក់ និងទទួលបានឱកាសបញ្ចេញមតិច្រើនជាងសិស្សស្រីផងដែរ។
- យោងតាមការស្រាវជ្រាវផ្នែកចិត្តសាស្ត្រសង្គម គ្រូមានទំនោរជឿថាមុខវិជ្ជាគណិតវិទ្យាពិបាករៀនសម្រាប់សិស្សស្រី ជាងសិស្សប្រុស។ ដោយសារជំនឿទាំងនេះ គ្រូបង្ហាញអាកប្បកិរិយាមិនដូចគ្នាចំពោះសិស្សប្រុស និងសិស្សស្រី។ ជំនឿទាំងនេះក៏បានញ៉ាំងឱ្យគ្រូមានការរំពឹងទុកខុសគ្នាចំពោះលទ្ធផលសិក្សារបស់សិស្សផងដែរ។ ការរំពឹងទុកមិនត្រឹមត្រូវបែបនេះអាចញ៉ាំងឱ្យស្ថានភាពនេះកើតឡើងក្លាយជាការពិត ពោលគឺសិស្សស្រីមានលទ្ធផលសិក្សាទាបព្រោះព្រោះគ្រូគិតថាពួកគេនឹងទទួលបានលទ្ធផលបែបនេះ ទើបមិនបានលើកទឹកចិត្តពួកគេឱ្យបានគ្រប់គ្រាន់។
- នៅក្នុងបណ្តាប្រទេសជាច្រើនដែលមានប្រាក់ចំណូលទាប និងមធ្យម ការអប់រំសម្រាប់មនុស្សវ័យជំទង់មិនសូវមានគុណភាព ហើយការងារដែលមានប្រាក់កម្រៃសមរម្យសម្រាប់ពលរដ្ឋដែលគ្រប់អាយុធ្វើការក៏មិនសូវសម្បូរដែរ។ ដោយសារតែបទដ្ឋានសង្គមដាក់កំហិតឱ្យក្មេងស្រីធ្វើតែការងារផ្ទះ ឬ ទទួលស្គាល់ការរៀបការទាំងវ័យក្មេង ក្មេងស្រីវ័យជំទង់មិនមានទំនោរនឹងបន្តការសិក្សានៅកម្រិតមធ្យមសិក្សា ឬមានទំនោរបោះបង់ការសិក្សាទាំងវ័យក្មេង[15]។

---

[14] UN. *Sustainable Development Goals*. Retrieved from https://sustainabledevelopment.un.org/sdgs

[15] VVOB vzw (Ed.). (2019). Putting SDG4 into practice: Enhancing adolescent wellbeing, learning and opportunities (1st ed.). Brussels: VVOB vzw.

## IV. សេចក្តីសន្និដ្ឋាន

ក្នុងមេរៀននេះ យើងបានវិភាគផ្នត់គំនិតយេនឌ័រក្នុងវិស័យអប់រំ។ ផ្នត់គំនិតយេនឌ័រមានភាពលំអៀង និងនាំឱ្យកើតមានជំនឿមិនសមហេតុផលចំពោះលក្ខណៈ និងតួនាទីរបស់ក្មេងស្រី និងក្មេងប្រុស ស្ត្រី និងបុរស ដែលត្រូវបាននាំបន្តពីជំនាន់មួយទៅជំនាន់មួយទៀតតាមរយៈសាលារៀន និងជីវភាពរស់នៅប្រចាំថ្ងៃនៅផ្ទះរបស់គេ។

ជាការចាំបាច់ដែលគ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងសាលារៀន ត្រូវចោទសួរដើម្បីផ្លាស់ប្តូរផ្នត់គំនិតយេនឌ័រ។ មុនពេលដែលពួកគាត់អាចប្រើប្រាស់សក្តានុពលរបស់ខ្លួន និងប្រែក្លាយជាភ្នាក់ងារសម្រាប់ការផ្លាស់ប្តូរដែលអាចកែប្រែផ្នត់គំនិតយេនឌ័របានដោយជោគជ័យ ពួកគាត់ចាំបាច់ត្រូវយល់ដឹង និងផ្លាស់ប្តូរជំនឿ និងការយល់ឃើញលម្អៀងអំពីយេនឌ័រជាមុនសិន។

# មេរៀនទី៤

## ការបង្រៀន និងរៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ

### I. សេចក្តីផ្តើម

គ្រូបង្រៀនម្នាក់មានគុណតម្លៃ និងបទដ្ឋានផ្នែកសង្គម និងវប្បធម៌ផ្សេងៗគ្នា ដែលជះឥទ្ធិពលទៅលើការបង្រៀនរបស់គាត់ ហើយពេលខ្លះ គាត់បានប្រែក្លាយទៅជាការរើសអើង និងលម្អៀងយេនឌ័រនៅក្នុងថ្នាក់រៀនទៀតផង។ ការរើសអើង និងវិសមភាពយេនឌ័រក្នុងវិស័យអប់រំនឹងបន្តកើតមាន ប្រសិនបើគ្រូបង្រៀនមានភាពលម្អៀង ឬមិនបានយកចិត្តទុកដាក់យ៉ាងសកម្មទៅលើការផ្លាស់ប្តូរការរំពឹងទុក និងបទដ្ឋានយេនឌ័របែបប្រពៃណី។ ដូច្នេះការបំប៉នសមត្ថភាពលើវិធីសាស្ត្របង្រៀន និងរៀនដែលឆ្លើយតបទៅនឹងសមភាពយេនឌ័រគឺជាកិច្ចការចាំបាច់។ នៅក្នុងមេរៀននេះ យើងនឹងពិភាក្សាអំពីភាពសំខាន់នៃការការបង្រៀន និងរៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ ហើយយើងពន្យល់ពីមូលហេតុដែលបណ្តាលឱ្យមានការរើសអើងយេនឌ័រនៅក្នុងថ្នាក់រៀន។ ក្រោយពីរៀនមេរៀននេះចប់ អ្នកនឹងទទួលបានការយល់ដឹងអំពីរបៀបដែលវិធីបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រអាចចូលរួមទប់ស្កាត់ការរើសអើងយេនឌ័រដោយយកចិត្តទុកដាក់ជាពិសេសចំពោះតម្រូវការរៀនសូត្ររបស់ក្មេងស្រី និងក្មេងប្រុស។

### II. វត្ថុបំណង

- ពន្យល់ពីសារៈសំខាន់នៃការឆ្លើយតបទៅនឹងសមភាពយេនឌ័រនៅក្នុងវិស័យអប់រំ
- ពន្យល់ពីមូលហេតុដែលបណ្តាលឱ្យកើតមានការរើសអើងយេនឌ័រនៅក្នុងវិស័យអប់រំ
- ពន្យល់អំពីវិធីបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ
- បញ្ចូលវិធីបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការបង្រៀន និងរៀន។

### III. ខ្លឹមសារ

**១.ហេតុអ្វីបានជាការអប់រំដែលឆ្លើយតបនឹងសមភាពយេនឌ័រសំខាន់ចំពោះ ក្មេងស្រី និងក្មេងប្រុស?**

ការលើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រក្នុងវិស័យអប់រំសំខាន់ដោយសារមូលហេតុជាច្រើន ទាំងនៅកម្រិតបុគ្គល កម្រិតគ្រួសារ សហគមន៍ និងប្រទេសទាំងមូល[16]។ ការបង្រៀន និងរៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រៈ

- កសាងសក្តានុពលរបស់សិស្សគ្រប់រូប
- ធ្វើឱ្យក្មេងស្រី និងក្មេងប្រុសកាន់តែមានទំនុកចិត្ត
- លើកកម្ពស់គុណភាពអប់រំ

[16] IREX (Ed.). (2014). Developing Gender Responsive Learning Environments. An IREX Toolkit for Teachers. Retrieved from http://rtglobaltigers.weebly.com/uploads/4/4/9/7/44979895/gender_and_educationtoolkit_jan_2014.pdf

- ធានាបានការរៀនសូត្រកាន់តែមានប្រសិទ្ធភាព
- បង្កើនឱកាសរកបានការងារធ្វើ និងប្រាក់ចំណូល
- ចូលរួមកាត់បន្ថយភាពក្រីក្រ
- ចូលរួមលើកកម្ពស់សុខភាពមាតា និងទារកឱ្យកាន់តែប្រសើរ
- បង្កផលវិជ្ជមាននៃការអប់រំឆ្លងជំនាន់ (កូនៗដែលមានឪពុកម្តាយទទួលបានការអប់រំមានឱកាសខ្ពស់ក្នុងការចូលសាលារៀន)
- លើកកម្ពស់ការអភិវឌ្ឍន៍សង្គម
- បង្កើនការចូលរួមរបស់ពលរដ្ឋ។

យើងបានរៀបរាប់ពីអត្ថប្រយោជន៍នៃការអប់រំដែលឆ្លើយតបនឹងសមភាពយេនឌ័រប្រកបដោយគុណភាព។ តើអ្នកគិតថាមានអត្ថប្រយោជន៍អ្វីផ្សេងទៀតទេ?

## ២.តើមានមូលហេតុអ្វីខ្លះដែលបណ្តាលឱ្យកើតមានការរើសអើងយេនឌ័រក្នុងវិស័យអប់រំ?

ដើម្បីស្វែងយល់ថាតើកត្តាអ្វីខ្លះដែលញ៉ាំងឱ្យកើតមានការរើសអើងផ្នែកយេនឌ័រ សូមអានស្ថានភាពមួយចំនួនដូចខាងក្រោមដោយយកចិត្តទុកដាក់ និងឆ្លើយសំណួរ។

### ស្ថានភាព កៈ

ពេលដែលអ្នកកំពុងបង្រៀនមេរៀនវេយ្យាករណ៍ភាសាខ្មែរ ស្រាប់តែសិស្សស្រីម្នាក់ឈ្មោះចន្ទលីណា និងសិស្សប្រុសម្នាក់ឈ្មោះប្រុស ចាប់ផ្តើមឈ្លោះប្រកែកគ្នានៅផ្នែកខាងក្រោយនៃថ្នាក់រៀន។ អ្នកចាប់ផ្តើមដំឡើងសំឡេង ហើយប្រាប់ឱ្យពួកគេឈប់ឈ្លោះគ្នា និងយកចិត្តទុកដាក់ស្តាប់គ្រូ។ យ៉ាងណាមិញ ៥នាទីក្រោយមក ការបង្រៀនរបស់អ្នកត្រូវបានរំខានម្តងទៀត ដោយចន្ទលីណា និងប្រុសដដែល។ លើកនេះ អ្នកបានហៅប្រុសឱ្យឡើងក្តារខៀន ហើយសរសេរ ១០ដងថា៖ “ខ្ញុំឈប់ធ្វើបាបចន្ទលីណាហើយ”។ ដោយយល់ថាមិនយុត្តិធម៌ ប្រុសបានសួរអ្នកថាហេតុអ្វីបានជាមិនដាក់ពិន័យចន្ទលីណាផង? អ្នកមិនខ្វល់ចំពោះសំណួររបស់គេទេ។ ភាគច្រើនគឺក្មេងប្រុសជាអ្នកដែលតែងតែបង្កបញ្ហា។

### ការឆ្លុះបញ្ចាំង កៈ

- តើរឿងនេះសមហេតុផលឬទេ? តើអ្នកយល់ស្របដែរឬទេថាប្រុស ជាដើមហេតុនៃការឈ្លោះប្រកែកគ្នានេះ?
- តើមូលហេតុអ្វីបានជាគ្រូដាក់ពិន័យតែលើប្រុសម្នាក់ឯង?
- តើចន្ទលីណាគួរទទួល ការពិន័យដែរទើបត្រឹមត្រូវមែនឬទេ?

- ប្រុសមានអារម្មណ៍ថាអយុត្តិធម៌។ តើហេតុការណ៍នេះនឹងជះឥទ្ធិពលលើអាកប្បកិរិយារបស់គេនាពេលអនាគតដោយរបៀបណា?

- តើអ្នកនឹងឆ្លើយតបចំពោះសំណួររបស់ប្រុសយ៉ាងដូចម្តេច?

**ស្ថានភាព ខ៖**

ដល់ពេលចុងឆ្នាំសិក្សាហើយ អ្នកកំពុងប្រកាសលទ្ធផលប្រឡងនៅក្នុងថ្នាក់។ សិស្សស្រីម្នាក់ឈ្មោះស្រី ទទួលបានពិន្ទុខ្ពស់ជាងគេក្នុងថ្នាក់។ ពេលដែលអ្នកអានពិន្ទុរបស់គាត់ឮៗ អ្នកបាននិយាយបន្ថែមទៀតថា៖ "តើមានអ្នកណាធ្លាប់គិតថាក្មេងស្រីម្នាក់នឹងទទួលបានពិន្ទុខ្ពស់ជាងគេលើមុខវិជ្ជាគណិតវិទ្យាដែរឬទេ?" សិស្សប្រុសម្នាក់ឈ្មោះតារា ដែលទទួលបានពិន្ទុខ្ពស់លើមុខវិជ្ជាគណិតវិទ្យាដែរបានប្រតិកម្មថា៖ "នាងគ្រាន់តែសំណាងល្អប៉ុណ្ណោះ គឺនាងបានទន្ទេញចាំមាត់លំហាត់ទាំងអស់"។ ស្រីដែលដំបូងមានមោទកភាព បានប្រែជាមិនសប្បាយចិត្តភ្លាមៗ។

**ការឆ្លុះបញ្ចាំង ខ៖**

- តើស្ថានភាពនេះសមហេតុផលឬទេ? តើអ្នកគិតថាស្រីទទួលបានពិន្ទុខ្ពស់ដោយសារគាត់ទន្ទេញលំហាត់ចាំមាត់មែនទេ?

- តើអ្នកយល់ឃើញយ៉ាងដូចម្តេចចំពោះប្រតិកម្មរបស់គ្រូ?

- តើអ្នកយល់ឃើញយ៉ាងដូចម្តេចចំពោះប្រតិកម្មរបស់តារា?

- បើជាអ្នកវិញ តើអ្នកនឹងឆ្លើយតបចំពោះប្រតិកម្មរបស់តារាយ៉ាងដូចម្តេច?

**ស្ថានភាព គ៖**

សម្រាប់ការសិក្សាមុខវិជ្ជាភាសាខ្មែរ សិស្សរបស់អ្នកត្រូវសរសេរតែងសេចក្តីខ្លីមួយដែលមានប្រធានបទ៖ "ការងារក្នុងក្តីសុបិនរបស់ខ្ញុំ"។ សិស្សស្រីម្នាក់ឈ្មោះទេវី បានសរសេរថា នាងចង់ក្លាយជាអ្នកគ្រូពេទ្យម្នាក់ ខណៈដែលសិស្សប្រុសម្នាក់ឈ្មោះដារុធ ចង់ក្លាយជាអ្នកបើករថយន្តធុនធ្ងន់។ ចំណែកឯក្មេងប្រុសម្នាក់ទៀតឈ្មោះចម្រើន និងក្មេងស្រីឈ្មោះសុគន្ធា សុបិនចង់ក្លាយជាវិស្វករ។ អ្នកបានសរសេរនៅក្នុងកំណែរបស់អ្នកទៅសុគន្ធាថា៖ "ដោយសារពិន្ទុរបស់ប្អូនល្អ វិស្វករជាជម្រើសមួយដ៏ត្រឹមត្រូវ។ យ៉ាងណាមិញ អ្នកចាំបាច់ត្រូវរឹងមាំ។ ការងារជាវិស្វករជាពិភពរបស់មនុស្សប្រុស"។

**ការឆ្លុះបញ្ចាំង គ៖**

- តើស្ថានភាពនេះសមហេតុផលឬទេ?

- តើអ្នកយល់យ៉ាងដូចម្តេចចំពោះយោបល់ត្រឡប់បែបនេះ?

- បើជាអ្នកវិញ តើអ្នកនឹងផ្តល់យោបល់ត្រឡប់ឱ្យសុគន្ធានោះបែបណាវិញ?
- តើគ្រូអាចនឹងសរសេរយោបល់ត្រឡប់បែបណាឱ្យចម្រើន?

**ស្ថានភាព ឃះ**

ក្រោយចប់ម៉ោងបង្រៀន អ្នកបានប្រាប់ឱ្យក្មេងប្រុសម្នាក់ឈ្មោះគីរីបោសសម្អាតថ្នាក់។ គីរីបានឆ្លើយថា៖ "នោះជាការងាររបស់ក្មេងស្រីទេ" រួចដើរចេញទៅលេងបាត់ទៅ។ អ្នកញាក់ស្មាដោយមិនដឹងថាគួរធ្វើយ៉ាងណា រួចក៏ប្រាប់ក្មេងស្រីម្នាក់ឈ្មោះម៉ាលីឱ្យធ្វើការងារនេះជំនួសវិញ។ ម៉ាលីមិននិយាយអ្វីមួយម៉ាត់ទេ ហើយក៏ចាប់ផ្តើមបោសសម្អាតថ្នាក់។

**ការឆ្លុះបញ្ចាំង ឃះ**

- តើស្ថានភាពនេះសមហេតុផលឬទេ? ហេតុអ្វី?
- តើអ្នកយល់ស្របនឹងសម្តីរបស់គីរីដែរឬទេដែលបានលើកឡើងថាការងារបោសសម្អាតថ្នាក់រៀនជាការងាររបស់ក្មេងស្រី?
- តើអ្នកយល់យ៉ាងដូចម្តេចចំពោះប្រតិកម្មរបស់គ្រូ? តើគាត់គួរឃាត់គីរីកុំឱ្យចេញទៅក្រៅដែរឬទេ?
- តើអ្នកយល់យ៉ាងដូចម្តេចចំពោះប្រតិកម្មរបស់ម៉ាលី?
- តើហេតុការណ៍មួយនេះនឹងប៉ះពាល់ដល់ជីវិតរបស់គីរី និងម៉ាលីដោយរបៀបណា?

នៅក្នុងស្ថានភាពខាងលើ ក្មេងប្រុស ឬក្មេងស្រីម្នាក់ទទួលបានការយកចិត្តទុកដាក់ខុសគ្នា ដោយផ្អែកទៅលើភេទរបស់ពួកគេ នេះមានន័យថាពួកគេទទួលបានការរើសអើងយេនឌ័រ។ ការរើសអើងយេនឌ័រសំដៅលើស្ថានភាពដែលមនុស្សទទួលបានការផ្តល់តម្លៃមិនដូចគ្នាដោយសារតែពួកគេមានភេទប្រុស ឬភេទស្រី ជាជាងផ្អែកលើបំណិន ឬសមត្ថភាពផ្ទាល់ខ្លួនរបស់ពួកគេ។ ផ្នត់គំនិតយេនឌ័រមិនមែនជាដំណើរហេតុពិត ដែលមិនអាចកែប្រែបាននោះដែរ។ ផ្នត់គំនិតគឺការកំណត់ជាទូទៅ ហើយជានិច្ចកាលជារូបភាពបំផ្លើសនៃចរិតមួយ។ ចំពោះភាពត្រឹមត្រូវ ផ្នត់គំនិតមិនមែនជាការពិតនោះទេ។

ប៉ុន្តែ តើមានមូលហេតុអ្វីខ្លះដែលបណ្តាលឱ្យការរើសអើងក្នុងវិស័យអប់រំនៅតែបន្តកើតមាន? ខាងក្រោមនេះ គឺជាមូលហេតុសំខាន់ៗចំនួន៣៖

**1.ការគំរាមកំហែងនៃផ្នត់គំនិត**

ការគំរាមកំហែងនៃផ្នត់គំនិតគឺជាបាតុភូតមួយដែលត្រូវបានចងក្រងជាឯកសារ។ បាតុភូតនេះបានលើកឡើងថា នៅពេលដែលអ្នកបានឮថាអ្នកមិនសូវពូកែលើផ្នែក ឬមុខវិជ្ជាអ្វីមួយ អ្នកនឹងចាប់ផ្តើមខ្សោយផ្នែក ឬមុខវិជ្ជានោះដោយមិនដឹងខ្លួន។ ឧទាហរណ៍ ការសិក្សាស្រាវជ្រាវបានអះអាងថា ក្មេងស្រី

មានសមត្ថភាពរៀនមុខវិជ្ជាគណិតវិទ្យាបានល្អដូចក្មេងប្រុសដែរ។ ពេលដែលយើងលុបបំបាត់ផ្នត់គំនិតយេនឌ័រដែលយល់ថាក្មេងស្រីរៀនមិនចេះមុខវិជ្ជាគណិតវិទ្យា យើងបានបញ្ចៀសស្ថានភាពមួយដែលសិស្សពាក់កណ្តាលថ្នាក់រៀនខ្សោយ។

### 2.លម្អៀងយេនឌ័រ

ផ្នត់គំនិតយេនឌ័រញ៉ាំងឱ្យគ្រូបង្រៀនមានភាពលម្អៀងយេនឌ័រ។ ភាពលម្អៀងយេនឌ័ររបស់គ្រូបង្រៀនដែលមិនត្រូវបានកត់សម្គាល់បានបង្កជាផលវិបាកដែលប៉ះពាល់ដល់សិស្សមួយចំនួន (ផ្នែកបន្ទាប់នឹងសិក្សាលម្អិតបន្ថែមទៀតអំពីលម្អៀងយេនឌ័រ)។ បើមិនមានវត្តមានផ្នត់គំនិតយេនឌ័រទេ លម្អៀងយេនឌ័រអាចនឹងសាបរលាប។

### 3.សម្ពាធ និងការធ្វើទុក្ខបុកម្នេញពីមិត្តរួមថ្នាក់

ជានិច្ចកាល កុមារជួបប្រទះនឹងផ្នត់គំនិតយេនឌ័រ (នៅក្នុងសៀវភៅសិក្សា តាមរយៈប្រព័ន្ធផ្សព្វផ្សាយ។ល។) ធ្វើឱ្យពួកគេចាប់ផ្តើមជឿថាអ្វីផ្សេងពីនោះគឺជារឿងដែលខុសឆ្គង ឬជារឿងដែលខុសប្រក្រតី។ ស្ថានភាពបែបនេះអាចបណ្តាលឱ្យកើតមានទង្វើធ្វើទុក្ខបុកម្នេញ និងបៀតបៀនដែលសំដៅទៅរកក្រុមសិស្សដែលមិនត្រូវគ្នានឹងផ្នត់គំនិតទាំងឡាយខាងលើ។ តាមរយៈការបង្រៀនសិស្សថាផ្នត់គំនិតទាំងនេះមិនត្រឹមត្រូវ អ្នកអាចបង្រៀនពួកគេឱ្យចេះអធ្យាស្រ័យចំពោះភាពខុសគ្នារវាងពួកគេ ហើយចេះគោរពគ្នាទៅវិញទៅមក។

## ៣.វិធីបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ

ជានិច្ចកាល វិធីបង្រៀនសំដៅលើសិល្បៈ និងវិទ្យាសាស្ត្រនៃការបង្រៀន។ វិធីបង្រៀនបានប្រែក្លាយទ្រឹស្តីនៃការសិក្សាទៅជាការអនុវត្តដោយផ្តល់នូវយុទ្ធសាស្ត្រ និងការណែនាំសម្រាប់សកម្មភាព និងការវិនិច្ឆ័យ។ វិធីបង្រៀនរាប់បញ្ចូលការយល់ដឹងពីសិស្ស តម្រូវការរបស់ពួកគេ ព័ត៌មានទូទៅរបស់ពួកគេ និងចំណាប់អារម្មណ៍របស់ពួកគេ។ វិធីបង្រៀនក៏ជួយនាំផ្លូវគ្រូពីវិធីទំនាក់ទំនងជាមួយសិស្ស និងបង្កើតបរិស្ថានមួយដែលលំនាំទទួលបានចំណេះដឹងរបស់សិស្សមានភាពរស់រវើក។

វិធីបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រសំដៅលើការបង្រៀនដែលយកចិត្តទុកដាក់ជាពិសេសលើតម្រូវការរៀនសូត្រជាក់លាក់របស់ក្មេងស្រី និងក្មេងប្រុស។ វិធីបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រទាមទារឱ្យគ្រូបង្រៀន និងនាយក នាយិកាសាលាឆ្លើយតបនឹងសមភាពយេនឌ័រនៅគ្រប់ផ្នែកទាំងអស់នៃការបង្រៀន។ វិធីបង្រៀនជាច្រើនមិនបានគិតដល់បញ្ហាយេនឌ័រនោះទេ។ ឧទាហរណ៍ សៀវភៅសិក្សា និងកម្រិតអប់រំនៅក្នុងប្រទេសជាច្រើនបានធ្វើឱ្យផ្នត់គំនិតយេនឌ័រកើនឡើងដូចជា៖ រូបភាពមនុស្សប្រុសតែងតែត្រូវបានគេប្រើនៅក្នុងតួនាទីដែលសកម្ម ខណៈដែលរូបភាពមនុស្សស្រីគ្រាន់តែមានតួនាទីជួយគាំទ្រប៉ុណ្ណោះ។ ជានិច្ចកាល វេជ្ជបណ្ឌិត និងវិស្វករត្រូវបានបង្ហាញជាភេទប្រុស ខណៈដែលអាជីពផ្នែកថែទាំ និងជំនួយការដូចជាគិលានុបដ្ឋាកយិកា និងលេខាត្រូវបានបង្ហាញជាភេទស្រី។

វិធីបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័ររាប់បញ្ចូលទាំងសកម្មភាពបង្រៀន និងរៀន ការរៀបចំកិច្ចតែងការ ការជ្រើសរើសសម្ភារឧបទេស ការប្រើប្រាស់ភាសា ការរៀបចំថ្នាក់រៀន ការពង្រឹងវិន័យ និងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស (សូមមើលរូបភាពទី២)។ នៅក្នុងជំពូកបន្ទាប់ យើងនឹងសិក្សាលម្អិតអំពីវិធីបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ។

វិធីបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រនឹងជំរុញឱ្យគ្រូបង្រៀនដឹងពីតួនាទីរបស់គាត់ជាអ្នកផ្លាស់ប្តូរផ្នត់គំនិតយេនឌ័រដែលមានពីមុនមក។ វាជួយឱ្យគ្រូបង្រៀនផ្តល់ឱកាសឱ្យសិស្សស្មើៗគ្នាដើម្បីចូលរួម និងទទួលបានចំណេះដឹងដោយមិនប្រកាន់ពីភេទរបស់ពួកគេឡើយ។ មិនតែប៉ុណ្ណោះ វិធីបង្រៀនដែលឆ្លើយតបនឹងយេនឌ័របានផ្តល់ឱកាសឱ្យគ្រូយកចិត្តទុកដាក់គ្រប់គ្រាន់ដល់បញ្ហាយេនឌ័រក្នុងការបង្រៀន និងនៅគ្រប់អន្តរកម្មទាំងក្នុង និងក្រៅថ្នាក់រៀន។ លើសពីនេះទៅទៀត វិធីបង្រៀនដែលឆ្លើយតបនឹងយេនឌ័រណែនាំគ្រូបង្រៀន និងនាយក នាយិកាសាលារៀនពីវិធីគាំទ្រសមភាពរវាងភេទផ្សេងគ្នា ញ៉ាំងឱ្យគ្រូសង្កេតសិស្សគ្រប់គ្នា និងដោះស្រាយភាពខុសគ្នារវាងបុគ្គលខាងផ្នែកតម្រូវការ និងបំណិន ហើយលើកកម្ពស់បរិស្ថាន និងសុខមាលភាពដែលមានលក្ខណៈបរិយាបន្ន។




**រូបភាពទី២៖ វិធីបង្រៀន និងរៀនឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការអនុវត្តជាក់ស្តែង**

## IV. សេចក្តីសន្និដ្ឋាន

ការលើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រក្នុងវិស័យអប់រំមានភាពសំខាន់ទាំងនៅកម្រិតបុគ្គល កម្រិតគ្រួសារ សហគមន៍ និងប្រទេសទាំងមូល។ ក្នុងមេរៀននេះ យើងបានរៀបរាប់ពីអត្ថប្រយោជន៍នៃការអប់រំដែលឆ្លើយតបនឹងសមភាពយេនឌ័រប្រកបដោយគុណភាព។

យើងបានលើកទឹកចិត្តឱ្យអ្នកឆ្លុះបញ្ចាំងអំពីមូលហេតុដែលបណ្តាលឱ្យមានការរើសអើងយេនឌ័រក្នុងវិស័យអប់រំ។ យើងបានបែបចែកជាមូលហេតុសំខាន់ៗចំនួន៣គឺ៖ ការគំរាមកំហែងនៃផ្នត់គំនិតលម្អៀងយេនឌ័រ និងសម្ពាធពីមិត្តរួមថ្នាក់។

ចុងក្រោយ យើងបានពន្យល់ពីបញ្ញត្តិវិធីបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ។ យើងជឿថាវិធីបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រជំរុញឱ្យគ្រូបង្រៀនឆ្លុះបញ្ចាំងពីជំនឿផ្ទាល់ខ្លួនរបស់ពួកគាត់អំពីតួនាទីយេនឌ័របែបប្រពៃណី និងផ្លាស់ប្តូរវិធីបង្រៀនរបស់គាត់។ នៅក្នុងសៀវភៅណែនាំសម្រាប់គ្រូ យើងពិភាក្សាស៊ីជម្រៅអំពីវិធីបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ។

# មេរៀនទី៥

## អំពើហិង្សាទាក់ទងនឹងយេនឌ័រនៅក្នុងសាលារៀន

### I. សេចក្តីផ្តើម

អំពើហិង្សាយេនឌ័រ និងជាពិសេសអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅក្នុងសាលារៀនគឺជាឧបសគ្គចម្បងដែលរាំងស្ទះការសម្រេចឱ្យបានសមភាពយេនឌ័រ។ ប្រព័ន្ធអប់រំផ្តល់ឱកាសសម្រាប់អន្តរាគមន៍ដែលមានលក្ខណៈបង្កើតថ្មី មានប្រសិទ្ធភាព និងមាននិរន្តរភាពដើម្បីបញ្ចៀសអំពើហិង្សាប្រឆាំងកុមារ និងរវាងកុមារ និងកុមារដូចគ្នា និងដើម្បីការផ្លាស់ប្តូរអត្តចរិត និងជំនឿអំពីតួនាទីយេនឌ័រ។ គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលា គឺជាមូលដ្ឋានគ្រឹះនៃការផ្លាស់ប្តូរការអនុវត្ត អត្តចរិត និងគុណតម្លៃរួមទាំងការបំផុសគំនិតឱ្យសិស្សក្នុងការយល់ដឹង និងការអនុវត្តសមភាពយេនឌ័រ និងឥរិយាបថអហិង្សា។

ក្នុងមេរៀននេះ យើងសិក្សាបន្ថែមទៀតអំពីអំពើហិង្សាយេនឌ័រដែលទាក់ទងនឹងសាលារៀន និងផលប៉ះពាល់អវិជ្ជមានរបស់វាទៅលើសុខមាលភាព និងលទ្ធផលសិក្សារបស់កុមារ ព្រមទាំងកំណត់យុទ្ធសាស្ត្រដើម្បីលុបបំបាត់អំពើហិង្សាប្រភេទនេះ និងបង្កើតបរិស្ថានរៀនសូត្រមួយដែលមានសុវត្ថិភាពជំនួសវិញ។

### II. វត្ថុបំណង

- កំណត់បាននូវនិយមន័យអំពើហិង្សាយេនឌ័រដែលទាក់ទងនឹងសាលារៀន និងផលប៉ះពាល់របស់វា
- ទទួលស្គាល់ពីសារៈសំខាន់នៃបរិយាកាសសាលារៀនដែលមានសុវត្ថិភាព
- កំណត់វិធានការដើម្បីទប់ស្កាត់អំពើហិង្សាយេនឌ័រដែលទាក់ទងនឹងសាលារៀន និងបង្កើតបរិស្ថានសិក្សាដែលមានសុវត្ថិភាព។

### III. ខ្លឹមសារមេរៀន

#### ១.តើអ្វីទៅជាអំពើហិង្សាយេនឌ័រដែលទាក់ទងនឹងសាលារៀន?

អំពើហិង្សាយេនឌ័រដែលទាក់ទងនឹងសាលារៀនសំដៅលើសកម្មភាព ឬការគំរាមកំហែងពាក់ព័ន្ធនឹងអំពើហិង្សាផ្លូវភេទ ផ្លូវកាយ ឬផ្លូវចិត្តដែលកើតឡើងនៅខាងក្នុង និងជុំវិញសាលារៀន បណ្តាលមកពីបទដ្ឋាន និងផ្នត់គំនិតយេនឌ័រ និងកើនឡើងដោយសារការបែងចែកអំណាចមិនស្មើគ្នា។ អំពើហិង្សាយេនឌ័រដែលទាក់ទងនឹងសាលារៀនគឺជាឧបសគ្គដ៏ធំចំពោះការសម្រេចបានការអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្នសម្រាប់ក្មេងស្រី និងក្មេងប្រុស (UNESCO, 2016)។

ករណីរំលោភបំពានលើកុមារក្នុងបរិបទសាលារៀននៅកម្ពុជាមានអត្រាខ្ពស់ចំពោះកុមារទាំងពីរភេទ។ តាមរយៈការស្រាវជ្រាវដែលរៀបចំឡើងដោយវីរីអូប៊ី អ្នកផ្តល់ចម្លើយភេទប្រុសនៅខេត្តបាត់ដំបង និងខេត្តស្វាយរៀងមានរបាយការណ៍ខ្ពស់ជាងភេទស្រីចំពោះករណីរំលោភបំពានផ្លូវអារម្មណ៍ ផ្លូវកាយ និងផ្លូវភេទ។ ប៉ុន្តែក្នុងការសម្ភាសន៍ជាបុគ្គល និងជាក្រុម មាតាបិតា គ្រូបង្រៀន និងសិស្សពិភាក្សាផ្តោតលើរបៀបដែលក្មេងស្រីក្លាយជាជនរងគ្រោះដោយសារអំពើហិង្សាយេនឌ័រដែលទាក់ទងនឹងសាលារៀន។ នៅក្នុងសហគមន៍នៅកម្ពុជា គេជឿថាកិត្តិយសរបស់ក្មេងស្រីជះឥទ្ធិពលដល់មុខមាត់របស់គ្រួសារនៅក្នុងសហគមន៍។ អាស្រ័យហេតុនេះហើយ ទើបការរំលោភផ្លូវភេទចំពោះក្មេងស្រីច្រើនត្រូវបានលើកយកមកពិភាក្សាដោយគ្រូបង្រៀន មាតាបិតា ឬសមាជិកផ្សេងៗទៀតនៅក្នុងសហគមន៍ ជាងករណីរំលោភបំពានផ្លូវភេទលើក្មេងប្រុស។ ស្ថានភាពនេះមិនបញ្ជាក់ថាការរំលោភបំពានផ្លូវភេទលើក្មេងស្រីមានស្ថានភាពធ្ងន់ធ្ងរជាងក្មេងប្រុសនោះទេ ព្រោះឱ្យតែជាអំពើរំលោភបំពានផ្លូវភេទ ទោះកើតមានលើភេទណាក៏ដោយ សុទ្ធតែមិនអាចទទួលយកបានទាំងអស់។

អំពើហិង្សាយេនឌ័រដែលទាក់ទងនឹងសាលារៀនអាចកើតមានឡើងនៅទីកន្លែងជាច្រើននៅក្នុង និងជុំវិញបរិវេណសាលារៀន។ អំពើហិង្សាយេនឌ័រអាចកើតមានឡើងនៅក្នុងសាលារៀន អាចបង្កឡើងដោយគណៈគ្រប់គ្រងសាលារៀន ដោយគ្រូបង្រៀន ឬបង្កឡើងដោយសិស្សផ្សេងទៀត។ អំពើហិង្សាយេនឌ័រក៏អាចកើតឡើងនៅតាមផ្លូវពីផ្ទះទៅសាលាផងដែរ។ ចំពោះសិស្សដែលដើរ ឬជិះកង់ទៅសាលាតែម្នាក់ឯង មានហានិភ័យនឹងរងគ្រោះដោយសារអំពើហិង្សា។ គប្បីលើកទឹកចិត្តពួកគេឱ្យធ្វើដំណើរមកសាលារៀនជាក្រុម ជាជាងធ្វើដំណើរតែម្នាក់ឯង។ កុមារគួរតែទទួលបានការការពារ និងមានអារម្មណ៍សុវត្ថិភាពពេលនៅផ្ទះ ប៉ុន្តែមានកុមារមួយចំនួនបានទទួលរងអំពើហិង្សាយេនឌ័រនៅផ្ទះផងដែរ។ មានករណីខ្លះ ឪពុកម្តាយ ឬបងប្អូនបង្កើតអាចប្រើអំពើហិង្សាលើកុមារ។ មានករណីផ្សេងៗទៀតដែលកុមារបានឃើញអំពើហិង្សាកើតឡើងរវាងឪពុក ម្តាយ រវាងបងប្អូនបង្កើត ឬរវាងបងប្អូនបង្កើតជាមួយឪពុកម្តាយ។ នៅក្នុងការស្រាវជ្រាវមួយផ្សេងទៀតដែលរៀបចំឡើងដោយវីរីអូប៊ី បានបង្ហាញថាមានកុមារជាច្រើននៅកម្ពុជាដែលបានឃើញអំពើហិង្សាក្នុងគ្រួសារ ធ្វើឱ្យប៉ះពាល់ដល់សុខមាលភាព និងលទ្ធផលសិក្សារបស់ពួកគេ។ អំពើហិង្សាយេនឌ័រក៏កើតមានឡើងនៅក្នុងសហគមន៍ និងលើបណ្តាញអ៊ីនធើនែតផងដែរ។ ពេលដែលកុមារកំពុងប្រើប្រាស់បណ្តាញអ៊ីនធើនែត ឬកំពុងផ្ញើសារទំនាក់ទំនង ពួកគេអាចក្លាយជាជនរងគ្រោះដោយសារការធ្វើទុក្ខបុកម្នេញលើបណ្តាញអ៊ីនធើនែត។




**រូបភាពទី៣៖ អំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រនៅក្នុង និងជុំវិញបរិវេណសាលារៀន**

**២.តើអ្វីទៅជាអំពើហិង្សាលើកុមារ?**

ការស្រាវជ្រាវបានបង្ហាញថាអំពើហិង្សាលើកុមារ ទោះជាកើតឡើងចំពោះផ្លូវអារម្មណ៍ ផ្លូវភេទ ឬរូបរាងកាយក៏ដោយ សុទ្ធតែអាចបង្កផលប៉ះពាល់ធ្ងន់ធ្ងរដូចគ្នាចំពោះសុខមាលភាព និងសុខភាពផ្លូវកាយ និង/ឬផ្លូវចិត្តរយៈពេលវែងរបស់កុមារ (Glaser, 2002; Gershoff, 2002; Farahati et al., 2003; Currie et al., 2010; Eliot et al., 2010)។ អំពើហិង្សាលើកុមារសំដៅលើគ្រប់ទម្រង់នៃអន្តរកម្មដែលបង្កផលប៉ះពាល់ប្រឆាំងកុមារ ឬរវាងកុមារ និងកុមារដូចគ្នា។ អំពើហិង្សាលើកុមាររាប់បញ្ចូលគ្រប់អន្តរកម្មដែលបង្កផលប៉ះពាល់ដល់កុមារ។ យើងបែងចែកអំពើហិង្សាលើកុមារជា ៣ទម្រង់៖

**1. អំពើហិង្សាផ្លូវអារម្មណ៍** រាប់បញ្ចូលគ្រប់អន្តរកម្មដែលប៉ះពាល់ដល់ផ្លូវអារម្មណ៍របស់កុមារ។ ការដាក់ឱ្យនៅដាច់ពីគេ ការវាយប្រហារដោយពាក្យសម្តី ការធ្វើឱ្យអាប់មុខ និងការបំភិតបំភ័យសុទ្ធតែជាឧទាហរណ៍នៃអំពើហិង្សាផ្លូវអារម្មណ៍។

**2. អំពើហិង្សាលើរូបរាងកាយ** រាប់បញ្ចូលគ្រប់អន្តរកម្មដែលប៉ះពាល់ដល់ផ្លូវកាយកុមារ។ ការវាយដំ ទាត់ ធាក់ ឬបោចសក់សុទ្ធតែជាឧទាហរណ៍នៃអំពើហិង្សាលើរូបរាងកាយ។

**3. អំពើហិង្សាផ្លូវភេទ** គឺជាការចូលរួមរបស់កុមារក្នុងសកម្មភាពផ្លូវភេទដែលកុមារី ឬកុមារាម្នាក់នោះនៅមិនទាន់យល់ដឹងច្បាស់ មិនអាចផ្តល់ការយល់ព្រមបាន ឬដែលកុមារនោះនៅមិនទាន់លូតលាស់កាយសម្បទាសមរម្យសម្រាប់សកម្មភាពនោះនៅឡើយ ឬមូលហេតុផ្សេងទៀតដែលល្មើសច្បាប់ ឬ

បម្រាមរបស់សង្គម។ និយមន័យនេះរាប់បញ្ចូលទាំងអាកប្បកិរិយាដែលមានការប៉ះពាល់រូបរាងកាយ និង មិនប៉ះពាល់ផងដែរ។




រូបភាពទី៤៖ អំពើហិង្សាផ្លូវអារម្មណ៍ ផ្លូវកាយ និងផ្លូវភេទ

អំពើហិង្សាច្រើនកើតមាននៅក្នុងទំនាក់ទំនងរវាងអ្នកមើលថែ និងកុមារ (Glaser, 2002)។ អ្នកមើលថែរួមមានឪពុកម្ដាយ អាណាព្យាបាល និងសមាជិកគ្រួសារផ្សេងៗទៀត ក៏ដូចជាគ្រូបង្រៀន និងសមាជិកសហគមន៍ផងដែរ។

យ៉ាងណាមិញ អំពើហិង្សាលើកុមារក៏អាចកើតមានរវាងកុមារដែលមានវ័យស្របាលគ្នាផងដែរ ដូចជាការធ្វើបាបសិស្សសាលាផ្សេងទៀតនៅក្នុង និងក្រៅសាលារៀនបានក្លាយជាឧទាហរណ៍ដែលបានកើតឡើងជាញឹកញាប់ (Huang et al., 2019)។

ខណៈដែលមានទម្រង់មួយចំនួននៃអំពើហិង្សាលើកុមារងាយសង្កេតឃើញដោយអ្នកខាងក្រៅជានិច្ចកាល អំពើហិង្សាលើកុមារកើតមានឡើងក្នុងបរិស្ថានបិទជិត ហើយមានតែកុមារ និងអ្នកប្រព្រឹត្តប៉ុណ្ណោះដែលដឹង។

ជួនកាល អំពើហិង្សាលើកុមារមិនត្រូវបានគេសង្កេតឃើញនោះទេ។ នៅក្នុងបណ្ដាប្រទេសជាច្រើន ការដាក់ទណ្ឌកម្មលើរូបរាងកាយកុមារមិនត្រូវបានចាត់ទុកថាជាការរំលោភបំពាននោះទេ (Stoltenborge et al., 2015; Parkes et al., 2016)។ លើសពីនេះទៅទៀត ការយល់ឃើញ និងការទទួលអារម្មណ៍របស់កុមារចំពោះអំពើហិង្សាលើកុមារអាស្រ័យលើបទដ្ឋាន និងជំនឿយេនឌ័រ ផ្នត់គំនិតយេនឌ័រ និងការយល់ឃើញអំពីសមភាពរវាងភេទ។ ឧទាហរណ៍ ជំនឿ និងបទដ្ឋានយេនឌ័របានញ៉ាំងឱ្យកុមារទទួលរងស្ថានភាពជាជនរងគ្រោះខុសៗគ្នាទៅតាមភេទរបស់ពួកគេ។

### សកម្មភាព៖ អំពើហិង្សាយេនឌ័រដែលទាក់ទងនឹងសាលារៀននៅក្នុង និងជុំវិញបរិវេណសាលា

តើប្រភេទអំពើហិង្សាយេនឌ័រដែលទាក់ទងនឹងសាលារៀនដូចខាងក្រោមធ្លាប់កើតមាននៅក្នុង និងជុំវិញបរិវេណសាលារៀនរបស់អ្នកដែរឬទេ?

សូមបញ្ជាក់ពីទម្រង់នៃអំពើហិង្សា ដែលបានកើតឡើង៖ ជាអំពើហិង្សាផ្លូវអារម្មណ៍ ផ្លូវកាយ ឬផ្លូវភេទ?

- នៅក្នុងសាលារៀន៖
    - គ្រូបង្រៀនម្នាក់ប្រើទណ្ឌកម្មលើរូបរាងកាយសិស្សដែលប្រព្រឹត្តមិនសមរម្យនៅក្នុងថ្នាក់រៀនរបស់គាត់ (ផ្លូវភេទ/ផ្លូវកាយ/ផ្លូវចិត្ត)
    - ពេលសិស្សស្រីរៀនពូកែមុខវិជ្ជាគណិតវិទ្យា ខុសពីការរំពឹងទុករបស់គ្រូ គ្រូបង្រៀនបានហៅឈ្មោះពួកគេដោយប្រើពាក្យសម្ដីមិនសមរម្យ (ផ្លូវភេទ/ផ្លូវកាយ/ផ្លូវចិត្ត)
    - ក្មេងប្រុសដែលចង់លេងលោតអន្ទាក់តែងត្រូវបានសិស្សផ្សេងៗទៀតហៅថា "ខ្ទើយ" ឬហៅថាជា "ក្មេងស្រី" (ផ្លូវភេទ/ផ្លូវកាយ/ផ្លូវចិត្ត)
    - ក្មេងប្រុសដែលសម្ដែងអារម្មណ៍របស់ខ្លួនត្រូវបានគេធ្វើបាបដោយសារបានធ្វើ "ដូចជាក្មេងស្រី" (ផ្លូវភេទ/ផ្លូវកាយ/ផ្លូវចិត្ត)

- ○ សិស្សម្នាក់បានបង្ហាញរូបភាពដែលទាក់ទងនឹងផ្លូវភេទ ពេលដែលសិស្សផ្សេងៗទៀតមិនចូលចិត្ត ហើយមានអារម្មណ៍ថាពិបាក (ផ្លូវភេទ/ផ្លូវកាយ/ផ្លូវចិត្ត)
- នៅតាមផ្លូវទៅសាលារៀន៖
  - ○ សិស្សមិនមានអារម្មណ៍ថាមានសុវត្ថិភាពនោះទេ ពេលធ្វើដំណើរទៅសាលារៀន និងពេលត្រឡប់មកផ្ទះវិញ ព្រោះមានបុរសចំណាស់ម្នាក់តែងតែតាមពួកគេនៅកាច់ជ្រុងផ្លូវ (ផ្លូវភេទ/ផ្លូវកាយ/ផ្លូវចិត្ត)
  - ○ សិស្សស្រីតែងធ្វើដំណើរត្រឡប់ទៅផ្ទះវិញជុំគ្នាជាក្រុមតូចៗ ព្រោះពួកគេខ្លាចត្រូវគេបៀតបៀននៅតាមផ្លូវ (ផ្លូវភេទ/ផ្លូវកាយ/ផ្លូវចិត្ត)
- នៅផ្ទះ៖
  - ○ ឪពុកម្ដាយដាក់ទណ្ឌកម្មលើរូបរាងកាយកូនៗរបស់ពួកគាត់ ពេលដែលពួកគេទទួលបានលទ្ធផលសិក្សាទាប (ផ្លូវភេទ/ផ្លូវកាយ/ផ្លូវចិត្ត)
  - ○ សិស្សស្រីម្នាក់មិនអាចបន្តសិក្សាមុខវិជ្ជាវិទ្យាសាស្ត្របាន ព្រោះឪពុកម្ដាយរបស់នាងគិតថាមុខវិជ្ជាវិទ្យាសាស្ត្រមិនមែនសម្រាប់ក្មេងស្រីរៀននោះទេ (ផ្លូវភេទ/ផ្លូវកាយ/ផ្លូវចិត្ត)
- នៅក្នុងសហគមន៍៖
  - ○ ក្មេងស្រីដែលមានមិត្តភក្តិប្រុសគេហៅថា "អាក្រក់/ខិលខូច/ស្រីខូច" (ផ្លូវភេទ/ផ្លូវកាយ/ផ្លូវចិត្ត)
  - ○ ក្មេងស្រីជំទង់ម្នាក់ដែលមានផ្ទៃពោះ ត្រូវបានបណ្ដេញចេញពីសាលារៀនដោយសារធ្វើឱ្យប៉ះពាល់កិត្តិយសគ្រួសារ (ផ្លូវភេទ/ផ្លូវកាយ/ផ្លូវចិត្ត)
- បច្ចេកវិទ្យាទំនាក់ទំនង (តាមរយៈទូរស័ព្ទចល័ត ឬបណ្ដាញអ៊ីនធើនែត)
  - ○ មិត្តរួមថ្នាក់ម្នាក់បានផ្ញើសារមិនសមរម្យទៅកាន់សិស្សផ្សេងទៀត (ផ្លូវភេទ/ផ្លូវកាយ/ផ្លូវចិត្ត)
  - ○ សិស្សម្នាក់បានបង្ហោះសារចចាមអារ៉ាមនៅលើបណ្ដាញសង្គមអំពីមិត្តរួមថ្នាក់ម្នាក់ (ផ្លូវភេទ/ផ្លូវកាយ/ផ្លូវចិត្ត)
  - ○ គ្រូបង្រៀនម្នាក់បានចែករំលែករូបភាព ឬវីដេអូដែលគួរឱ្យអៀនខ្មាស់របស់មិត្តរួមការងារម្នាក់ (ផ្លូវភេទ/ផ្លូវកាយ/ផ្លូវចិត្ត)។

**៣.តើអំពើហិង្សាទាក់ទងនឹងយេនឌ័រមានផលប៉ះពាល់អ្វីខ្លះ?**

គ្រប់ទម្រង់នៃអំពើហិង្សាប្រឆាំងកុមារសុទ្ធតែរំលោភសិទ្ធិកុមារ។ វត្តមាននៃអំពើហិង្សាទាក់ទងនឹងយេនឌ័រផ្ទុយនឹងគោលការណ៍របស់អនុសញ្ញារបស់អង្គការសហប្រជាជាតិស្ដីអំពីសិទ្ធិកុមារ។

អំពើហិង្សាលើកុមារបង្កផលប៉ះពាល់អវិជ្ជមានចំពោះសុខភាព និងសុខមាលភាពរបស់ក្មេងស្រី និងក្មេងប្រុស។ អំពើហិង្សាទាក់ទងនឹងយេនឌ័របណ្ដាលឱ្យមានការប៉ះទង្គិចលើផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ សុខភាពបន្តពូជ ទំនុកចិត្តលើខ្លួនឯង ក៏ដូចជាសមត្ថភាពផ្ដោតលើការសិក្សានៅសាលារៀន។ អំពើហិង្សាយេនឌ័រអាចបង្កផលប៉ះពាល់រយៈពេលយូរលើផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទ។ កុមារដែលទទួលរងអំពើហិង្សាអាចមានទំនោរក្លាយជាមិនមានភាពរំញោចចំពោះការឈឺចាប់ ហើយពួកគេអាចនឹងមើលឃើញថាការប្រើអំពើហិង្សាជាមធ្យោបាយស្របច្បាប់ដើម្បីសម្រេចគោលបំណងផ្ទាល់ខ្លួនរបស់ពួកគេទៀតផង។ ផលប៉ះពាល់ទាំងនេះកើតមានចំពោះដំណើរការលូតលាស់តាំងពីវ័យកុមាររហូតដល់ធំពេញវ័យ ហើយវាជះឥទ្ធិពលចំពោះសង្គមទាំងមូល ដោយដាក់កំហិតចំពោះការចូលរួមចំណែករបស់ពួកគេក្នុងការអភិវឌ្ឍន៍សង្គម។ លើសពីនេះទៅទៀត អំពើហិង្សាទាក់ទងនឹងយេនឌ័រញ៉ាំងឱ្យវិសមភាពសិទ្ធិអំណាចក្នុងទំនាក់ទំនងបុគ្គល និងក្នុងសង្គមបន្តកើតឡើងឥតឈប់ឈរ។ កត្តាដ៏ធំមួយដែលជាបេះដូងនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រគឺវិសមភាពរវាងស្ត្រី/ក្មេងស្រី និងបុរស/ក្មេងប្រុសដែលកំពុងរីករាលដាលខ្លាំង និងការរើសអើងដែលស្ត្រី និងក្មេងស្រីជួបប្រទះនៅក្នុងសង្គម។ ភាពអន់ថយផ្នែកសេដ្ឋកិច្ច និងសង្គមគឺជាការបញ្ជាក់អំពីវិសមភាពនៃទំនាក់ទំនងសិទ្ធិអំណាច និងអំពើហិង្សា។ លើសពីនេះទៅទៀត អំពើហិង្សាទាក់ទងនឹងយេនឌ័រជាកត្តាដែលញ៉ាំងឱ្យវិសមភាពនៃទំនាក់ទំនងសង្គម សេដ្ឋកិច្ច និងនយោបាយរវាងស្ត្រី និងបុរសកាន់តែរឹងមាំ នៅគ្រប់កម្រិតនៃសង្គម និងគ្រប់ប្រទេសក្នុងពិភពលោក។

ដោយមូលហេតុខាងលើ ការដោះស្រាយ និងទប់ស្កាត់អំពើហិង្សាយេនឌ័រគួរតែចាត់ទុកជាបញ្ហាអាទិភាព។

## ៤.តើធ្វើដូចម្ដេចទើបអាចលុបបំបាត់អំពើហិង្សាយេនឌ័រដែលទាក់ទងនឹងសាលារៀន?

ដើម្បីការពារសិទ្ធិកុមារ និងថែរក្សាសុខមាលភាព និងសុខភាពរបស់កុមារ ចាំបាច់ត្រូវលុបបំបាត់គ្រប់ទម្រង់នៃការរំលោភបំពានលើកុមារ និងជាពិសេសអំពើហិង្សាយេនឌ័រដែលទាក់ទងនឹងសាលារៀន។

សាលារៀនដើរតួនាទីសំខាន់នៅក្នុងដំណើរការនេះ។ សាលារៀនដែលបដិសេធការរំលោភបំពានបានបញ្ជូនសារដ៏រឹងមាំមួយទៅកាន់សិស្សអំពីការប្រើប្រាស់អំពើហិង្សា ការគំរាមកំហែង និង/ឬការធ្វើឱ្យអាប់ឱនកិត្តិយស។ ប្រព័ន្ធអប់រំផ្ដល់ឱកាសឱ្យមានអន្តរាគមន៍ដែលមានលក្ខណៈបង្កើតថ្មី មានប្រសិទ្ធភាព និងមាននិរន្តរភាពដើម្បីបញ្ចៀសអំពើហិង្សាយេនឌ័រដែលទាក់ទងនឹងសាលារៀន និងឱកាសសម្រាប់ផ្លាស់ប្ដូរអត្តចរិត និងជំនឿចំពោះតួនាទីយេនឌ័រ។

គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀនគឺជាបុគ្គលដ៏សំខាន់ ជាមូលដ្ឋានគ្រឹះសម្រាប់ផ្លាស់ប្ដូរការអនុវត្ត អត្តចរិត និងគុណតម្លៃ និងបណ្ដុះឱ្យសិស្សមានការយល់ដឹង និងអនុវត្តសមភាពយេនឌ័រ និងអាកប្បកិរិយាអហិង្សា។

បន្ថែមលើនេះទៅទៀត ការសិក្សាពិសោធន៍បានបង្ហាញឱ្យឃើញរួចហើយពីផលប៉ះពាល់វិជ្ជមានរយៈពេលយូរនៃអន្តរាគមន៍ ឬការផ្លាស់ប្តូរនៃកម្មវិធីសិក្សាអំពីសុខមាលភាព និងលទ្ធផលសិក្សារបស់កុមារ (ឧទាហរណ៍៖ អំណះអំណាងល្អបំផុតមាននៅក្នុងឯកសារដោយ Schweinhart and Weikart, 1980; Cho et al., 2011; Cabus and De Witte, 2015; Chetty et al., 2016; និងឯកសារផ្សេងៗទៀត)។

**៥.សាលារៀនដែលមានសុវត្ថិភាព និងរាក់ទាក់**

ហេដ្ឋារចនាសម្ព័ន្ធរូបវន្តរបស់សាលារៀនមានសារសំខាន់ព្រោះអំពើហិង្សាយេនឌ័រដែលទាក់ទងនឹងសាលារៀនអាចកើតមាននៅក្នុង និងជុំវិញបរិវេណអាគារសាលារៀន ទីធ្លាសាលារៀន និងនៅតាមផ្លូវពីផ្ទះទៅសាលា និងត្រឡប់មកផ្ទះវិញ។ ចំណុចដែលច្រើនកើតមានអំពើហិង្សារួមមានក្នុងបន្ទប់ទឹក បន្ទប់រៀនដែលគ្មានមនុស្ស ផ្លូវដើរមុខថ្នាក់រៀន និងអាគារសម្រាប់សិស្សស្នាក់នៅ ក៏ដូចជាបរិវេណទីធ្លាសាលារៀនទាំងមូល។

អំពើហិង្សាយេនឌ័រដែលទាក់ទងនឹងសាលារៀនអាចនឹងកើតឡើងកាន់តែធ្ងន់ធ្ងរដោយសារតែហេដ្ឋារចនាសម្ព័ន្ធដែលត្រូវបានរៀបចំ និងគ្រប់គ្រងមិនបានល្អ ដូចជាមិនមានពន្លឺគ្រប់គ្រាន់ ឬសោរខូច ក៏ដូចជាការដាក់នៅដាច់ឆ្ងាយពីគេ និងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធមិនបានគ្រប់ជ្រុងជ្រោយ។

សាលារៀនមួយដែលមានសុវត្ថិភាព និងមានការគាំទ្រ មានហេដ្ឋារចនាសម្ព័ន្ធរូបវន្តសមស្របដែលរួមមានអាគារសិក្សា ទីធ្លា រចនាសម្ព័ន្ធទឹក និងអនាម័យ សង្ហារឹម ប្រព័ន្ធបំភ្លឺ និងឧបករណ៍សន្តិសុខជាដើម។ ខណៈដែលមានភាពចាំបាច់ត្រូវធានាឱ្យបានថាហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងចន្លោះផ្សេងៗមានសុវត្ថិភាព សាលារៀនក៏ចាំបាច់ត្រូវមានភាពរាក់ទាក់ស្វាគមន៍ចំពោះសិស្ស មាតាបិតាសិស្ស និងភាគីផ្សេងៗទៀតនៅក្នុងសហគមន៍ផងដែរដើម្បីលើកទឹកចិត្តឱ្យមានគណនេយ្យភាព និងការចូលរួម។

## វិធីធានាចន្លោះសុវត្ថិភាពនៅក្នុងសាលារៀន

| | |
|---|---|
| ទីតាំងសាលារៀន ទីធ្លាសាលារៀន និងផ្លូវចូល | • សាលារៀនត្រូវបានសង់លើទីតាំងដែលសហគមន៍មូលដ្ឋានយល់ថាមានសុវត្ថិភាព (ឧទាហរណ៍៖ ឆ្ងាយពីរង្គសាល និងទីតាំងដែលមានកម្រិតបទឧក្រិដ្ឋខ្ពស់)<br>• ធ្វើសវនកម្មត្រួតពិនិត្យសុវត្ថិភាពនៃអាគារសិក្សា ទីធ្លា និងផ្លូវចូលសាលាដើម្បីកំណត់ទីតាំងដែលមិនមានសុវត្ថិភាព ដោយស្តាប់យោបល់ក្រុមសិស្សផ្សេងៗគ្នា (ឧទាហរណ៍៖ ក្មេងប្រុស ក្មេងស្រី កុមារជនជាតិភាគតិច កុមារដែលមានពិការភាព។ល។)<br>• កែលម្អ និងជួសជុលប្រព័ន្ធបំភ្លឺនៅក្នុងបរិវេណ និងជុំវិញទីធ្លាសាលារៀន<br>• ធ្វើរបងព័ទ្ធជុំវិញទីធ្លាសាលា និងទ្វារបិទច្រកចេញចូល និងសម្អាតព្រៃគម្ពោត។ |
| ការរចនាអាគារ និងថ្នាក់រៀន | • គិតអំពីបញ្ហាសុវត្ថិភាព និងអំពើហិង្សាផ្អែកយេនឌ័រដែលទាក់ទងនឹងសាលារៀន ពេលរៀបចំហេដ្ឋារចនាសម្ព័ន្ធសាលារៀន<br>• ធានាភាពងាយស្រួលក្នុងការមើលឃើញដល់ក្នុងថ្នាក់រៀនពីខាងក្រៅដោយបង្កើនចំនួន និងពង្រីកទំហំទ្វារ និងបង្អួចថ្នាក់រៀន ការិយាល័យ និងលំហ ផ្សេងៗទៀត។ |
| ហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និងអនាម័យ | • បន្ទប់ទឹកដាច់ដោយឡែកពីគ្នា និងមានចាក់សោរសម្រាប់សិស្សប្រុស សិស្សស្រី បុគ្គលិកប្រុស និងបុគ្គលិកស្រី<br>• បន្ទប់ទឹកគួរតែនៅជិតអាគារសិក្សា នៅទីតាំងដែលចំហ និងងាយមើលឃើញ<br>• មានទីតាំង ឬធុងសម្រាមសម្រាប់សម្រាមពាក់ព័ន្ធនឹងអនាម័យរាងកាយ<br>• មានទីតាំងនៅជិតបន្ទប់ទឹកដើម្បីប្តូរ និងសម្អាតសម្ភារពាក់ព័ន្ធនឹងអនាម័យស្ត្រី។ |
| ការត្រួតពិនិត្យតាមដាន និងជួសជុល | • ការត្រួតពិនិត្យយ៉ាងទៀងទាត់នូវលម្ហដែលកុមារងាយរងគ្រោះដោយសារអំពើហិង្សាផ្អែកយេនឌ័រដែលទាក់ទងនឹងសាលារៀន (ឧទាហរណ៍៖ នៅជិតបន្ទប់ទឹក នៅក្នុងបន្ទប់រៀន ឬផ្លូវដើរដែលមិនមានមនុស្ស បរិវេណរបងសាលា) ដោយបុគ្គលិកសន្តិសុខសាលារៀន គ្រូបង្រៀន បុគ្គលិកដែលមិនមានតួនាទីបង្រៀន និងសិស្សដែលកាន់វេនយាម (ក្រោមការដឹកនាំរបស់គ្រូ)<br>• ត្រួតពិនិត្យ និងជួសជុលយ៉ាងទៀងទាត់នូវអំពូល សម្ភារបន្ទប់ទឹក (ដែលរួមមានសោរ និងទ្វារ) និងសម្ភារដែលពាក់ព័ន្ធនឹងសន្តិសុខផ្សេងៗទៀត។ |
| ការធ្វើដំណើរ | • បង្កើនសុវត្ថិភាពតាមផ្លូវពីផ្ទះទៅសាលា និងត្រឡប់មកផ្ទះវិញ។ ឧទាហរណ៍ ដោយការបង្កើតផ្លូវសុវត្ថិភាពពីផ្ទះទៅសាលា និងសម្រាប់ត្រឡប់មកផ្ទះវិញដែលមានការយាមល្បាត ឬជម្រើសធ្វើដំណើររួមគ្នាដែលមានសុវត្ថិភាព។ |

រូបភាពទី៥៖ វិធីធានាចន្លោះសុវត្ថិភាពនៅក្នុងសាលារៀន

**សកម្មភាព៖ ការធ្វើផែនទីដែលមានការចូលរួមអំពីទីតាំងមិនមានសុវត្ថិភាព និងទម្រង់នៃអំពើហិង្សាដែលសិស្សជួបប្រទះនៅក្នុងសាលារៀន**

សិស្សអាចចូលរួមក្នុងសកម្មភាពធ្វើផែនទីទីតាំងមិនមានសុវត្ថិភាពនៅក្នុងសាលារៀន។ ឱ្យពួកគេពិនិត្យមើលទីតាំងផ្សេងៗនៅក្នុង និងជុំវិញបរិវេណសាលារៀន និងប្រាប់អ្នក (និងបុគ្គលិកផ្សេងទៀតដែលអាចទុកចិត្តបាន) ពីទីតាំងដែលពួកគេមានអារម្មណ៍ថាមានសុវត្ថិភាព និងមិនមានសុវត្ថិភាព និងមូលហេតុដែលពួកគេមានអារម្មណ៍បែបនេះ។

សូមធ្វើតាមជំហានបន្ទាប់ទៀតដូចខាងក្រោម៖

- ធ្វើកិច្ចការជាក្រុមដែលមានភេទតែមួយ ដើម្បីឱ្យមានអារម្មណ៍សុវត្ថិភាពក្នុងការពិភាក្សា
- ឱ្យក្មេងប្រុស និងក្មេងស្រីគូរផែនទីដែលបង្ហាញទីតាំងសំខាន់ៗនៅក្នុងសាលារៀនរបស់ពួកគេ (ដូចជាបន្ទប់រៀន ទីធ្លារត់លេង បន្ទប់ទឹក។ល។) ក៏ដូចជាផ្លូវទៅសាលារៀនរបស់ពួកគេ
- ក្រោយពីគូរផែនទីរួច ឱ្យសិស្សបិទចំណុចពណ៌បៃតងនៅលើទីតាំងដែលពួកគេគិតថាមានសុវត្ថិភាព និងចំណុចពណ៌ក្រហមនៅលើទីតាំងដែលពួកគេយល់ថាមិនមានសុវត្ថិភាព
- ពិភាក្សាជាមួយសិស្សអំពីមូលហេតុដែលពួកគេកំណត់ថាទីតាំងមួយមានសុវត្ថិភាព ឬមិនមានសុវត្ថិភាព។

បញ្ហាដែលសិស្សបានលើកឡើងនៅក្នុងដំណើរការគូរផែនទីដែលមានការចូលរួមបានផ្តល់ព័ត៌មានឱ្យអ្នកដឹងពីសកម្មភាពដែលត្រូវធ្វើជាអាទិភាព។

**៦.យន្តការបញ្ជូនគាំពារកុមារផ្លូវការ និងមិនផ្លូវការដែលមានសុវត្ថិភាព**

ពេលដែលកុមារក្លាយជាជនរងគ្រោះនៃការរំលោភបំពានធ្ងន់ធ្ងរ ឬការរំលោភបំពានដែលកើតឡើងជាប្រចាំ ចាំបាច់ត្រូវបញ្ជូនពួកគេទៅទទួលការគាំទ្រពីសេវាដែលមានជំនាញ។ សាលារៀនគប្បីមានប្រព័ន្ធសម្រាប់បញ្ជូនបន្តករណីទៅស្ថាប័នដែលមានឯកទេសខ្ពស់ជាងខ្លួននៅពេលដែលចាំបាច់។ គ្រូបង្រៀនអាចដើរតួនាទីជាចំណុចទំនាក់ទំនងដំបូងនៅក្នុងប្រព័ន្ធបញ្ជូនបន្តរបស់សាលារៀន។ សាលារៀនក៏គួរតែរៀបចំឱ្យមានសេវាផ្តល់ប្រឹក្សាផងដែរ ប៉ុន្តែអ្នកផ្តល់ប្រឹក្សាគប្បីទទួលបានវគ្គបំប៉ន និងជាបុគ្គលដែលសិស្សទុកចិត្ត។

ខណៈដែលគន្លងសម្រាប់បញ្ជូនដែលមានសុវត្ថិភាពត្រូវបានបង្កើតឡើងហើយ សិស្សចាំបាច់ត្រូវដឹងពីវិធីរាយការណ៍ពីអំពើហិង្សា និងបុគ្គលដែលពួកគេត្រូវទំនាក់ទំនង។ ជាការប្រសើរ គួរចែករំលែកប្រព័ន្ធបញ្ជូនឱ្យបានទូលំទូលាយទាំងនៅក្នុងសាលារៀន និងនៅក្នុងសហគមន៍ ដើម្បីឱ្យគ្រូ បុគ្គលិក

រដ្ឋបាល និងគ្រូសារសិស្ស និងសិស្សអាចរាយការណ៍ ឬឆ្លើយតបទៅនឹងបញ្ហាគាំពារកុមារដែលកើតមានឡើងនៅក្នុង និងជុំវិញបរិស្ថានសាលារៀន និងនៅផ្ទះរបស់សិស្ស។ សហគមន៍ក៏អាចដើរតួនាទីសំខាន់ដោយបដិសេធចំពោះសកម្មភាពហិង្សាដោយបុគ្គលដែលមានឥទ្ធិពល ដូចជាការប្រើទណ្ឌកម្មរបស់គ្រូលើរូបរាងកាយសិស្សជាដើម។

វត្តមានដំណើរការបញ្ជូន រាយការណ៍ និងដាក់ពិន័យដែលមានតម្លាភាពមានសារសំខាន់នៅក្នុងករណីធ្ងន់ធ្ងរនៃអំពើហិង្សាយេនឌ័រដែលទាក់ទងនឹងសាលារៀន ប៉ុន្តែសូម្បីតែចំពោះករណីហិង្សាដែលមិនសូវធ្ងន់ធ្ងរក៏ដោយ ក៏ចាំបាច់ត្រូវមាននិតិវិធីច្បាស់លាស់ និងមានតម្លាភាពដែរ។ ការធ្វើអន្តរាគមន៍នៅដំណាក់កាលដំបូងនៃអំពើហិង្សាយេនឌ័រទាក់ទងនឹងសាលារៀន ជានិច្ចកាលងាយស្រួលដោះស្រាយជាងករណីដែលបានប្រែក្លាយទៅជាអំពើហិង្សាធ្ងន់ធ្ងរ ឬករណីដែលបានកើតឡើងម្តងហើយម្តងទៀតជាយូរមកហើយ។

ក្នុងករណីអំពើហិង្សារវាងសិស្ស និងសិស្សដូចគ្នា ជាការប្រសើរ វិធានការណ៍ទប់ទល់ជាមួយអ្នកបង្កអំពើហិង្សាយេនឌ័រដែលទាក់ទងនឹងសាលារៀនគួរមានកំណត់យ៉ាងច្បាស់លាស់នៅក្នុងគោលនយោបាយរបស់សាលារៀន។ សូមយោងតាមគោលនយោបាយជាតិស្តីពីការការពារកុមារ និងគោលការណ៍របស់ក្រសួងអប់រំ យុវជន និងកីឡាដែលមានស្រាប់។ ប្រសិនបើមានចម្ងល់ សូមទំនាក់ទំនងជាមួយមន្ត្រីជាន់ខ្ពស់របស់ក្រសួង ដើម្បីស្នើសុំការជួយគាំទ្រដើម្បីបង្កើតគោលនយោបាយដែលមានភាពរឹងមាំ។

គប្បីយកចិត្តទុកដាក់ខ្ពស់ចំពោះយេនឌ័រនៅក្នុងគោលនយោបាយទាំងនេះ ឧទាហរណ៍ ដោយមានជំពូកមួយដែលផ្តោតទៅលើអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងជំពូកមួយដែលផ្តោតលើអំពើហិង្សា និងការបៀតបៀនផ្លូវភេទ។ ដ្យាក្រាម[17]នៅក្នុងទំព័របន្ទាប់បង្ហាញពីច្រកចូល និងគន្លងដែលត្រូវបញ្ជូន និងតាមដានជនរងគ្រោះ។

បន្ថែមលើវត្តមានគោលនយោបាយ និងយន្តការសម្រាប់បញ្ជូនជនរងគ្រោះ គណៈគ្រប់គ្រងសាលារៀនក៏ត្រូវបង្កើនការយល់ដឹង និងពង្រឹងភាពអង់អាចរបស់គ្រូបង្រៀនឱ្យហ៊ានឆ្លុះបញ្ចាំងការអនុវត្តរបស់ពួកគាត់ និងតាមដាន និងរាយការណ៍ពីអំពើហិង្សាផងដែរ។ គ្រូចាំបាច់ត្រូវមានសមត្ថភាពអាចកំណត់បានសញ្ញានៃការរំលោភបំពាន ភាពធ្វេសប្រហែស អំពើហិង្សា និងការកេងប្រវញ្ចនិងដឹងពីវិធានការដែលត្រូវអនុវត្តក្នុងករណីដែលមានអំពើហិង្សាកើតឡើង។

[17] Edström, J., Long, S. & Roelen, K. (2012). Pathways to protection – referral mechanisms and case management for vulnerable children in Eastern and Southern Africa. Brighton: Centre for Social Protection, Institute of Development Studies. Retrieved from www.ids.ac.uk/files/dmfile/Pathwaystoprotection_finalreport_Jun12.pdfGender




**រូបភាពទី៦៖ មធ្យោបាយបញ្ជូនបន្តនូវជនរងគ្រោះជាកុមារដោយសារអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ**

## IV. សេចក្តីសន្និដ្ឋាន

ក្នុងមេរៀននេះ យើងបានពិភាក្សាអំពីនិយមន័យអំពើហិង្សាយេនឌ័រដែលទាក់ទងនឹងសាលារៀន ថាគឺជាសកម្មភាព ឬការគំរាមកំហែងគ្រប់ទម្រង់នៃអំពើហិង្សាផ្លូវភេទ ផ្លូវកាយ ឬផ្លូវចិត្ត។ អំពើហិង្សាប្រភេទនេះកើតមានឡើងនៅក្នុង និងជុំវិញបរិវេណសាលារៀន ហើយវាកើតឡើងដោយសារបទដ្ឋាន និងផ្នត់គំនិតយេនឌ័រ និងត្រូវបានបង្កើនដោយការបែងចែកសិទ្ធិអំណាចមិនស្មើគ្នា។

គ្រប់ទម្រង់នៃអំពើហិង្សាយេនឌ័រជាការរំលោភសិទ្ធិកុមារ។ អំពើហិង្សាប្រភេទនេះមានផលប៉ះពាល់អវិជ្ជមានចំពោះសុខមាលភាព និងលទ្ធផលសិក្សារបស់ក្មេងស្រី និងក្មេងប្រុស។ អំពើហិង្សាយេនឌ័រដែលទាក់ទងនឹងសាលារៀនក៏បង្កផលប៉ះពាល់អវិជ្ជមានចំពោះការអភិវឌ្ឍផ្នែកសង្គមរបស់ពួកគេ និងបន្តឱ្យមានវិសមភាពនៃសិទ្ធិអំណាចរវាងស្ត្រី និងបុរស នៅកម្រិតទំនាក់ទំនងបុគ្គល និងនៅក្នុងសង្គមផងដែរ។

# ជំពូកទី២

# វិធីសាស្រ្តបង្រៀន និងរៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ  សម្រាប់គ្រូ

ជំពូកនេះផ្ដោតលើវិធីសាស្ត្របង្រៀន និងរៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ នៅក្នុងការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ។ ជំពូកនេះផ្ដោតលើវិធីដែលអ្នកអាចបញ្ចូលយេនឌ័រក្នុងដំណើរការរៀបចំ និងបង្រៀនមេរៀន ក្នុងដំណើរការវាយតម្លៃការយល់ដឹងរបស់សិស្ស និងដំណើរការកសាងសម្ភារឧបទេសជាដើម។ ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនបានសង្កត់ធ្ងន់លើភាពសំខាន់នៃគ្រូបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ។ យោងតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ចំណេះដឹងវិជ្ជាជីវៈទាមទារឱ្យគ្រូបង្រៀនម្នាក់ដឹងពីតម្រូវការរៀនសូត្ររបស់សិស្ស និងទំនាក់ទំនងរវាងតម្រូវការទាំងនេះទៅនឹងសមត្ថភាព ស្ថានភាពគ្រួសាររបស់សិស្ស និងឥរិយាបថរបស់ពួកគេចំពោះការសិក្សា។ លើសពីនេះទៅទៀត អ្នកចាំបាច់ត្រូវវាយតម្លៃតម្រូវការរបស់ពួកគេដោយផ្ដោតលើភាពឆ្លើយតបនឹងសមភាពយេនឌ័រ។

ក្រមសីលធម៌វិជ្ជាជីវៈបានលើកឡើងថាគ្រូបង្រៀនដែលមានប្រសិទ្ធភាពមិនរើសអើងចំពោះសិស្សដោយផ្អែកលើភេទ ឬលក្ខណៈសម្បត្តិណាមួយនោះទេ។ គ្រូបង្រៀនល្អម្នាក់ចាត់ទុកសិស្សរបស់គាត់ស្មើៗគ្នាដោយមិនលម្អៀង។

ដើម្បីអនុវត្តវិធីសាស្ត្របង្រៀន និងរៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ យើងវិភាគលំនាំបង្រៀននិងរៀនដូចខាងក្រោម៖

- ការរៀបចំកិច្ចតែងការ (មេរៀនទី១)
- សម្ភារបង្រៀន និងរៀន (មេរៀនទី២)
- ភាសា និងអន្តរកម្មនៅក្នុងថ្នាក់រៀន (មេរៀនទី៣)
- ការរៀបចំថ្នាក់រៀន (មេរៀនទី៤)
- វិន័យបែបវិជ្ជមាន (មេរៀនទី៥)
- ការវាយតម្លៃ (មេរៀនទី៦)




**រូបភាពទី៧៖ វិធីបង្រៀន និងរៀនឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការអនុវត្តជាក់ស្តែង**

នៅក្នុងមេរៀនទី៧ យើងបង្ហាញឧបករណ៍សម្រាប់ជួយអ្នកធ្វើការឆ្លុះបញ្ចាំងមួយដើម្បីឱ្យដឹងថាអ្នកមានកម្រិតឆ្លើយតបនឹងសមភាពយេនឌ័រដល់កម្រិតណាក្នុងនាមជាគ្រូបង្រៀន។ ការយល់ដឹងមួយនេះនឹងជួយអ្នកក្នុងការសម្រេចចិត្តថាតើផ្នែកណាមួយដែលអ្នកគួរពង្រឹងបន្ថែម និងផ្នែកនៅក្នុងសៀវភៅជំនួយដែលអ្នកអាចស្វែងរកព័ត៌មានទាំងនោះបាន។

## មេរៀនទី១

# ការធ្វើកិច្ចតែងការបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ

## I. សេចក្តីផ្តើម

កិច្ចតែងការបង្រៀន ដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាដំណើរការបង្រៀន និងរៀន ឱ្យមានភាពរលូន និងមានប្រសិទ្ធភាព។ ជាទូទៅគ្រូបង្រៀនត្រូវរៀបចំកិច្ចតែងការបង្រៀន ឱ្យបានល្អមុនពេលចាប់ផ្តើមបង្រៀន ដែលបរិយាយអំពីជំហាន វិធីសាស្ត្រ សកម្មភាព និង សម្ភារឧបទេស សម្រាប់បង្រៀន និងរៀន។ គ្រូបង្រៀនភាគច្រើនមានបំណិនក្នុងការរៀបចំកិច្ចតែងការបង្រៀន ប៉ុន្តែជាទូទៅ ពួកគាត់មិនទទួលបានវគ្គបំប៉នពីវិធីធ្វើឱ្យកិច្ចតែងការទាំងនោះឆ្លើយតបនឹងសមភាពយេនឌ័រទេ។ ផ្ទុយទៅវិញ ការរៀបចំកិច្ចតែងការបង្រៀនដែលឆ្លើយតបទៅនឹងសមភាពយេនឌ័រ គឺជាមធ្យោបាយដ៏សំខាន់ក្នុងការដោះស្រាយបញ្ហាវិសមភាពយេនឌ័រដែលមាននៅក្នុងថ្នាក់រៀន។ នៅក្នុងមេរៀននេះយើងនឹងបង្ហាញវិធីមួយចំនួនក្នុងការរៀបចំកិច្ចតែងការបង្រៀន ដែលឆ្លើយតបនឹងសមភាពយេនឌ័រ។

## II. វត្ថុបំណង

- ពិពណ៌នាបានពីកិច្ចតែងការបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ
- រៀបចំកិច្ចតែងការបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ
- បណ្តុះទម្លាប់ធ្វើកិច្ចតែងការបង្រៀនដែលបញ្ជ្រាបទស្សនៈយេនឌ័រ។

## III. ខ្លឹមសារ

### ១.កិច្ចតែងការបង្រៀន

គុណភាពនៃការបង្រៀនមេរៀនមួយអាស្រ័យលើការរៀបចំផែនការយ៉ាងម៉ត់ចត់ និងមានប្រសិទ្ធភាព។ ការរៀបចំកិច្ចតែងការរួមមានការសម្រេចចិត្តជាច្រើនដូចជាសម្ភារបង្រៀន និងរៀនដែលត្រូវប្រើ វិធីសាស្ត្របង្រៀន ខ្លឹមសារ សកម្មភាពបង្រៀន និងរៀន ភាសាដែលត្រូវប្រើ អន្តរកម្មរវាងសិស្ស និងគ្រូ ការរៀបចំថ្នាក់រៀន ការវាយតម្លៃកម្រិតយល់ដឹងរបស់សិស្ស។ល។ ទោះជាលោកគ្រូ អ្នកគ្រូភាគច្រើនអាចរៀបចំកិច្ចតែងការបង្រៀនបានល្អហើយក្តី ក៏គាត់ត្រូវការបំណិន និងឥរិយាបទពិសេសមួយចំនួនទើបអាចរៀបចំកិច្ចតែងការដែលឆ្លើយតបនឹងសមភាពយេនឌ័របានល្អ។

កិច្ចតែងការបង្រៀនដែលល្អត្រូវមានធាតុដូចខាងក្រោមនេះ៖

- វត្ថុបំណងជាក់លាក់ (វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា)

- រយៈពេល (៤៥ ទៅ ៥០ នាទីក្នុងមួយម៉ោងសិក្សា)
- សម្ភារឧបទ្ទេសសមស្របដែលឆ្លើយតបនិងសមភាពយេនឌ័រ
- លំនាំបង្រៀនៈ
    - ដំណើរការបង្រៀន និងរៀនទៅតាមជំហានទាំងប្រាំ (រដ្ឋបាលថ្នាក់ រំឭកមេរៀនចាស់ បង្រៀនខ្លឹមសារថ្មី ពង្រឹងចំណេះដឹង និងបណ្ដាំផ្ញើ)
    - សកម្មភាពគ្រូ
    - សកម្មភាពសិស្ស

## ២. កិច្ចតែងការបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ

កិច្ចតែងការដែលឆ្លើយតបនឹងសមភាពយេនឌ័រគិតដល់តម្រូវការពិសេសរបស់សិស្សទាំងអស់គ្នា ទាំងសិស្សស្រី និងសិស្សប្រុស ពេញមួយដំណើរការបង្រៀន និងរៀន។ ទោះបីជាខ្លឹមសារមេរៀន ជានិច្ចកាលត្រូវបានកំណត់ដោយកម្មវិធីសិក្សាក្ដី គ្រូបង្រៀនមានការទទួលខុសត្រូវធ្វើយ៉ាងណាឱ្យមេរៀនរបស់គាត់ឆ្លើយតបនឹងសមភាពយេនឌ័រ។ ដើម្បីបង្រៀនមេរៀនមួយឱ្យមានលក្ខណៈឆ្លើយតបនឹងសមភាពយេនឌ័របាន អ្នកគួរឆ្លុះបញ្ចាំងរកមើលធាតុមួយចំនួនខាងក្រោមពេលដែលអ្នករៀបចំកិច្ចតែងការបង្រៀនៈ

- របៀបដែលអ្នកនឹងបង្រៀនមេរៀននេះ ដោយគិតដល់សមាសភាពសិស្សនៅក្នុងថ្នាក់ ចំនួនសិស្សស្រី និងសិស្សប្រុស និងតម្រូវការជាក់លាក់របស់ពួកគេ
- បរិស្ថានសិក្សា ដោយរាប់បញ្ចូលទាំងការរៀបចំទីតាំងអង្គុយ
- សកម្មភាព និងសម្ភារបង្រៀន និងរៀនដែលចាំបាច់
- អន្តរកម្មរវាងសិស្ស និងគ្រូ រវាងសិស្ស និងសិស្ស ដោយគិតទាំងភាសាដែលពួកគេប្រើ
- ការវាយតម្លៃកម្រិតយល់ដឹងរបស់សិស្ស។

ចំណុចទាំងអស់ខាងលើនេះនឹងត្រូវបានសិក្សាលម្អិតនៅក្នុងជំពូកនេះផងដែរ។

ដើម្បីរៀបចំកិច្ចតែងការបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ គ្រូត្រូវៈ

- មានវត្ថុបំណងជាក់លាក់ៈ
    - កំណត់វត្ថុបំណងមេរៀនឱ្យបានច្បាស់លាស់ ដោយរំលេចអំពីលទ្ធផលរំពឹងទុករបស់សិស្សស្រី និងសិស្សប្រុសទាំងវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា
    - មេរៀនជាក់លាក់មួយចំនួនអាចឱ្យគ្រូសួរសំណួរអំពីតួនាទីយេនឌ័របានពេលគាត់បង្រៀន ឧទាហរណ៍មេរៀនដែលនិយាយអំពីអាជីពផ្សេងៗគ្នា ការទទួលខុសត្រូវ សមាជិកគ្រួសារ និងការងារផ្ទះរបស់ពួកគាត់

- ពេលរៀបចំកិច្ចតែងការមួយ គ្រូគួរគិតរកសំណួរបើកមួយចំនួនដែលបំផុសការគិតរបស់សិស្ស និងជំរុញឱ្យមានការកែប្រែតួនាទីយេនឌ័រពាក់ព័ន្ធនឹងខ្លឹមសារមេរៀនដូចជាៈ
  - តើមានប្អូនណាខ្លះដែលប៉ាជាអ្នកចម្អិនម្ហូប?
  - តើមានប្អូនណាខ្លះដែលជួយការងារឪពុកម្ដាយនៅក្នុងផ្ទះបាយ?
- អ្នកក៏អាចចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនដែលពាក់ព័ន្ធនឹងការផ្លាស់ប្ដូរផ្នត់គំនិតអំពីតួនាទីយេនឌ័រ ដូចជាៈ
  - អ្នកគ្រូៈ "ពេលខ្លះស្វាមីរបស់ខ្ញុំចូលផ្ទះបាយធ្វើម្ហូប គាត់ចេះធ្វើហាប្លុកត្រីបានឆ្ងាញ់ណាស់"។
  - លោកគ្រូៈ "ខ្ញុំចូលចិត្តចម្អិនម្ហូប។ កូនៗរបស់ខ្ញុំចូលចិត្តញ៉ាំហាប្លុកត្រីដែលខ្ញុំធ្វើណាស់"។
  - តើមានប្អូនណាចាំបានអ្នកគ្រូពេទ្យដែលយើងបានជួបនៅមណ្ឌលសុខភាព? តើគាត់ឈ្មោះអ្វី?
- អ្នកគួរត្រៀមឧទាហរណ៍ទាំងនេះជាមុន មុននឹងចូលទៅក្នុងថ្នាក់រៀន

• សម្ភារបង្រៀន និងរៀនៈ ពេលជ្រើសរើសសម្ភារឧបទ្ទេសមកប្រើ ត្រូវប្រាកដថាសម្ភារទាំងអស់នោះ ពិតជាបានឆ្លើយតបនឹងសមភាពយេនឌ័រ (សូមមើលមេរៀនទី២ នៅទំព័រទី៦៧)។ **ឧទាហរណ៍ៈ** ពិនិត្យមើលសៀវភៅសិក្សាគោល និងឯកសារផ្សេងៗថាតើមានបង្ហាញតួអង្គបុរស និងស្ត្រីជាអ្នកប្រាជ្ញ ឬអ្នកវិទ្យាសាស្ត្រល្បីៗដែរឬទេមុននឹងលើកយកមកបង្រៀន។ ឬស្វែងរកបុគ្គលគំរូសម្រាប់សិស្សស្រីក្នុងវិស័យដែលភាគច្រើនបុរសជាអ្នកធ្វើ! តើអ្នកស្គាល់ Sau Lan Wu ឬ Jane Goodall ឬទេ? បើអ្នកចាប់អារម្មណ៍ចង់ស្គាល់អ្នកវិទ្យាសាស្ត្រជាស្ត្រីសំខាន់ៗបន្ថែមទៀតសូមចូលទៅកាន់គេហទំព័រៈ https://www.globalcitizen.org/en/content/17-top-female-scientists-who-have-changed-the-worl/។

• លំនាំបង្រៀនៈ
  - ជ្រើសរើសវិធីសាស្ត្របង្រៀន និងរៀនដែលបង្កលក្ខណៈឱ្យសិស្សប្រុស សិស្សស្រី បានចូលរួមដោយសមធម៌នៅក្នុងការងារជាក្រុម ការសម្ដែងតួ កិច្ចពិភាក្សា និងការស្រាវជ្រាវ
  - បង្កលក្ខណៈឱ្យសិស្សទាំងអស់អាចចូលរួមរៀនសូត្រពេលបញ្ចូលការពិសោធន៍ទៅក្នុងកិច្ចតែងការបង្រៀន
  - ធានាថាសិស្សទាំងអស់មានឱកាសស្មើគ្នា ក្នុងតួនាទីជាអ្នកដឹកនាំក្រុម ឬធ្វើបទបង្ហាញផ្សេងៗ
  - ត្រៀមសកម្មភាពមួយចំនួនដែលសិស្សអាចធ្វើដោយខ្លួនឯងបាន (នៅក្នុងក្រុម)។ លើកទឹកចិត្តឱ្យបង្កើតក្រុមដែលមានចម្រុះភេទ និងជំរុញឱ្យមានអន្តរកម្មក្នុងអំឡុងពេលធ្វើសកម្មភាព។
  - ពេលគ្រូត្រៀមសកម្មភាព គប្បីចងចាំថាអ្នកចង់ឱ្យសិស្សដឹងថា សិស្សស្រី និងសិស្សប្រុសបុរស និងស្ត្រីអាចធ្វើការដូចគ្នាបាន។ អ្នកមិនចាំបាច់ត្រូវរៀបចំសកម្មភាពដាច់ដោយឡែកពី

គ្នាសម្រាប់សិស្សប្រុស និងសិស្សស្រីនោះទេ។ ដើម្បីឱ្យការពិតនេះកាន់តែរឹងមាំ គ្រូគួរកត់សម្គាល់ឧទាហរណ៍ផ្សេងៗពាក់ព័ន្ធនឹងសមភាពយេនឌ័រ រួចនិយាយឱ្យសិស្សស្តាប់ ដូចជា៖

  - "ការដែលឪពុករបស់ចន្ទណាចូលចិត្តចិតបន្លែគឺជារឿងមួយល្អណាស់"

- យ៉ាងណាមិញ គ្រូមិនគួរញ៉ាំងឱ្យសិស្សកើតមានការវិនិច្ឆ័យក្នុងអំឡុងពេលសន្ទនានេះដោយប្រើឃ្លាដូចខាងក្រោមនោះទេ៖
  - "ឪពុកដែលមិនចេះធ្វើម្ហូប មិនល្អទេ"។

## ៣.ការបង្រៀនមេរៀន

ក្នុងអំឡុងពេលបង្រៀន និងរៀន អ្នកអាចបង្កើតឱកាសដែលសិស្សអាចមានអន្តរកម្មរវាងគ្នាទៅវិញទៅមក។ គ្រូអាចប្រើវិធីសាស្ត្របង្រៀនមួយចំនួនដែលមានដូចជាកិច្ចការក្រុម ដែលលើកទឹកចិត្តឱ្យសិស្សគ្រប់គ្នាមានការចូលរួមស្មើៗគ្នា។ ពេលដែលសិស្សមានឱកាសធ្វើកិច្ចការជាមួយមិត្តរួមថ្នាក់របស់គេ ពួកគេនឹងបង្កើនបំណិនធ្វើអន្តរកម្មប្រកបដោយប្រសិទ្ធភាព និងភាពងាយស្រួលទាំងជាមួយមិត្តរួមថ្នាក់ដែលមានភេទដូចគ្នា និងខុសគ្នា។ ពួកគេនឹងត្រូវការបំណិនសង្គមទាំងនេះក្នុងជីវភាពរស់នៅរបស់ពួកគេនាពេលអនាគត នៅទីកន្លែងជាច្រើន (កន្លែងធ្វើការ សហគមន៍) ពួកគេនឹងត្រូវធ្វើការជាមួយទាំងបុរស និងស្ត្រី។

អ្នកអាចជួយរំឭកសិស្សម្តងហើយម្តងទៀតថា ពួកគេគ្រប់គ្នាមានលក្ខណៈពិសេស និងមានសមត្ថភាពដែលខុសៗគ្នារៀងខ្លួន ហើយចំណុចនេះសំខាន់សម្រាប់សុខមាលភាព ទំនុកចិត្តចំពោះខ្លួនឯង និងការអភិវឌ្ឍន៍របស់ពួកគេ។

ដើម្បីបង្កើតឱកាសឱ្យសិស្សមានអន្តរកម្មជាមួយមិត្តរួមថ្នាក់ក្នុងម៉ោងបង្រៀន គ្រូអាច៖

- លើកទឹកចិត្តសិស្សគ្រប់គ្នាឱ្យចូលរួម ដោយពិនិត្យមើលថាតើអ្នកបានផ្តល់ឱកាសស្មើៗគ្នាដល់សិស្សប្រុស និងសិស្សស្រីឆ្លើយសំណួរដែរឬទេ?
- លើកទឹកចិត្តសិស្សឱ្យចូលរួមដោយលាយបញ្ចូលគ្នារវាងសិស្សប្រុស និងសិស្សស្រី។ រៀបចំឱ្យពួកគេអង្គុយលាយឡំគ្នាក្នុងក្រុមនីមួយៗ។ បែងចែកសិស្សជាក្រុមតាមវិធីព្រាវ។ ឧទាហរណ៍៖ បែងចែកសិស្សដែលមាននាមត្រកូលចាប់ផ្តើមដោយស្រៈដាក់លាក់មួយនៅក្នុងក្រុមជាមួយគ្នា ហើយសិស្សដែលមានឈ្មោះចាប់ផ្តើមដោយព្យញ្ជនៈដាក់លាក់មួយនៅក្នុងក្រុមមួយទៀត ឬអាចបែងចែកក្រុមទៅតាមពណ៌ដែលពួកគេចូលចិត្តក៏បាន។
- កោតសរសើរ និងជួយសិស្សគ្រប់គ្នាឱ្យបានស្មើៗគ្នា

- ដាក់កិច្ចការសាលា ឬការងារបោសជូតថ្នាក់ (ដូចជាបោសជូតថ្នាក់ ឬរៀបចំកៅអី) ឱ្យសិស្សប្រុស និងសិស្សស្រីដូចៗគ្នា
- ប្រើវិធីសាស្ត្របង្រៀនមួយចំនួនដើម្បីរក្សាការចូលរួមរបស់សិស្សគ្រប់គ្នា
- ហៅសិស្សឱ្យនិយាយអំពីតួនាទីយេនឌ័រដែលពួកគេយល់ឃើញពីការពិភាក្សាគ្នា៖
  - "តើអ្នកយល់ថាឪពុកមួយចំនួនអាចចម្អិនម្ហូបបានទេ?"
  - "តើក្មេងស្រីអាចបើករថយន្តធំៗបានទេ?"
- វត្ថុបំណងគឺដើម្បីបើកការគិតរបស់សិស្សឱ្យធំទូលាយ មិនមែនដើម្បីបដិសេធការយល់ឃើញរបស់ពួកគេនោះទេ។

**សកម្មភាព ក៖ កិច្ចតែងការដែលឆ្លើយតបនឹងយេនឌ័រ**

ពិនិត្យមើលគំរូកិច្ចតែងការ (សូមមើលឧបសម្ព័ន្ធ ខ នៅទំព័រទី១១៤) ហើយកំណត់យ៉ាងហោចណាស់ ៥ចំណុចដែលជួយឱ្យកិច្ចតែងការនេះឆ្លើយតបនឹងសមភាពយេនឌ័រ។

**សកម្មភាព ខ៖ ការត្រៀមមេរៀន និងការបង្រៀនមេរៀន**

- សូមរៀបចំកិច្ចតែងការមេរៀនមួយដែលឆ្លើយតបនឹងសមភាពយេនឌ័រ សម្រាប់មេរៀនបន្ទាប់របស់អ្នក។ ឬប្រើកិច្ចតែងការមេរៀនចុងក្រោយដែលអ្នកបានរៀបចំ និងប្រែក្លាយកិច្ចតែងការនេះឱ្យឆ្លើយតបនឹងសមភាពយេនឌ័រ។
- ពិភាក្សាអំពីកិច្ចតែងការរបស់អ្នកជាមួយគ្រូបង្រៀនផ្សេងទៀតក្នុងសាលារៀនជាមួយគ្នាដើម្បីទទួលបានយោបល់ និងព័ត៌មានត្រឡប់។
- បង្រៀនមេរៀននេះ ហើយវាយតម្លៃប្រសិទ្ធភាពមេរៀនដោយផ្អែកលើទស្សនៈយេនឌ័រ។

## IV. សេចក្តីសន្និដ្ឋាន

កិច្ចតែងការបង្រៀន ដែលឆ្លើយតបនឹងសមភាពយេនឌ័រនឹងជួយឱ្យគ្រូបង្រៀនប្រើប្រាស់ដើម្បីសម្របសម្រួលសកម្មភាពបង្រៀន និងរៀនឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់សិស្សានុសិស្សទាំងអស់ដែលធ្វើឱ្យលទ្ធផលសិក្សារបស់ពួកគេ ទាំងសិស្សស្រី និងសិស្សប្រុសមានភាពល្អប្រសើរ។ ដូច្នេះគ្រូបង្រៀន ត្រូវយកចិត្តទុកដាក់រៀបចំកិច្ចតែងការបង្រៀនឱ្យបានគ្រប់មេរៀន ដោយបញ្ជ្រាបយេនឌ័រនៅក្នុងគ្រប់សកម្មភាពបង្រៀន និងរៀនទាំងអស់ ដើម្បីឱ្យសម្រេចបាននូវវត្ថុបំណងរួមរបស់មេរៀន ។

## មេរៀនទី២

# សម្ភារឧបទេសដែលឆ្លើយតបនឹងសមភាពយេនឌ័រ

## I. សេចក្តីផ្តើម

សម្ភារឧបទេសធ្វើឱ្យមានភាពទាក់ទាញដល់ការសិក្សារបស់សិស្ស និងធ្វើឱ្យពួកគេឆាប់យល់មេរៀន។ ប៉ុន្តែលោកគ្រូ អ្នកគ្រូត្រូវមានការប្រុងប្រយ័ត្នក្នុងការផលិត និងប្រើប្រាស់ សម្ភារឧបទេសទាំងនោះ ព្រោះថាវាក៏អាចជះឥទ្ធិពលអវិជ្ជមានដល់សិស្សានុសិស្សដែរ ប្រសិនបើវាមានភាពលម្អៀងយេនឌ័រ។ មេរៀននេះនឹងណែនាំដល់គ្រូបង្រៀនពីរបៀបដែលសម្ភារឧបទេសអាចកែប្រែ ឬធ្វើឱ្យខ្លឹមសារមេរៀនមួយក្នុងសៀវភៅសិក្សាគោលកាន់តែរឹងមាំ។

## II. វត្ថុបំណង

- ផលិតសម្ភារឧបទេសដើម្បីឆ្លើយតបនឹងសមភាពយេនឌ័រ
- ប្រើសម្ភារឧបទេសដែលមានស្រាប់តាមរបៀបដែលឆ្លើយតបនឹងសមភាពយេនឌ័រ
- កែប្រែផ្នត់គំនិតយេនឌ័រក្នុងសម្ភារបង្រៀន និងរៀនដែលមានស្រាប់។

## III. ខ្លឹមសារ

### ១. សម្ភារឧបទេសដែលឆ្លើយតបនឹងសមភាពយេនឌ័រ

សម្ភារឧបទេសរួមមានសៀវភៅសិក្សាគោល រូបភាព គំនូរ វីដេអូ។ល។ ដែលជួយដល់ដំណើរការបង្រៀន និងរៀន។ សម្ភារឧបទេសមួយចំនួនបានមកពីការផលិត ឬកែច្នៃដោយគ្រូបង្រៀន និងសិស្សស្របតាមខ្លឹមសារក្នុងសៀវភៅសិក្សាគោល។ មានវត្ថុធាតុដើមមួយចំនួន ដូចជា៖ ក្រដាសផ្ទាំងធំ កាតុងសំបកកេស ដបទឹកសុទ្ធ កំប៉ុង ក្រវិលកំប៉ុង បំពង់បឺត។ល។ ដែល លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សអាច យកទៅកែច្នៃទៅជាសម្ភារឧបទេសបាន ដោយមិនចាំបាច់ចំណាយថវិកា ឬចំណាយតិចតួច។

សម្ភារបង្រៀន និងរៀនដើរតួនាទីសំខាន់នៅក្នុងលំនាំបង្រៀន និងមានតួនាទីសំខាន់ផងដែរក្នុងការរៀបចំផ្នត់គំនិតរបស់កុមារ។ ប៉ុន្តែ តាមរយៈការពិនិត្យមើលសៀវភៅសិក្សា និងសម្ភារឧបទេសផ្សេងៗទៀតបានបង្ហាញថា សម្ភារទាំងនេះបានបង្ហាញដោយមិនដឹងខ្លួននូវតួនាទីយេនឌ័របែបប្រពៃណី ។

## ២.ផ្នត់គំនិតយេនឌ័រក្នុងសៀវភៅសិក្សាគោល

ជាញឹកញាប់ សៀវភៅសិក្សាគោលបញ្ជូនសារថាស្ត្រី និងក្មេងស្រីមានភាពទន់ខ្សោយ អសកម្ម និងស្តាប់បង្គាប់។ ពួកគាត់ច្រើនត្រូវបានបង្ហាញក្នុងតួនាទីធ្វើការងារផ្ទះ ការងារថែទាំ និងជួយគាំទ្រ។ ផ្ទុយទៅវិញ បុរសច្រើនត្រូវបានបង្ហាញថាមានកម្លាំងខ្លាំង មានទំនុកចិត្តខ្ពស់ មានប្រាជ្ញាវាងវៃ និងជាអ្នកដឹកនាំក្នុងសង្គមផងដែរ។ កាលពីឆ្នាំ១៩៩៧ សៀវភៅសិក្សារបស់កម្ពុជាត្រូវបានកែលម្អដើម្បីឱ្យមានភាពសមភាពយេនឌ័រៈ សៀវភៅសិក្សាគោលបច្ចុប្បន្នបង្ហាញចំនួនស្មើគ្នារវាងរូបភាពភេទស្រី និងភេទប្រុស ទោះជាស្ត្រី និងក្មេងស្រីនៅតែត្រូវបានបង្ហាញក្នុងតួនាទីយេនឌ័របែបប្រពៃណីដូចជាមេផ្ទះ និងមិនមែនជាអ្នកវិទ្យាសាស្ត្រ វេជ្ជបណ្ឌិត ឬអ្នកគណិតវិទូក៏ដោយ[18]។

កត្តាបុគ្គលិកលក្ខណៈដែលបង្ហាញនៅក្នុងសៀវភៅសិក្សាត្រូវគ្នានឹងការកំណត់របស់សង្គម និងប្រពៃណីពាក់ព័ន្ធនឹងឧត្តមភាព និងសិទ្ធិអំណាចរបស់ភេទប្រុស។ ជាលទ្ធផល សម្ភារបង្រៀន និងរៀនបានធ្វើឱ្យផ្នត់គំនិតមួយនេះកាន់តែរឹងមាំថែមទៀត។ ដោយមូលហេតុនេះហើយ ទើបគ្រូបង្រៀនចាំបាច់ត្រូវមានសមត្ថភាពអាចពិនិត្យមើលសៀវភៅសិក្សា និងសម្ភារឧបទេសផ្សេងៗទៀតដើម្បីរកមើលផ្នត់គំនិតយេនឌ័រដែលអាចកើតមាន។ គ្រូបង្រៀនក៏គួរតែអាចបង្កើត និងប្រើប្រាស់សម្ភារបង្រៀន និងរៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រផងដែរ។

ការស្រាវជ្រាវបានរកឃើញថាផ្នត់គំនិតយេនឌ័រត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយនៅក្នុងសៀវភៅសិក្សាគោលពាសពេញពិភពលោក។ បច្ចុប្បន្ននេះ មានការផ្តួចផ្តើមមួយចំនួនដែលពិនិត្យមើលសៀវភៅសិក្សាគោលដើម្បីរកមើលផ្នត់គំនិតយេនឌ័រមុននឹងដាក់ឱ្យប្រើប្រាស់។ ផ្ទុយទៅវិញ គ្រូបង្រៀនគប្បីពិនិត្យមើលផ្នត់គំនិតយេនឌ័រក្នុងសៀវភៅសិក្សាគោលដោយខ្លួនឯង ព្រោះនៅមានសៀវភៅសិក្សាគោលជាច្រើនដែលកំពុងប្រើប្រាស់ ហើយបង្កប់ទៅដោយផ្នត់គំនិតយេនឌ័រនៅក្នុងអត្ថបទ រឿងនិទាន និងរូបភាព។ ការពិនិត្យរកមើលជាមុនដើម្បីរកមើលផ្នត់គំនិតយេនឌ័រនៅក្នុងផ្ទាំងរូបភាព ឬសៀវភៅមួយអាចជួយឱ្យអ្នកសម្រេចចិត្តថាតើគួរប្រើសៀវភៅ ឬផ្ទាំងរូបភាពនេះឬអត់ ឬគួរប្រើដោយវិធីណាបាន។

បើពិនិត្យមើលផ្តើមចេញពីយេនឌ័រ មិនមានសៀវភៅរឿងនិទាន ឬសៀវភៅរូបភាពណាមួយដែលមិនល្អនោះទេ។ **គ្រប់សៀវភៅទាំងអស់ រួមទាំងសៀវភៅដែលមានផ្នត់គំនិតយេនឌ័រ សុទ្ធតែអាចផ្តល់ឱកាសឱ្យមានការជជែកពិភាក្សាជាមួយសិស្សអំពីតួនាទីយេនឌ័រទាំងអស់។** ឧទាហរណ៍ៈ អ្នកអាចឱ្យសិស្សពិនិត្យមើលរូបភាពនៅក្នុងសៀវភៅសិក្សា និងផ្តល់ឱកាសឱ្យគេប្រាប់ពីការយល់ឃើញរបស់ពួកគេចំពោះការប្រើរូបភាពទាំងនោះ។

[18] VVOB vzw (Ed.). (2019). Putting SDG4 into practice: Enhancing adolescent wellbeing, learning and opportunities (1st ed.). Brussels: VVOB vzw.

**វិធីពិនិត្យរកមើលផ្នត់គំនិតយេនឌ័រនៅក្នុងសៀវភៅ ឬផ្ទាំងរូបភាព**

គ្រូគួរយល់ដឹងពីកម្រិតឆ្លើយតបយេនឌ័រនៃសៀវភៅ ផ្ទាំងរូបភាព និងសម្ភារឧបទេសផ្សេងៗទៀត មុនពេលដែលគាត់ប្រើសម្ភារទាំងនោះជាមួយសិស្ស។ សូមអានរឿងនិទាន ពិនិត្យមើលចំណងជើង និងរូបភាព ហើយសួរខ្លួនឯងនូវសំណួរមួយចំនួនដូចខាងក្រោមៈ

១.ចំនួនដងនៃការបង្ហាញខ្លួនតួអង្គស្ត្រី និងតួអង្គបុរស

- តើមានតួអង្គស្ត្រី និងបុរសប៉ុន្មាននាក់ដែលត្រូវបានបង្ហាញ ឬរំឭកដល់ក្នុងអត្ថបទ និងរូបភាព?
- តើតួអង្គស្ត្រី និងបុរសត្រូវបានបង្ហាញប៉ុន្មានលើកនៅក្នុងសម្ភារបង្រៀន និងរៀន?

២.លក្ខណៈនៃការបង្ហាញតួអង្គស្ត្រី និងតួអង្គបុរស

- តើសកម្មភាពប្រភេទណា (មានផលិតភាពខ្ពស់/សហគមន៍) ដែលតួអង្គនីមួយៗពាក់ព័ន្ធជាមួយ?
- តើតួអង្គស្ត្រី និងបុរសត្រូវបានបង្ហាញយ៉ាងដូចម្តេច (អ្នកថែទាំ អ្នកផលិតផ្នែកសេដ្ឋកិច្ច មេដឹកនាំ ជនរងគ្រោះ។ល។)?
- តើចរិតបែបណាខ្លះ (ឆ្លាតវៃ ក្លាហាន កំសាក ទន់ភ្លន់។ល។) ដែលត្រូវបានភ្ជាប់ជាមួយតួអង្គស្ត្រី និងបុរស?
- តើតួនាទីក្នុងគ្រួសារត្រូវបានបែងចែកយ៉ាងដូចម្តេចរវាងតួអង្គស្ត្រី និងបុរស (មើលថែទាំកូន ជួយធ្វើកិច្ចការសាលារបស់កូន លេងជាមួយកូន បោសសម្អាតផ្ទះសម្បែង ចម្អិនអាហារ ជួសជុល។ល។)?
- តើក្មេងស្រី និងក្មេងប្រុសចូលរួមក្នុងសកម្មភាពជាក់លាក់អ្វីខ្លះ?

៣.រូបភាព

- តើទាំងស្ត្រី និងបុរសត្រូវបានបង្ហាញក្នុងរូបភាព/គំនូរយ៉ាងដូចម្តេច? តើរូបស្ត្រីត្រូវបានបង្ហាញយ៉ាងដូចម្តេចបើធៀបនឹងរូបបុរស ជាពិសេសទំហំរូប?
- តើរូបភាពទាំងនេះសមស្របនឹងវប្បធម៌ ហើយ/ឬឆ្លើយតបនឹងសមភាពយេនឌ័រឬទេ?
- តើរូបភាពបានបង្ហាញស្ត្រី និងបុរសក្នុងន័យវិជ្ជមាន ហើយបានចៀសវាងភាពលម្អៀងយេនឌ័រឬទេ?

៤.ទីកន្លែង

- តើសកម្មភាពនៅក្នុងរូបភាព/គំនូរនេះកើតមាននៅកន្លែងណា? តើជាទីកន្លែងសាធារណៈ ឬជាកន្លែងឯកជន?
- តើទីន្លែងណាខ្លះដែលបង្ហាញពីភាពសំខាន់? ហេតុអ្វី? តើស្ត្រី និងបុរសត្រូវបានបង្ហាញនៅទីកន្លែងទាំងនេះជាមួយគ្នាដែរឬទេ?
- តើទីតាំងរបស់មនុស្សម្នាក់ៗបានជះឥទ្ធិពលអ្វីខ្លះដល់ការទាក់ទាញចំណាប់អារម្មណ៍របស់ពួកគេ?

៥.លទ្ធផល

- តើសកម្មភាពដែលបុគ្គលម្នាក់ៗចូលរួមបានបញ្ជាក់អត្ថន័យអ្វីខ្លះពាក់ព័ន្ធនឹងឋានៈ ភាពសំខាន់ដែលកំណត់ដោយសង្គម និងការបង្ហាញអំពីទំនាក់ទំនងយេនឌ័រ? តើស្ត្រីនិងបុរសត្រូវបានបង្ហាញនៅលើមូលដ្ឋាន/ជំហរស្មើគ្នាឬទេ?

- តើតួអង្គស្ត្រីត្រូវបានបង្ហាញជាបុគ្គលតែមួយអង្គឯង ឬគ្រាន់តែបង្ហាញក្នុងទំនាក់ទំនងជាមួយតួអង្គបុរស?
- តើបញ្ហាអ្វីដែលលេចធ្លោ? សូមគិតអំពី៖ តួនាទីជាច្រើនរបស់ស្ត្រី/ក្មេងស្រី ស្ត្រីផ្តួចផ្តើមគំនិតដើម្បីគ្រប់គ្រងការរស់នៅរបស់ពួកគាត់ ស្ត្រី/ក្មេងស្រីចោទសួរអំពីស្ថានភាពការរស់នៅរបស់ពួកគាត់ អ្នកដឹកនាំជាស្ត្រី/ក្មេងស្រីក្នុងតួនាទីជាប្រធានថ្នាក់ ឬនាយិកាសាលារៀន ស្ត្រី/ក្មេងស្រីក្នុងតួនាទីជាដៃគូស្មើភាពជាមួយបុរស/ក្មេងប្រុស និងស្ត្រីក្នុងមុខរបរដែលមិនមានលក្ខណៈប្រពៃណី/ក្មេងស្រីក្នុងតួនាទីដែលមិនមានលក្ខណៈប្រពៃណី។
- តើខ្លឹមសារសមហេតុផលឬទេបើនិយាយអំពីតួនាទី និងការទទួលខុសត្រូវនៅក្នុងសហគមន៍របស់ស្ត្រី/បុរស ក្មេងស្រី/ក្មេងប្រុស?
- តើបុគ្គលគំរូប្រភេទណាដែលត្រូវបានបង្ហាញទៅទាំងក្មេងស្រី និងក្មេងប្រុស? តើអ្នកមានសង្កេតឃើញចំណុចខុសប្លែកគ្នាដែរឬទេ?

ដោយផ្អែកលើចម្លើយនៃសំណួរទាំងនេះ អ្នកអាចសម្រេចចិត្តថាតើអ្នកគួរប្រើសៀវភៅ ឬផ្ទាំងរូបភាពនេះឬទេ ឬប្រើដោយរបៀបណា។ គួរប្រុងប្រយ័ត្នពេលប្រើរូបភាពដែលយកពីទស្សនាវដ្តី ព្រោះជានិច្ចកាលរូបភាពទាំងនោះបង្ហាញរូបភាពបុរស ស្ត្រី ក្មេងស្រី និងក្មេងប្រុសតាមរបៀបដែលបង្កប់ទៅដោយផ្នត់គំនិត។

**របៀបកែប្រែផ្នត់គំនិតរបស់សិស្ស**

នៅពេលដែលសៀវភៅ ផ្ទាំងរូបភាព ឬរូបភាពមួយបញ្ជាក់ ឬកែប្រែផ្នត់គំនិត អ្នកអាចទាញការចាប់អារម្មណ៍របស់សិស្សឱ្យផ្តោតលើចំណុចទាំងនេះបាន។ អ្នកអាច៖

- លើកទឹកចិត្តសិស្សឱ្យកំណត់រកតួអង្គដែលបង្កប់ផ្នត់គំនិតយេនឌ័រនៅក្នុងសៀវភៅ ឬផ្ទាំងរូបភាពមួយ។ យ៉ាងណាមិញ សូមចងចាំថា មិនប្រាកដថាសិស្សរបស់អ្នកសុទ្ធតែអាចសម្គាល់ឃើញផ្នត់គំនិតយេនឌ័រ និងផលប៉ះពាល់ដែលផ្នត់គំនិតទាំងនោះមានលើតួអង្គនៅក្នុងសៀវភៅនោះទេ។ អ្នកអាចជួយពួកគេឱ្យយល់ដឹងដោយសួរសំណួរមួយចំនួនដូចខាងក្រោម៖
    - តើប្អូនៗមានសម្គាល់ឃើញអ្វីខុសគ្នារវាងក្មេងស្រី និងក្មេងប្រុសនៅក្នុងសៀវភៅនេះឬទេ?
    - តើនៅក្នុងរូបភាពនេះ ក្មេងស្រី និងក្មេងប្រុសកំពុងធ្វើអ្វី?
    - តើអ្នកចង់ធ្វើដូចនេះដែរឬទេ?
    - តើអ្នកយល់ឃើញយ៉ាងដូចម្តេចដែរចំពោះរូបភាពនេះ?
    - តើជាធម្មតាត្រូវតែបែបនេះមែនទេ?
    - តើស្ថានភាពកើតឡើងបែបនេះនៅក្នុងសាលារៀនរបស់យើងមែនទេ?
    - តើប្អូនបានឃើញស្ថានភាពបែបនេះញឹកញាប់ទេ?

- ភ្ជាប់ទំនាក់ទំនងរវាងតួអង្គនៅក្នុងសៀវភៅ ឬរូបភាពជាមួយមនុស្សគំរូក្នុងជីវភាពជាក់ស្តែង។ អ្នកអាចលើកឧទាហរណ៍ផ្សេងៗទៀតដោយខ្លួនឯង ឬហៅសិស្សឱ្យលើកឧទាហរណ៍៖
    - តើក្មេងស្រី/ក្មេងប្រុសអាចធ្វើបែបនេះបានទេ?
    - ហេតុអ្វីបានជាពួកគេអាចធ្វើបែបនេះបាន?
    - ហេតុអ្វីបានជាពួកគេមិនអាចធ្វើបែបនេះបាន?

ប្រសិនបើអ្នកមានឱកាសអាចផ្តល់ព័ត៌មានត្រឡប់ទៅឱ្យភាគីពាក់ព័ន្ធ (ឧទាហរណ៍៖ គ្រូឧទ្ទេស មន្ត្រីក្រសួងអប់រំ និងនាយិកា នាយកសាលា) ក្នុងដំណើរការកសាងសៀវភៅសិក្សាគោល អ្នកអាចដើរតួនាទីសំខាន់ក្នុងការលើកកម្ពស់ការយល់ដឹងអំពីការបង្កើតឱ្យមានផ្នត់គំនិតយេនឌ័រនៅក្នុងសៀវភៅសិក្សាគោលបាន។

**ករណីសិក្សា**

សកម្មភាព ក៖ សូមពិនិត្យមើលរូបភាពខាងក្រោម រួចឆ្លុះបញ្ចាំងដោយប្រើសំណួរនៅទំព័រទី៦៩ និង៧០

លំហាត់ទី១៖




**រូបភាពទី៨៖ សៀវភៅវិទ្យាសាស្រ្តថ្នាក់ទី៧ ទំព័រទី១២៨ បោះពុម្ពឆ្នាំ២០១៣**



រូបភាពទី៩៖ សៀវភៅសិក្សាសង្គម ថ្នាក់ទី៩ ទំព័រទី១៦២ បោះពុម្ពឆ្នាំ២០១៨

លំហាត់ទី២៖



រូបភាពទី១០៖ សៀវភៅសិក្សាគោលគណិតវិទ្យា ថ្នាក់ទី១ ទំព័រទី១១ បោះពុម្ពឆ្នាំ២០១៨

**សកម្មភាព ខ៖ វិភាគសៀវភៅសិក្សាគោលដើម្បីរកផ្នត់គំនិតយេនឌ័រ**

សូមជ្រើសរើសយកសៀវភៅសិក្សាគោលមួយដែលអ្នកកំពុងប្រើ ហើយវិភាគរកផ្នត់គំនិតយេនឌ័រ។ សូមប្រើសំណួរនៅទំព័រទី៦៩ និង៧០។

## IV. សេចក្តីសន្និដ្ឋាន

សម្ភារឧបទេសមានសារៈសំខាន់ក្នុងដំណើរការបង្រៀន និងរៀន និងបណ្តុះ ឬកែប្រែផ្នត់គំនិតយេនឌ័រដល់ក្មេងៗជំនាន់ក្រោយ។ លោកគ្រូ អ្នកគ្រូត្រូវចេះពិនិត្យមើលសៀវភៅសិក្សាគោល និងសម្ភារឧបទេសផ្សេងៗទៀតដើម្បីចៀសវាងបង្ហាញពីផ្នត់គំនិតយេនឌ័រ។ ម្យ៉ាងវិញទៀត លោកគ្រូ អ្នកគ្រូក៏អាចផលិតសម្ភារឧបទេសឱ្យឆ្លើយតបនឹងសមភាពយេនឌ័រដែលឆ្លុះបញ្ចាំងពីស្ថានភាព និងជីវភាពរស់នៅរបស់សិស្សានុសិស្សបានផងដែរ។

## មេរៀនទី៣

# ការប្រើប្រាស់ភាសា និងអន្តរកម្មដែលឆ្លើយតបនឹងសមភាពយេនឌ័រ

## I. សេចក្ដីផ្ដើម

ទង្វើ និងពាក្យសម្ដីរបស់លោកគ្រូ អ្នកគ្រូ និងមាតាបិតា ឬអ្នកអាណាព្យាបាលដើរតួនាទីយ៉ាងសំខាន់នៅក្នុងលំនាំទំនាក់ទំនងសង្គមរបស់កុមារ។ ពេលខ្លះលោកគ្រូ អ្នកគ្រូ និងមាតាបិតា ឬអ្នកអាណាព្យាបាលបានប្រើភាសាមួយចំនួនដែលបង្កប់ផ្នត់គំនិត ឬធ្វើទង្វើរើសអើងដោយមិនបានចាប់អារម្មណ៍ថាវាមាន លក្ខណៈលម្អៀង។ ក្នុងនាមជាគ្រូបង្រៀន និងមាតាបិតា ឬអ្នកអាណាព្យាបាលដែលគិតគូរអំពីសមភាពយេនឌ័រ មិនគួរប្រើភាសាដែលបង្កប់ផ្នត់គំនិតរើសអើងយេនឌ័រ ឬធ្វើទង្វើដែលមានការរើសអើងយេនឌ័រឡើយ។

មកដល់ចំណុចនេះ អ្នកបានរៀបចំកិច្ចតែងការដែលឆ្លើយតបនឹងសមភាពយេនឌ័រ (មេរៀនទី១) ហើយក៏បានពិនិត្យមើលភាពឆ្លើយតបនឹងយេនឌ័រនៅក្នុងសម្ភារបង្រៀន និងរៀនផងដែរ (មេរៀនទី២)។ ក្នុង មេរៀននេះ អ្នកនឹងសិក្សាពីវិធីបង្រៀនខ្លឹមសារមេរៀនដែលអ្នកបានរៀបចំតាមវិធីដែលឆ្លើយតបនឹងសមភាពយេនឌ័រវិញម្ដង។ នៅក្នុងផ្នែកខ្លឹមសារមេរៀន យើងនឹងពិភាក្សាពីការប្រើភាសា និងអន្តរកម្មដែលឆ្លើយតបនឹងសមភាពយេនឌ័រ។

## II. វត្ថុបំណង

- ពន្យល់បានពីការប្រើប្រាស់ភាសា និងអាកប្បកិរិយាផ្សេងៗដែលឆ្លើយតបនឹងសមភាពយេនឌ័រ
- ប្រើប្រាស់ភាសា និងធ្វើអាកប្បកិរិយាផ្សេងៗ ប្រកបដោយសមភាពយេនឌ័រ
- បណ្ដុះទម្លាប់ប្រើប្រាស់ភាសា និងទង្វើផ្សេងៗប្រកបដោយសមភាពយេនឌ័រ។

## III. ខ្លឹមសារ

### ១. ពិចារណាឡើងវិញអំពីស្ថានភាពសិស្សក្នុងថ្នាក់

ពាក់ព័ន្ធនឹងអំពើហិង្សា មានស្ថានភាពជាច្រើននៅក្នុងអន្តរកម្មក្នុងថ្នាក់រៀនដែលបានជះឥទ្ធិពលទៅលើលំនាំសកម្មភាពបង្រៀន និងរៀន។ ឧទាហរណ៍ រូបភាពខាងក្រៅរបស់គ្រូ និងសិស្ស (សម្លៀកបំពាក់ រូបរាងកាយ កាយវិការ ដំណើរ) អាកប្បកិរិយារបស់សិស្ស (ចូលចិត្តធ្វើបាបសិស្សផ្សេងទៀត ឆ្មើងឆ្មៃ អៀនប្រៀន ចូលចិត្តបង្អាប់អ្នកដទៃ) និងអាកប្បកិរិយារបស់គ្រូ (ចូលចិត្តប្រើពាក្យគំរោះគំរើយ និងអំពើហឹង្សា/គោរពសិទ្ធកុមារ/ឃើតយ៉ាវ/ទៀងទាត់ពេលវេលា/យកចិត្តទុកដាក់សិស្សស្មើៗគ្នា/លម្អៀង) ស្ថានភាពទាំងនេះជះឥទ្ធិពលលើជោគជ័យ ឬបរាជ័យនៃលំនាំបង្រៀន និងរៀន។ ស្ថានភាពទាំងនេះ

កាន់តែសំខាន់ទ្វេដង ពេលដែលអ្នកចង់ឱ្យអន្តរកម្មក្នុងថ្នាក់រៀនឆ្លើយតបនឹងសមភាពយេនឌ័រ។ នៅក្នុងមេរៀននេះ យើងនឹងពិភាក្សាអំពីស្ថានភាពនីមួយៗដូចខាងក្រោមៈ

- ការបង្រៀនរបស់គ្រូ (សមត្ថភាព ភាពពូកែ ចំណេះដឹងមុខវិជ្ជា ការបង្កើតថ្មី)ៈ សូមមើលផ្នែក១.១ នៅទំព័រទី៧៥
- អន្តរកម្មរវាងគ្រូ និងសិស្សៈ សូមមើលផ្នែក១.២ នៅទំព័រទី៧៦
- អន្តរកម្មរវាងសិស្ស និងសិស្សៈ សូមមើលផ្នែក១.៣ នៅទំព័រទី៧៩

### ១.១ ការបង្រៀនខ្លឹមសាររបស់គ្រូ

ខាងក្រោមនេះគឺជាវិធីសាស្ត្របង្រៀនមួយចំនួនដែលត្រូវបានប្រើញឹកញាប់ៈ

- វិធីដែលញ៉ាំងឱ្យសិស្សចូលរួមសកម្ម
- ការសម្ដែងតួ
- ការធ្វើបង្ហាញ
- ការពិភាក្សា
- វិធីធ្វើពិសោធន៍
- វិធីពណ៌នា
- វិធីឧទ្ទេស
- វិធីនិទានរឿង
- វិធីបង្រៀនតាមបែបរិះរក និងវិធីផ្សេងៗទៀត។

វិធីសាស្ត្រទាំងនេះមិនប្រាកដថាមានលក្ខណៈឆ្លើយតបនឹងយេនឌ័រនោះទេ។ អាស្រ័យហេតុនេះ តើគ្រូបង្រៀនអាចធ្វើឱ្យវិធីបង្រៀនទាំងនេះឆ្លើយតបនឹងសមភាពយេនឌ័រដោយរបៀបណា? យើងនឹងពិភាក្សាអំពីឧទាហរណ៍២ ដែលគេនិយមប្រើច្រើននៅកម្ពុជាៈ

| វិធីសាស្ត្រ | សកម្មភាពដែលឆ្លើយតបនឹងសមភាពយេនឌ័រ |
|---|---|
| វិធីសំណួរ និងចម្លើយ | • ផ្ដល់ឱកាសស្មើគ្នាឱ្យសិស្សប្រុស និងសិស្សស្រីឆ្លើយសំណួរ<br>• ផ្ដល់ការពង្រឹងបែបវិជ្ជមានដល់សិស្សប្រុសនិងសិស្សស្រី<br>• ផ្ដល់ពេលវេលាឆ្លើយសំណួរឱ្យបានគ្រប់គ្រាន់ដោយរាប់បញ្ចូលទាំងសិស្សស្រីដែលអៀនខ្មាស់ច្រើន ឬភ័យខ្លាចមិនហ៊ាននិយាយ<br>• ដាក់លំហាត់ដែលលើកទឹកចិត្តសិស្ស ជាពិសេសសិស្សស្រីឱ្យក្លាហានហ៊ាននិយាយ<br>• បែងចែកសំណួរឱ្យសិស្សគ្រប់គ្នាក្នុងថ្នាក់ ហើយធានាថាសិស្សគ្រប់គ្នាបានចូលរួមឆ្លើយ<br>• បង្កើតសំណួរដើម្បីដែលប្រើទាំងឈ្មោះបុរស និងស្ត្រី និងប្រើទាំងតួអង្គ |

| | |
|---|---|
| | បុរស និងស្ត្រី។ |
| ការពិភាក្សាក្រុម | • ធានាថាក្រុមនីមួយៗមានលាយឡំគ្នា (ទាំងសិស្សប្រុស និងសិស្សស្រី)<br>• ធានាថាសមាជិកក្រុមម្នាក់ៗមានឱកាសជជែក និងដឹកនាំការពិភាក្សា<br>• ធានាថាប្រធានក្រុមមានទាំងសិស្សប្រុស និងសិស្សស្រី<br>• លើកទឹកចិត្តទាំងសិស្សប្រុស និងសិស្សស្រីឱ្យឡើងបង្ហាញលទ្ធផលពិភាក្សា<br>• លើកទឹកចិត្តទាំងសិស្សប្រុស និងសិស្សស្រីឱ្យធ្វើជាអ្នកកត់ត្រាខ្លឹមសារការពិភាក្សា<br>• ធានាថាក្រុមនីមួយៗមានសមាសភាពសិស្សស្រី និងសិស្សប្រុសដែលមានសមត្ថភាពសិក្សាខុសៗគ្នា<br>• ធានាថាប្រធានបទពិភាក្សាក្នុងក្រុមនីមួយៗគិតដល់យេនឌ័រ ដោយរាប់បញ្ចូលទាំងវីរបុរស និងវីរនារីក្នុងមេរៀនប្រវត្តិវិទ្យា ទាំងបុរស និងស្ត្រីក្នុងការពិភាក្សាអំពីភាពជាអ្នកដឹកនាំ។ |

## ១.២ អន្តរកម្មរវាងគ្រូ និងសិស្ស

សិស្សស្រីប្រុស ម្នាក់ៗមានចរិត សមត្ថភាពសិក្សា ប្រវត្តិ និងក្តីសុបិនខុសៗគ្នារៀងៗខ្លួន។ ការស្វែងយល់ពីលក្ខណៈរបស់សិស្សម្នាក់ៗអាចជួយគ្រូក្នុងលំនាំបង្កើតទំនាក់ទំនងថ្នាក់រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ។ តាមរយៈការចំណាយពេលដើម្បីស្វែងយល់ពីសិស្សម្នាក់ៗក្នុងនាមជាបុគ្គលដែលមានលក្ខណៈខុសៗគ្នា គ្រូកាន់តែមានភាពល្អប្រសើរក្នុងការយកចិត្តទុកដាក់ប្រកបដោយការគិតពិចារណាពេញលេញចំពោះកិច្ចការរបស់សិស្ស។ នេះជាជំហានមួយចាំបាច់ឆ្ពោះទៅរកការបង្កើតទំនាក់ទំនងថ្នាក់រៀន និងគិតបញ្ចូលការយកចិត្តទុកដាក់ទៅលើផ្នែកមួយចំនួនខាងក្រោម៖

- ការដោះស្រាយតម្រូវការជាក់លាក់របស់សិស្ស
- ព័ត៌មានត្រឡប់
- ការកសាងទំនាក់ទំនងជាមួយសិស្ស
- ការរំខានដែលផ្អែកលើយេនឌ័រនៅក្នុងថ្នាក់រៀន។

### ១.២.១ ការដោះស្រាយតម្រូវការពិសេសរបស់សិស្ស

គ្រូក៏គួរកត់សម្គាល់ថា សិស្សមួយចំនួនរៀនយឺត មួយចំនួនមានទេពកោសល្យ ហើយសិស្សខ្លះរៀនពូកែលើផ្នែកជាក់លាក់ណាមួយជាងសិស្សផ្សេងៗទៀត។ ទោះជាយ៉ាងនេះក្តី គ្រូបង្រៀនចាំបាច់ត្រូវមើលឱ្យផុតសមត្ថភាពសិក្សារបស់សិស្ស។សូមពិនិត្យរកបុគ្គលិកលក្ខណៈមួយចំនួនដូចជាភាអៀនប្រៀនផ្ទើងផ្ទៃ ការរំខាន និងខ្វះទំនុកចិត្ត។ គប្បីចងចាំថា សិស្សមួយចំនួនមានប្រភពមកពីគ្រួសារដែលមានស្ថានភាពលំបាកដូចជាកុមារកំព្រា គ្រួសារផ្លាស់ទីលំនៅ ឬក្រីក្រខ្លាំង។

សូមពិនិត្យមើលតម្រូវការយេនឌ័រជាក់លាក់របស់សិស្សៈ សិស្សស្រីដែលមានបញ្ហាព្រោះពួកគេកំពុងមានវដ្តរដូវ។ សិស្សប្រុសដែលមានភាពអៀនខ្មាស់មិនហ៊ាននិយាយនៅក្នុងថ្នាក់ដោយសារសំឡេងរបស់គេបែក ឬសិស្សស្រីដែលខ្លាចមិនហ៊ាននិយាយដោយសារបញ្ហាវប្បធម៌របស់គេ។ សិស្សប្រុស ឬសិស្សស្រីមួយចំនួនអាចមានវិបត្តិដោយសារ ធ្លាប់ត្រូវបានរំលោភបំពាន ឬបៀតបៀនផ្លូវភេទ។

### ១.២.២ ការផ្តល់ព័ត៌មានត្រឡប់

អន្តរកម្មនៅក្នុងថ្នាក់រៀនគឺជាលំនាំទំនាក់ទំនង ពីរទិសដៅ ដែលរួមមានតួអង្គពីរ គឺគ្រូ និងសិស្ស។ គ្រូបង្រៀនមេរៀន ហើយរំពឹងថាសិស្សនឹងឆ្លើយតបមកគ្រូវិញ។ គ្រូចាំបាច់ត្រូវធានាថាសិស្សកំពុងទទួលបានចំណេះដឹង។ ហេតុនេះ គ្រូគួរបង្កើតបរិស្ថានមួយដែលគាត់អាចទទួលបានព័ត៌មានត្រឡប់ពីសិស្សវិញ ដើម្បីបញ្ជាក់ថាពួកគេពិតជាទទួលបានចំណេះដឹងពិតមែន។ គ្រូគប្បីលើកទឹកចិត្ត និងមានឆន្ទៈទទួលយកព័ត៌មានត្រឡប់ពីសិស្សដើម្បីកែលម្អលំនាំបង្រៀន និងរៀន។ ហេតុនេះ សូមបញ្ជាក់ជាមួយសិស្សឱ្យបានទៀងទាត់ ថាពួកគេយល់ខ្លឹមសារមេរៀន ឬនៅ។ គ្រូចាំបាច់ត្រូវជួយសិស្សឱ្យស្វែងយល់ថា ការមិនទាន់យល់មេរៀនគឺជារឿងមួយធម្មតាទេ ហេតុនេះចំណុចសំខាន់គឺពួកគេត្រូវសួរ។ ដើម្បីលើកទឹកចិត្តឱ្យសិស្សសួរសំណួរ គ្រូអាចដាក់កិច្ចការផ្ទះ ឬកិច្ចការក្នុងម៉ោងរៀនឱ្យសិស្សបង្កើតសំណួរបីពាក់ព័ន្ធនឹងខ្លឹមសារដែលគ្រូបានបង្រៀន។

បង្កើនការចូលរួមរបស់សិស្សដោយធានាថាទាំងសិស្សស្រី និងសិស្សប្រុសបានឆ្លើយសំណួរ។ គួរផ្តល់ពេលវេលាឱ្យសិស្សគ្រប់គ្រាន់ដើម្បីឆ្លើយសំណួរ ឬសួរ ហើយពុំគួរនិយាយកាត់ពួកគេពាក់កណ្តាលទីនោះទេ។ នេះមានន័យថាគ្រូត្រូវកសាង និងហ្វឹកហាត់ភាពអំណត់ និងបំណិនស្តាប់ឱ្យបានល្អ។ បំណិនទាំងអស់នេះសំខាន់ជាពិសេសពេលបង្រៀនសិស្សស្រីដែលត្រូវការពេលដើម្បីបង្ហាញការយល់ឃើញរបស់ពួកគេ ដោយសារពួកគេអាចមិនទម្លាប់ជជែកជាសាធារណៈ។

### ១.២.៣ ការកសាងទំនាក់ទំនងជាមួយសិស្ស

សិស្សអាចនឹងងាយស្រួលទទួលបានចំណេះដឹងក្នុងបរិស្ថានថ្នាក់រៀនដែលមានទំនាក់ទំនងល្អរវាងគ្រូ និងសិស្ស និងរវាងមិត្តរួមថ្នាក់។ យ៉ាងណាមិញ ការបង្កើតទំនាក់ទំនងរវាងគ្រូប្រុស និងសិស្សស្រីអាចជារឿងមួយលំបាក។ ជាទូទៅ វប្បធម៌តម្រូវឱ្យ រក្សាគម្លាតរវាងភេទប្រុស និងភេទស្រី។ ក្រមសីលធម៌ក្នុងវិស័យការងារ ទាមទារឱ្យមានការគោរពចំពោះគម្លាតមួយនេះ។ ដើម្បីចៀសវាងការយល់ច្រឡំ គ្រូបង្រៀនមួយចំនួនរក្សាឥរិយាបថសោះអង្កើយសូម្បីតែចំពោះអន្តរកម្មនៅក្នុងថ្នាក់រៀន។ បើស្ថានភាពនេះកើតមានឡើងដល់កម្រិតមួយធ្ងន់ធ្ងរ នឹងធ្វើឱ្យប៉ះពាល់ដល់លទ្ធផលសិក្សារបស់សិស្សប្រុស និងសិស្សស្រី។ ម្យ៉ាងវិញទៀត មានគ្រូបង្រៀនមួយចំនួនបានបំពានសេចក្តីទុកចិត្តដែលបានជាប់មកជាមួយតួនាទីរបស់គាត់ក្នុងនាមជាគ្រូបង្រៀនម្នាក់ ដូចមានករណីកើតឡើងជាច្រើនដែលគ្រូបានបៀតបៀន (ផ្លូវភេទ) ទៅលើសិស្ស។ ជាការងារដ៏ចាំបាច់ដែលត្រូវរកឱ្យឃើញចំណុចកណ្តាលមួយរវាងភាពសោះអង្កើយជ្រុល និងស្និទ្ធស្នាលជ្រុលដើម្បីបង្កើត និងថែរក្សាទំនាក់ទំនងចាំបាច់រវាងគ្រូ និងសិស្ស ទើបការរៀន និងបង្រៀនមានប្រសិទ្ធភាព។

### ១.២.៤ ការរំខានដែលផ្អែកលើយេនឌ័រនៅក្នុងថ្នាក់រៀន

អាកប្បកិរិយារបស់គ្រូ និងសិស្សដែលប៉ះពាល់ដល់យេនឌ័រអាចរំខានដល់ដំណើរការរៀន និងបង្រៀន។ មានឧទាហរណ៍ជាច្រើនដូចជា៖ សិស្សប្រុសធ្វើបាបសិស្សស្រី ក្មេងធំទាំងប្រុស ទាំងស្រីធ្វើបាបក្មេងដែលតូចជាង ការបង្អាប់ ការប្រើភាសា និងកាយវិការរំលោភបំពាន ការរំខានផ្លូវភេទ ការប៉ះពាល់ និងស្ទាបអង្អែល ការហុចសារផ្សេងៗ ការគូរគំនូរតាមជញ្ជាំងដែលមិនសមរម្យ។ល។ គ្រូបង្រៀនចាំបាច់ត្រូវរកវិធីបង្កលក្ខខណ្ឌអន្តរកម្មក្នុងថ្នាក់រៀនដែលអំណោយផលដល់ការរៀនសូត្រដោយលុបបំបាត់ចោលនូវអាកប្បកិរិយាមិនសមរម្យទាំងឡាយដូចបានរៀបរាប់ខាងលើ។

### សកម្មភាព៖ អន្តរកម្មរបស់គ្រូដែលឆ្លើយតបនឹងសមភាពយេនឌ័រ

សកម្មភាពទី១៖ ជូនកាល គ្រូពិបាកនឹងពិនិត្យមើលអន្តរកម្មរបស់ខ្លួនជាមួយសិស្សពេលកំពុងបង្រៀន។ ហេតុនេះហើយ ការសង្កេតរបស់ភាគីដទៃទៀតអាចជួយបាន។ ភាគីនោះអាចជាមិត្តរួមការងារដែលយកចិត្តទុកដាក់ចំពោះវិធីបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ ឬនាយក នាយិកាសាលាដែលអ្នកអាចពឹងឱ្យជួយសង្កេតការបង្រៀនរបស់អ្នក។ អ្នកសង្កេតអាចផ្តោតលើវិធីដែលអ្នកសម្គាល់លក្ខណៈខុសគ្នារៀងៗខ្លួនរបស់សិស្ស។

បើអ្នកមានឧបករណ៍ដែលអាចថតវីដេអូបាន (ទូរស័ព្ទចល័តក៏បាន) អ្នកអាចថតសកម្មភាពបង្រៀនរបស់ខ្លួន ហើយពិនិត្យមើលក្រោយបង្រៀនចប់ដើម្បីឆ្លុះបញ្ចាំងអន្តរកម្មរបស់ខ្លួន។

### ករណីសិក្សា

គ្រូបង្រៀនម្នាក់បានដាក់សំណួរ ហើយជ្រើសរើសសិស្សស្រីម្នាក់ឱ្យឆ្លើយ។ នៅពេល ដែលសិស្សស្រីនោះឆ្លើយខុស គ្រូបង្រៀននោះបានឆ្លើយតបដោយពោលពាក្យថា "អីក៏ ល្ងង់ម្ល៉េះ? ប្អូនឯងវែងតែសក់ តែគំនិតខ្លី"។

ពេលចេញពីរៀន មិត្តរួមថ្នាក់របស់គាត់បានចំអកឱ្យគាត់តាមពាក្យដែល លោកគ្រូប្រើ "សក់វែងតែគំនិតខ្លី" ដែលធ្វើឱ្យនាងមានអារម្មណ៍ខ្មាស់អៀនយ៉ាងខ្លាំង ហើយសម្រេចចិត្តឈប់រៀន។

### សំណួរឆ្លុះបញ្ចាំង

- ហេតុអ្វីបានជាសិស្សស្រីម្នាក់នេះមានអារម្មណ៍ថាខ្មាស់អៀន?
- ហេតុអ្វីបានជាគ្រូបង្រៀនប្រើពាក្យនេះជាមួយសិស្សរបស់គាត់ "អីក៏ល្ងង់ម្ល៉េះ សក់វែងតែគំនិតខ្លី"? តើអ្នកគិតថាការប្រើពាក្យសម្តីបែបនេះសមរម្យឬទេ?
- តើអ្នកនឹងធ្វើអ្វីខ្លះដើម្បីជួយសិស្សស្រីម្នាក់នេះ?
- តើអ្នកធ្លាប់ឮគ្រូបង្រៀនផ្សេងទៀតប្រើពាក្យសម្តីមិនសមរម្យដែលធ្វើឱ្យសិស្សខ្មាស់អៀនឬអាម៉ាស់មុខ នៅក្នុងថ្នាក់ដែរឬទេ?

- ចូរលើកឧទាហរណ៍អំពីពាក្យសម្ដី ឬភាសាមានលក្ខណៈលម្អៀងផ្នែកយេនឌ័រដែលមិត្តរួមការងាររបស់អ្នកធ្លាប់ប្រើ។
- តើសាលារៀនគួរធ្វើអ្វីខ្លះដើម្បីលុបបំបាត់ពាក្យសម្ដី ឬភាសារើសអើងយេនឌ័រ?

### ១.៣ អន្តរកម្មរវាងសិស្ស និងសិស្ស

សកម្មភាព៖ ការឆ្លើយតបនឹងសមភាពយេនឌ័រតាមរយៈការប្រើប្រាស់ភាសាក្នុងអន្តរកម្មនៅក្នុងថ្នាក់រៀន

សូមវិភាគការឆ្លើយតបនឹងសមភាពយេនឌ័រតាមរយៈការប្រើប្រាស់ភាសាក្នុងអន្តរកម្មនៅក្នុងថ្នាក់រៀនដោយធ្វើកិច្ចការខាងក្រោម៖

- សហការជាមួយសិស្សដើម្បីរកពាក្យសម្ដីដែលត្រូវប្រើដើម្បីបញ្ជាក់ពីក្មេងប្រុស និងក្មេងស្រី។ពិភាក្សាថាតើពាក្យសម្ដីទាំងនេះមានន័យវិជ្ជមាន ឬអវិជ្ជមាន ហើយថាតើពួកគេមានអារម្មណ៍បែបណានៅពេលដែលត្រូវបានគេហៅដោយប្រើពាក្យសម្ដីទាំងនោះ។
- សហការជាមួយសិស្សដើម្បីកំណត់រកភាសាទំនាក់ទំនងដោយមិនចាំបាច់និយាយរវាងសិស្ស និងសិស្ស និងរវាងសិស្ស និងគ្រូ។ ពិភាក្សាថាតើការប្រើភាសាទំនាក់ទំនងនេះវិជ្ជមាន ឬអវិជ្ជមាន ហើយមានផលប៉ះពាល់អ្វីខ្លះចំពោះក្មេងស្រី និងក្មេងប្រុស។

## ២.ពិចារណាឡើងវិញអំពីស្ថានភាពទំនាក់ទំនងជាមួយគ្រូផ្សេងទៀត និងមាតាបិតាសិស្ស

### ២.១ អន្តរកម្មរវាងគ្រូ និងគ្រូ

អ្នកចាំបាច់ត្រូវទទួលស្គាល់ថា ទោះជាអ្នកប្រឹងប្រែងយ៉ាងណា អ្នកមិនអាចផ្លាស់ប្ដូរស្ថានភាពឆ្លើយតបយេនឌ័រក្នុងសាលារៀនរបស់អ្នកតែម្នាក់ឯងបានទេ។ ការផ្លាស់ប្ដូរទម្លាប់ និងការរៀបចំនៅក្នុងសាលារៀនទាមទារសកម្មភាព និងការប្ដេជ្ញាចិត្តរបស់គ្រូបង្រៀនទាំងអស់ក្នុងសាលារៀននោះ ក្រោមការដឹកនាំរបស់គណៈគ្រប់គ្រងសាលា។ អ្នកនឹងទទួលបានខ្លឹមសារបន្ថែមទៀតពាក់ព័ន្ធនឹងចំណុចនេះនៅក្នុងសៀវភៅសម្រាប់គណៈគ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងសាលារៀន។

អន្តរកម្មរវាងអ្នក ជាមួយគ្រូបង្រៀនផ្សេងទៀតអាចនឹងបង្កើន ឬបន្ថយអាកប្បកិរិយាដែលបង្កើតផ្នត់គំនិតយេនឌ័របាន។ សូមកត់ចំណាំថា សិស្សរៀនសូត្រពីការសង្កេតមើលការប្រតិបត្តិរបស់អ្នកដទៃ។ អន្តរកម្មរវាង អ្នកជាមួយគ្រូបង្រៀនផ្សេងទៀតងាយឱ្យសិស្សសម្គាល់ និងចម្លងតាមណាស់[19]។ អាកប្បកិរិយាទាំងនេះរួមមានរបៀបដែលគ្រូហៅគ្នាទៅវិញទៅមក និងការប្រព្រឹត្តចំពោះគ្រូដែលមានភេទផ្ទុយគ្នា។ ទង្វើទាំងនេះធ្វើឱ្យសិស្សកើតមានការយល់ឃើញចំពោះតម្លៃនៃភេទប្រុស ឬភេទស្រី និងជះឥទ្ធិពលលើគំនិតរបស់ក្មេងអំពីតួនាទីរបស់បុរស និងស្ត្រីនៅក្នុងសាលារៀន ក៏ដូចជានៅក្នុងសង្គម។ អន្តរកម្មរវាងគ្រូប្រុស និងគ្រូស្រី នឹងជះឥទ្ធិពលលើទង្វើរវាងសិស្សប្រុស និងសិស្សស្រីផងដែរ។

[19] Bosow, S.A. (1992). Gender: Stereotypes and roles (3rd ed.). Belmont: Thomson Brooks/Cole Publishing Co.

យោបល់មួយចំនួនខាងក្រោមអាចជួយអ្នកក្នុងនាមជាគ្រូបង្រៀនម្នាក់បាន៖

- ការពិនិត្យមើលឡើងវិញលើទំនាក់ទំនងរបស់អ្នក ឬការពិភាក្សាផ្លាស់ប្តូរយោបល់ជាមួយមិត្តរួមការងារអាចជួយអ្នកបាន។ ធ្វើបែបនេះអាចជួយបង្កើនការយល់ដឹងរបស់អ្នកអំពីផ្នត់គំនិតដែលបង្កប់នៅក្នុងពាក្យសម្តី ឬរបៀបដែលអ្នកបាននិយាយ។ សូមពិចារណាអំពីអាកប្បកិរិយា ឬឥរិយាបថដែលធ្វើឱ្យផ្នត់គំនិតយេនឌ័របែបអវិជ្ជមានកើតមានកាន់តែច្រើន ហើយពិភាក្សារកដំណោះស្រាយជាមួយមិត្តរួមការងាររបស់អ្នក (ឧទាហរណ៍៖ ភាគច្រើន អ្នកគ្រូមានភារកិច្ចរៀបចំទឹកន្លែង និងអាហារសម្រន់ពេលប្រជុំផ្សេងៗនៅក្នុងសាលា)។
- ប្រើឱកាសប្រជុំគ្រូដើម្បីពន្យល់មិត្តរួមការងារ និងគណៈគ្រប់គ្រងសាលារៀនអំពីអត្ថប្រយោជន៍នៃវិធីបង្រៀនដែលឆ្លើយតបយេនឌ័រចំពោះការរីកចម្រើនរបស់សិស្ស។
- កំណត់បញ្ហាពាក់ព័ន្ធនឹងយេនឌ័រនៅក្នុងសាលារៀនដែលទាមទារឱ្យមានអន្តរាគមន៍របស់អ្នក។ អ្នកអាចពិភាក្សាអំពីបញ្ហាទាំងនេះជាមួយមិត្តរួមការងារ ហើយសហការគ្នាដោះស្រាយ។ ឧទាហរណ៍៖ តើសាលារៀនរបស់អ្នកមានបន្ទប់ទឹកដាច់ដោយឡែកសម្រាប់សិស្សស្រីឬទេ? តើមានផ្តល់សម្ភារបំពេញតម្រូវការសុខភាពពាក់ព័ន្ធនឹងរដូវរដូវឬទេ? តើសាលារៀនរបស់អ្នកមានបុគ្គលម្នាក់ដែលទទួលខុសត្រូវស្តាប់ពីកង្វល់ និងដោះស្រាយបណ្តឹងរបស់សិស្សដែរឬទេ?
- ពិភាក្សាជាមួយគ្រូបង្រៀនផ្សេងទៀតអំពីសារសំខាន់នៃការធ្វើជាគំរូនៅក្នុងថ្នាក់រៀន ក៏ដូចជាតាមរយៈអន្តរកម្មរវាងគ្រូ និងគ្រូ។
- បញ្ចុះបញ្ចូលដើម្បីទាមទារឱ្យមានការកសាងសមត្ថភាពនៅកម្រិតសាលារៀនអំពីការឆ្លើយតបនឹងសមភាពយេនឌ័រដើម្បីឱ្យគ្រូទាំងអស់អនុវត្តសកម្មភាពឆ្លើយតបនឹងសមភាពយេនឌ័រក្នុងលំនាំបង្រៀន និងរៀន។
- ស្វែងរកការគាំទ្រពីគណៈគ្រប់គ្រងសាលារៀនដើម្បីបញ្ចូលវិធីបង្រៀនដែលឆ្លើយតបនឹងយេនឌ័រជាផ្នែកមួយនៃប្រព័ន្ធរបស់សាលារៀន។

## ២.២ អន្តរកម្មរវាងគ្រូ និងមាតាបិតាសិស្ស

ជានិច្ចកាល មាតាបិតា និងអ្នកមើលថែក្មេងបានចម្លងបន្តនូវជំនឿ និងអាកប្បកិរិយារបស់ពួកគាត់អំពីតួនាទីយេនឌ័រទៅកូនៗរបស់ពួកគាត់ដោយមិនដឹងខ្លួន។ ចាប់តាំងពីពេលដែលពួកគេចាប់កំណើត ក្មេងប្រុសត្រូវបានឪពុកម្តាយយកចិត្តទុកដាក់ខុសគ្នាពីក្មេងស្រី។ ឧទាហរណ៍ដែលច្រើនតែកើតមានដូចជា៖ ក្មេងស្រីច្រើនតែស្លៀកពាក់សម្លៀកបំពាក់ដែលមានពណ៌ជាក់លាក់សម្រាប់ភេទរបស់គេ ដូចជាពណ៌ផ្កាឈូក និងពណ៌ស្វាយ ហើយទទួលបានរបស់លេងដែលលើកទឹកចិត្តពួកគេឱ្យរៀនស្លូតត្រចេះមើលថែអ្នកដទៃដូចជាកូនតុក្កតាជាដើម។ ក្មេងប្រុសលេងរបស់លេងដែលជំរុញការគិតពិចារណាស៊ីជម្រៅដូចជាឡាន និងឧបករណ៍សម្រាប់រៀបសង់ផ្ទះជាដើម[20]។ ក្មេងស្រីត្រូវបានបង្រៀនឱ្យចេះស្តាប់បង្គាប់ រីឯក្មេងប្រុសត្រូវបានបង្រៀនឱ្យមានភាពរឹងមាំ។ ជួនកាល ក្មេងស្រីត្រូវបានមើលថែការពារជ្រុល

[20] Martin, C.L., Wood, C., & Little, J.K. (1990). The Development of gender stereotype components. Child development, 61/6, 1891–1904.

ហួសហេតុ និងចាត់ទុកថាពួកគេទន់ជ្រាយងាយរងគ្រោះ រហូតដល់សូម្បីតែសិស្សប្រុសក៏មានអារម្មណ៍ថាពួកគេត្រូវការពារបងប្អូនស្រីរបស់ពួកគេពីការប៉ះពាល់ផ្សេងៗផងដែរ។ ផ្ទុយទៅវិញ ក្មេងប្រុសមិនអាចសម្រក់ទឹកភ្នែកបានទេ ព្រោះទង្វើនេះបង្ហាញថាពួកគេទន់ខ្សោយ។

ឪពុកម្តាយអាចនឹងបង្កើនផ្នត់គំនិតយេនឌ័រតាមរយៈរបៀបដែលគាត់ដាក់កិច្ចការផ្ទះឱ្យកូនប្រុស និងកូនស្រីធ្វើ។ ជានិច្ចកាល គេរំពឹងថាក្មេងស្រីធ្វើកិច្ចការផ្ទះទាំងអស់ដូចជាការសម្អាត បោសជូត ចម្អិនអាហារ និងការងារបោកគក់ ហើយក្មេងប្រុសធ្វើ "ការងារមនុស្សប្រុស" នៅខាងក្រៅផ្ទះ។

ដើម្បីដោះស្រាយបញ្ហាផ្នត់គំនិត និងភាពលម្អៀងយេនឌ័រដែលកើតមាននៅក្នុងផ្ទះ និងសហគមន៍របស់សិស្ស សូមសហការយ៉ាងជិតស្និទ្ធ និងប្រកបដោយការគោរពចំពោះឪពុកម្តាយ និងអ្នកមើលថែពួកគេ៖

- ការឆ្លុះបញ្ចាំងអំពីការអនុវត្តបែបវប្បធម៌ បទដ្ឋាន និងជំនឿនៅក្នុងមូលដ្ឋានដែលបង្កើនផ្នត់គំនិតយេនឌ័រជាកិច្ចការមួយដ៏មានប្រយោជន៍។ ចំណុចទាំងអស់ខាងលើនេះអាចចម្លងបន្តពីឪពុកម្តាយ ឬអ្នកមើលថែទាំទៅឱ្យកូនៗរបស់ពួកគាត់។ សូមគិតអំពីដំណោះស្រាយចំពោះបញ្ហានេះតាមរយៈអន្តរកម្មរវាងគ្រូ ជាមួយមាតាបិតាសិស្ស។
- ពេលសិស្សបង្ហាញអាកប្បកិរិយារើសអើងយេនឌ័រ សូមព្យាយាមស្វែងយល់បន្ថែមទៀតអំពីស្ថានភាពគ្រួសាររបស់ពួកគេ និងមូលហេតុដែលញ៉ាំងឱ្យពួកគេមានអាកប្បកិរិយាបែបនេះ។ បន្ទាប់មកជួបជជែកជាមួយមាតាបិតា ឬអ្នកមើលថែទាំរបស់សិស្សដើម្បីពិភាក្សាអំពីអត្ថប្រយោជន៍នៃការផ្តល់ឱកាសស្មើៗគ្នា និងស្នើសុំការគាំទ្ររបស់ពួកគាត់។ ជាការប្រសើរ បើអ្នកអាចសហការជាមួយគ្រូផ្សេងទៀត និងគណៈគ្រប់គ្រងសាលារៀនពេលជជែកជាមួយមាតាបិតាសិស្ស។
- សូមចងចាំថាការគោរពគ្នាទៅវិញទៅមកគឺជាចំណុចស្នូលដើម្បីទទួលបានការគាំទ្រពីឪពុកម្តាយសិស្ស។
- ដោយសារឪពុកម្តាយ និងអ្នកមើលថែទាំដើរតួនាទីសំខាន់ក្នុងការកំណត់តួនាទីយេនឌ័ររបស់សិស្ស សូមពិភាក្សាអំពីចំណុចនេះនៅពេលដែលអ្នក ជួបប្រជុំជាមួយមាតាបិតាសិស្សទាំងអស់គ្នា។ សូមលើកទឹកចិត្តឱ្យមាតាបិតា និងអ្នកមើលថែទាំសិស្សចូលរួមជាមួយអ្នកក្នុងការលើកកម្ពស់ទំនាក់ទំនងយេនឌ័របែបវិជ្ជមានរវាងក្មេងប្រុស និងក្មេងស្រី។ លើកទឹកចិត្តឪពុកម្តាយឱ្យអនុញ្ញាតឱ្យកូនៗរបស់ពួកគាត់មានក្តីសុបិនដែលឈានហួសតួនាទីយេនឌ័រ ឧទាហរណ៍៖ ដោយស្នើថាក្មេងស្រីអាចមានក្តីសុបិនក្លាយជាវេជ្ជបណ្ឌិត ឬវិស្វករមួយរូប។ ការបង្ហាញពីទិន្នន័យមួយចំនួនអំពីឥទ្ធិពលនៃការរើសអើងយេនឌ័រអាចជាវត្ថុភ្ជាចដ៏មានប្រសិទ្ធភាពសម្រាប់អ្នកខ្លួនឯងផ្ទាល់ ក៏ដូចជាសម្រាប់មាតាបិតាសិស្សផងដែរ។

អ្នកអាចទទួលបានព័ត៌មានបន្ថែមទៀតអំពីការចូលរួមរបស់មាតាបិតា និងសហគមន៍នៅក្នុងសៀវភៅសម្រាប់គណៈគ្រប់គ្រងសាលារៀន។

## IV. សេចក្តីសន្និដ្ឋាន

ដំបូង មេរៀននេះពិនិត្យមើលការប្រើប្រាស់ភាសា អន្តរកម្មរវាងសិស្ស និងសិស្ស អន្តរកម្មរវាងសិស្ស និងគ្រូ និងខ្លឹមសារមេរៀនដែលគ្រូបង្រៀន។ បន្ទាប់មក មេរៀននេះក៏បានពិនិត្យមើលផងដែរនូវអន្តរកម្មរវាងគ្រូ និងគ្រូ និងអន្តរកម្មរវាងគ្រូ និងមាតាបិតា អាណាព្យាបាល ឬអ្នកមើលថែទាំសិស្ស។ ការពិនិត្យមើលអន្តរកម្មទាំងនេះសំខាន់ដោយសារសិស្សសង្កេតមើលអន្តរកម្មរវាងមនុស្សពេញវ័យ។ អ្វីដែលពួកគេមើលឃើញ និងស្តាប់ឮពីអន្តរកម្មទាំងនេះនឹងជះឥទ្ធិពលលើការយល់ឃើញរបស់គេចំពោះពិភពលោក និងចំពោះខ្លួនឯង។

អន្តរកម្មរបស់សិស្សបានពង្រីកទៅកាន់តែធំទូលាយ ក្នុងសហគមន៍សាលារៀន និងបរិស្ថានគ្រួសាររបស់សិស្សផងដែរ។

# មេរៀនទី៤

## ការរៀបចំថ្នាក់រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ

### I. សេចក្តីផ្តើម

ការរៀបចំថ្នាក់រៀនជាចំណេះដឹងមូលដ្ឋានដ៏ចាំបាច់ ដែលលោកគ្រូ អ្នកគ្រូត្រូវមាន ដើម្បីបង្កើតបរិយាកាសក្នុងថ្នាក់រៀនឱ្យមានភាពទាក់ទាញសម្រាប់អ្នកសិក្សាទាំងឡាយ ដោយមិនប្រកាន់ពីភេទ ពណ៌សម្បុរ ជាតិសាសន៍ ឋានៈ ពិការភាព ជាដើម។ មេរៀននេះផ្តោតលើការរៀបចំថ្នាក់រៀនមួយដែលឆ្លើយតបនឹងសមភាពយេនឌ័រដែលគ្រូបង្រៀនត្រូវយល់ដឹង និងអនុវត្តដើម្បីឆ្លើយតបតម្រូវការជាក់ស្តែងរបស់សិស្សប្រុស និងសិស្សស្រី ជាថ្នាក់រៀនមួយដែលគ្មានភាពលំអៀងយេនឌ័រ និងការរើសអើង ។

### II. គោលបំណង

- ពន្យល់បានពីការរៀបចំ និងតុបតែងថ្នាក់រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ
- មានបំណិនរៀបចំ និងតុបតែងថ្នាក់រៀនឱ្យឆ្លើយតបនឹងសមភាពយេនឌ័រ
- បណ្តុះទំលាប់រៀបចំថ្នាក់រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ។

### III. ខ្លឹមសារ

#### ១. ថ្នាក់រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ

ការរៀបចំថ្នាក់រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ គឺជាការបង្កើតបរិយាកាសថ្នាក់រៀនដើម្បីបំពេញតម្រូវការជាក់លាក់របស់សិស្សប្រុស និងសិស្សស្រី។ ថ្នាក់រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រអាចឆ្លុះបញ្ចាំងពីអត្តសញ្ញាណយេនឌ័រ និងអន្តរកម្មរវាងគ្រូ និងសិស្ស ដោយមិនប្រកាន់ភេទ។ ដូច្នេះការរៀបចំថ្នាក់រៀន ត្រូវផ្តោតទៅលើការរៀបចំកន្លែងអង្គុយ ការតុបតែង សម្ភារបង្រៀន និងរៀន រូបភាព ពាក្យស្លោក និងសម្ភារៈផ្សេងៗ ដែលបង្កលក្ខណៈឱ្យសិស្សអាចចូលរួមគ្រប់សកម្មភាពដោយស្មើភាពគ្នា។ ថ្នាក់រៀនជាទូទៅមានតម្រៀបជាជួរនៅទល់មុខគ្រូ និងក្តារខៀន ដែលសមស្របនឹងតម្រូវការនៃមេរៀនមួយចំនួន ប៉ុន្តែមិនសូវលើកទឹកចិត្តឱ្យអ្នករៀនទាំងអស់ចូលរួមដោយស្មើភាពគ្នានោះទេ ព្រោះកុមារដែលអង្គុយនៅខាងក្រោយ ឬនៅជ្រុងថ្នាក់រៀនចូលរួមបានតិចតួច។ ដោយមូលហេតុនេះ ការរៀបចំបែបនេះមិនបានចូលរួមលើកកម្ពស់សមភាពយេនឌ័រនៅក្នុងបរិយាកាសនៃថ្នាក់រៀនទេ។ ដូចនេះការរៀបចំថ្នាក់រៀន ចាំបាច់ណាស់ដើម្បីធានាថាក្មេងស្រី និងក្មេងប្រុសទទួលបានការយកចិត្តទុកដាក់ស្មើគ្នានៅក្នុងថ្នាក់រៀនមួយ[21]។

[21] https://www.irex.org/sites/default/files/node/resource/creating-supportive-learning-environments-girls-boys_2.pdf

## ២. ការរៀបចំថ្នាក់រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ

មានសាលារៀនជាច្រើនដែលមិនមានហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារឹមគ្រប់គ្រាន់ និងសមរម្យនៅឡើយ។ កង្វះខាតនេះបានធ្វើឱ្យគ្រូបង្រៀនមិនអាចរៀបចំថ្នាក់រៀនសម្រាប់ការរៀនសូត្រយ៉ាងមានប្រសិទ្ធភាពបានទេ។ ថ្នាក់រៀនដែលមានចំនួនសិស្សច្រើនពេកធ្វើឱ្យគ្រូពិបាករៀបចំទីតាំងអង្គុយដែលបង្កលក្ខណៈងាយស្រួលដល់ការរៀនសូត្របែបសិស្សមជ្ឈមណ្ឌលបាន។ លើសពីនេះទៅទៀត គ្រូបង្រៀនប្រហែលជាមិនមានសិទ្ធិអំណាចក្នុងការទាមទារប្រភេទសម្ភារឹមតាមតម្រូវការរបស់ពួកគាត់នោះទេ។ ទោះបីជាមានភាពមិនពេញលេញបែបនេះក្តី គ្រូបង្រៀនម្នាក់ដែលមានគំនិតបង្កើតថ្មីគួរតែអាចរៀបចំថ្នាក់រៀនមួយដែលអំណោយផលដល់ការរៀនសូត្របាន។

យ៉ាងណាមិញ ការរៀបចំថ្នាក់រៀនគប្បីឈានទៅមុខមួយជំហានទៀត ហើយយកចិត្តទុកដាក់ចំពោះភាពឆ្លើយតបទៅនឹងសមភាពយេនឌ័រតាមរយៈការរៀបចំថ្នាក់រៀន។ ដូចបានរៀបរាប់ខាងលើ មានក្មេងស្រីមួយចំនួនដែលមិនសូវហ៊ាននិយាយស្តីនោះទេ។ ការរៀបចំទីតាំងអង្គុយដែលដាក់ពួកគេនៅជួរខាងក្រោយ ឬនៅជ្រុងបន្ទប់រៀនធ្វើឱ្យពួកគេកាន់តែមិនហ៊ាននិយាយស្តីជាងមុនទៅទៀត ដែលបណ្តាលឱ្យលទ្ធផលសិក្សារបស់ពួកគេធ្លាក់ចុះ។ អាស្រ័យហេតុនេះ ទម្រង់ទីតាំងអង្គុយតាមទម្លាប់ដែលតុត្រូវបានរៀបចំយ៉ាងមានរបៀប បែរមុខទៅរកគ្រូ មិនបានលើកទឹកចិត្តការរៀនសូត្រតាមបែបសិស្សមជ្ឈមណ្ឌលដែលសមស្របសម្រាប់បង្កើនការចូលរួមសកម្មរបស់សិស្ស ជាពិសេសសិស្សស្រីនោះទេ។

ការរៀបចំថ្នាក់រៀនមួយដែលឆ្លើយតបនឹងសមភាពយេនឌ័របំពេញតាមតម្រូវការជាក់លាក់ទាំងរបស់ក្មេងប្រុស និងក្មេងស្រី។ ការងារនេះយកចិត្តទុកដាក់ចំពោះចំណុចមួយចំនួនដូចខាងក្រោម៖

- ការរៀបចំថ្នាក់រៀនដែលមានលាយឡំគ្នាទាំងសិស្សប្រុស និងសិស្សស្រី
- ការរៀបចំថ្នាក់រៀនដែលបង្កើនការចូលរួមទាំងសិស្សស្រី និងសិស្សប្រុស
- ការរៀបចំទីតាំងតុដែលលើកទឹកចិត្តសិស្សស្រីឱ្យហ៊ានបញ្ចេញមតិ និងយកឈ្នះភាពអៀនខ្មាស់របស់ពួកគេ
- រូបភាព និងការតុបតែងលើជញ្ជាំងដែលបញ្ជូនសារឆ្លើយតបនឹងសមភាពយេនឌ័រ។

## ៣. ដំណើរការរៀបចំថ្នាក់រៀន

### ៣.១ សកម្មភាព និងគន្លឹះសម្រាប់គ្រូបង្រៀន

#### ៣.១.១ អន្តរកម្មនៅក្នុងថ្នាក់រៀន

- ប្រើប្រាស់ប្រអប់ដើម្បីចាប់ឈ្មោះសិស្សដោយចៃដន្យដើម្បីលើកទឹកចិត្តឱ្យមានការចូលរួមដោយស្មើភាពគ្នានៅក្នុងថ្នាក់រៀន
- ឱ្យសិស្សឆ្លើយសំណួរឆ្លាស់គ្នាដោយយេនឌ័រ ដូរវេនគ្នាឆ្លើយទាំងសិស្សប្រុស សិស្សស្រី ដើម្បីបង្កើតបរិយាកាសចូលរួម
- ផ្តល់ការលើកទឹកចិត្តសម្រាប់ការចូលរួមជាលក្ខណៈក្រុម ឬបុគ្គលដើម្បីធ្វើឱ្យការចូលរួមកាន់តែទូលាយ

- ផ្លាស់ប្តូរតួនាទីគ្នាសម្រាប់ក្មេងប្រុស និងក្មេងស្រីនៅក្នុងក្រុម ហើយបង្កើតតួនាទីដូចជា "អ្នកដឹកនាំក្រុម អ្នកស្រាវជ្រាវ ឬអ្នកសរសេរ" ដើម្បីបំពេញទៅតាមតួនាទីយេនឌ័រដែលបានបង្កើត។

### ៣.១.២ ការរៀបចំថ្នាក់រៀនជាទូទៅ

- **ការរៀបចំកន្លែងអង្គុយ៖** ត្រូវបង្កលក្ខណៈងាយស្រួលឱ្យសិស្សស្រី និងសិស្សប្រុសអាចចូលរួមយ៉ាងសកម្មប្រកបដោយសមធម៌ ក្នុងគ្រប់សកម្មភាពសិក្សា។ គ្រូបង្រៀនត្រូវរៀបចំឱ្យសិស្សអង្គុយតាមស្ថានភាព និងលក្ខណៈរបស់សិស្ស ជាការប្រសើរត្រូវឱ្យសិស្សប្រុស សិស្សស្រីអង្គុយចម្រុះគ្នានៅក្នុងការងារក្រុម ប៉ុន្តែត្រូវស្វែងយល់និងជៀសវាងអាកប្បកិរិយាមិនសមរម្យមួយចំនួនដែលរំខានដល់ការសិក្សា។ ការអង្គុយចម្រុះភេទ អាចជួយឱ្យសិស្សរៀនស្គាល់គ្នា គោរពគ្នាទៅវិញទៅមក រៀនសូត្រសហការគ្នា និងកសាងទំនុកចិត្ត។ ចំណុចសំខាន់មួយដែលគួរឱ្យកត់សម្គាល់នោះគឺ ការរៀបចំកន្លែងអង្គុយផ្សេងៗគ្នាបម្រើគោលបំណងបង្រៀន និងរៀនផ្សេងៗគ្នា ប៉ុន្តែប្រសិទ្ធភាពនៃការបង្រៀន និងរៀន ក៏ដូចជាការឆ្លើយតបនឹងសមភាពយេនឌ័រអាចកើតឡើងបានលុះត្រាតែគ្រូបានសម្របសម្រួល និងមានអន្តរកម្មសមស្របជាមួយសិស្ស។ អ្នកអាចរកបាននូវឧទាហរណ៍នៃការរៀបចំប្លង់អង្គុយផ្សេងៗគ្នាក្នុងប្រអប់ខាងក្រោម។
- **ការរៀបចំរចនាសម្ព័ន្ធ៖** ការជ្រើសរើសប្រធានថ្នាក់ អនុប្រធានថ្នាក់ និងសមាជិក ឬក្រុមត្រូវធានាថាមានសមាមាត្ររវាងសិស្សានុសិស្សទាំងអស់នៅក្នុងថ្នាក់រៀន ក្នុងករណីខ្លះ លោកគ្រូ អ្នកគ្រូត្រូវលើកទឹកចិត្តសិស្សស្រីឱ្យមានតួនាទីជាប្រធានថ្នាក់ ឬប្រធានក្រុម។
- **ការតុបតែងថ្នាក់រៀន៖** សម្ភារតុបតែងថ្នាក់ គួរចៀសវាងវិសមភាព និងការរើសអើងយេនឌ័រ ឧទាហរណ៍: ការតាំងពាក្យស្លោក ឬរូបភាពផ្សេងៗដែលបង្កប់អត្ថន័យលម្អៀងយេនឌ័រ។
- **កៀន ឬជ្រុងសិក្សា៖** កៀន ឬជ្រុងបង្កើតឡើងសម្រាប់បំពេញបន្ថែម តម្រូវការរបស់សិស្សានុសិស្ស ហើយគួរមានលក្ខណៈឱ្យសិស្សចូលរួមសិក្សាប្រកបដោយសមធម៌។
- **សង្ហារឹមសិក្សា៖** ថ្នាក់រៀនត្រូវមានសង្ហារឹមសិក្សាដូចជា តុ កៅអី ក្តារខៀន។ល។ ដែលមានភាពងាយស្រួលដល់សិស្សប្រុស សិស្សស្រីក្នុងការប្រើប្រាស់ និងលើកចល័តទីតាំងបាន។
- **ការបង្កើតប្រអប់ផ្តល់មតិយោបល់៖** លោកគ្រូ អ្នកគ្រូត្រូវបង្កើតប្រអប់ផ្តល់មតិយោបល់សម្រាប់សិស្សានុសិស្សទាំងអស់បញ្ចេញមតិយោបល់ ឬអារម្មណ៍ផ្ទាល់ខ្លួនរបស់ពួកគាត់ ជាពិសេសទៅលើបញ្ហាយេនឌ័រ។
- **ការបង្កើតគោលការណ៍ថ្នាក់រៀន៖** លោកគ្រូ អ្នកគ្រូត្រូវលើកទឹកចិត្តឱ្យសិស្សទាំងអស់ចូលរួមបង្កើតគោលការណ៍ថ្នាក់រៀន ដើម្បីធ្វើឱ្យដំណើរការបង្រៀន និងរៀនមានប្រសិទ្ធភាព។

**ឧទាហរណ៍នៃការរៀបចំប្លង់អង្គុយ**

ខាងក្រោមនេះគឺជាឧទាហរណ៍នៃការរៀបចំប្លង់អង្គុយមួយចំនួន។ សូមចងចាំថា ទោះជាអ្នកជ្រើសយកប្លង់ណាមួយក៏ដោយ អ្នកគប្បីលើកទឹកចិត្តឱ្យសិស្សស្រី និងសិស្សប្រុសអង្គុយតុជាមួយគ្នា។

| | |
|---|---|
| បែបថ្នាក់រៀនធម្មតា  | បែបរោងកុន  |
| បែបឆ្អឹងត្រី  | បែបអក្សរ U  |
| បែបអង្គប្រជុំ  | បែបចតុកោណកែងចំហរក្នុង  |
| បែបពិធីជប់លៀង  | អ្នកអាចរៀបចំរបៀបអង្គុយផ្សេងទៀតដែលស្របនឹងតម្រូវការមេរៀន |

**រូបភាពទី១១៖ ឧទាហរណ៍នៃការរៀបចំប្លង់អង្គុយ**

### ៣.១.៣ យុទ្ធវិធីដោះស្រាយចំពោះថ្នាក់រៀនដែលមានសិស្សច្រើន[22]

បញ្ហាថ្នាក់រៀនដែលមានសិស្សច្រើន កើតមានឡើងជាទូទៅនៅកម្ពុជា ហើយបញ្ហានេះជាឧបសគ្គមួយក្នុងចំណោមឧបសគ្គជាច្រើនដែលបានរាំងស្ទះការធានាឱ្យបាននូវការអប់រំប្រកបដោយសមភាព។ ដោយសារមានចំនួនសិស្សច្រើន គ្រូពិបាកនឹងយកចិត្តទុកដាក់ជួយសិស្សទាំងអស់គ្នាបានស្មើៗគ្នាណាស់ ហេតុនេះអាចប៉ះពាល់ដល់លទ្ធផលសិក្សារបស់ពួកគេ។ ចំនួនសិស្សច្រើន ក៏បានបង្កការលំបាកដល់គ្រូក្នុងការអនុវត្តវិន័យក្នុងថ្នាក់រៀនផងដែរ។ នៅក្នុងផ្នែកនេះ យើងនឹងសិក្សាពីយុទ្ធវិធីមួយចំនួនដែលគ្រូអាចប្រើគ្រប់គ្រងថ្នាក់រៀនដែលមានសិស្សច្រើនឱ្យមានប្រសិទ្ធភាព។

វិធីដោះស្រាយក្នុងករណីដែលមិនមានលំហគ្រប់គ្រាន់៖

- ប្រើលំហនៅខាងក្រៅថ្នាក់រៀន៖ អ្នកអាចរកមើលលំហនៅខាងក្រៅថ្នាក់រៀនបាន ហើយប្រើលំហនោះនៅក្នុងកិច្ចតែងការបង្រៀនរបស់អ្នក។ ទីធ្លាសាលារៀនជាលំហមួយដែលអាចបង្កបរិយាកាសរៀនសូត្រសម្រាប់សិស្សបាន និងអាចជួយដោះស្រាយបញ្ហាថ្នាក់រៀនតូចចង្អៀតដែលមានសិស្សច្រើន។ ឧទាហរណ៍៖
    - ក្នុងមេរៀនគណិតវិទ្យាអំពីរាងធរណីមាត្រ សិស្សអាចសិក្សាអំពីទីធ្លាសាលារៀន និងកំណត់រករាងធរណីមាត្រឱ្យបានច្រើនបំផុតតាមដែលគេអាចធ្វើបាន។ បន្ទាប់មក ពួកគេអាចអង្គុយនៅក្រោមដើមឈើ ហើយកត់ត្រាឡើងវិញនូវរូបធរណីមាត្រដែលពួកគេអាចរកបាន។
    - នៅក្នុងមេរៀនរង្វាស់រង្វាល់ សិស្សអាចប្រើជំហានជើង ឬប្រវែងប្រអប់ជើងដើម្បីវាស់ប្រវែងបណ្ដោយទីធ្លាសាលា ប្រវែងក្លោងទ្វារសាលា ប្រវែងបណ្ដោយទីចាត់ការ។ល។
    - នៅក្នុងមេរៀនចំនួន សិស្សអាចរកវត្ថុរាប់នៅក្នុងទីធ្លាសាលាដែលមានដូចជាស្លឹកឈើ មែកឈើតូចៗ ដុំថ្ម គម្របដបទឹកសុទ្ធ។ល។
    - នៅក្នុងមេរៀនភាសាខ្មែរ សិស្សអាចសរសេរ និងបិទសម្គាល់ឈ្មោះវត្ថុផ្សេងៗនៅក្នុងទីធ្លាសាលារៀន។ ក្នុងពេលចេញលេង សិស្សផ្សេងៗទៀតអាចមើលស្លាកសម្គាល់នោះ ហើយចងចាំឈ្មោះវត្ថុ និងរបៀបសរសេរឈ្មោះនោះទៀតផង។

យុទ្ធវិធីដើម្បីបង្កើតបរិយាកាសរៀនសូត្របែបវិជ្ជមាននៅក្នុងថ្នាក់រៀនដែលមានសិស្សច្រើន៖

- បង្កើតដៃគូ ឬក្រុមតូចដែលមានលាយឡំសិស្សស្រី និងសិស្សប្រុស៖ ការធ្វើបែបនេះ ជួយឱ្យសិស្សស្រី និងសិស្សប្រុសមានឱកាសសហការគ្នា សួរសំណួរ ស្វែងយល់ពីកម្រិតយល់ដឹងទៅវិញទៅមក និងឆ្លុះបញ្ចាំងលើខ្លឹមសារមេរៀនជាមួយគ្នា។ គ្រូគប្បីអនុវត្តសកម្មភាពនេះឱ្យបានញឹកញាប់។ ទោះបីជាការពិភាក្សាដៃគូរយៈពេលមួយនាទី ក៏អាចផ្ដល់ឱកាសឱ្យសិស្សបានជជែក និងស្ដាប់គ្នាទៅវិញទៅមកអំពីខ្លឹមសារមេរៀនដែរ។

[22] FAWE. (2020). Gender Responsive Pedagogy Toolkit for Teachers and Schools 2nd edition. Nairobi: FAWE.

- ក្នុងការងារក្រុម គប្បីផ្ដល់ឱកាសឱ្យសិស្សស្រី និងសិស្សប្រុសប្ដូរតួនាទីគ្នាជាប់ជាប្រចាំ៖ អ្នកអាចផ្ដល់តួនាទីឱ្យសមាជិកនៅក្នុងក្រុមតូចដែលមានដូចជា៖
    - អ្នកកត់ត្រា៖ ជាអ្នកដែលមានតួនាទីកត់ត្រាខ្លឹមសារសំខាន់ៗនៃការពិភាក្សាក្រុម
    - អ្នកសម្របសម្រួល៖ មានតួនាទីលើកទឹកចិត្តសមាជិកក្រុមឱ្យចូលរួមបញ្ចេញយោបល់ និងមានពេលវេលានិយាយស្មើៗគ្នា
    - អ្នកឡើងរាយការណ៍៖ ជាអ្នកឡើងបង្ហាញលទ្ធផលពិភាក្សាក្រុមដល់សិស្សផ្សេងទៀត
- ត្រួតពិនិត្យការយល់ដឹងរបស់សិស្សតាមវិធីដែលបង្កភាពរីករាយ៖ អ្នកអាចប្រើវិធីវាយតម្លៃខ្លីៗពេលកំពុងបង្រៀន ដែលមានដូចជា៖
    - ដើម្បីបញ្ជាក់ថាសិស្សយល់ខ្លឹមសារ ឬមិនទាន់យល់ ពួកគេអាចលើកមេដៃឡើងលើ ដាក់មេដៃចុះក្រោម ឬដាក់មេដៃទៅចំហៀង។ ក្រៅពីនេះ ពួកគេអាចលើកម្រាមដៃចំនួនពី១ ដល់៣ ដាក់លើដើមទ្រូង ដើម្បីបញ្ជាក់ពីកម្រិតតិច ឬច្រើនដែលពួកគេយល់ខ្លឹមសារមេរៀនដែលគ្រូទើបតែបានបង្រៀនរួច។
    - សិស្សអាចសរសេរឃ្លាបំពេញចន្លោះខាងក្រោមដើម្បីបញ្ជាក់ពីកម្រិតយល់ដឹងរបស់គេ រួចដាក់ក្នុងប្រអប់មួយមុនពេលចេញទៅផ្ទះ៖
        - ចំណុចសំខាន់បំផុតដែលខ្ញុំរៀនចេះនៅថ្ងៃនេះគឺ………
        - ខ្ញុំត្រូវការជំនួយបន្ថែមទៀតនៅត្រង់ផ្នែក………
        - ខ្ញុំនៅមានសំណួរមួយគឺ………
        - ចំណុចដែលមេរៀនថ្ងៃនេះប៉ះពាល់សិស្សស្រី និងសិស្សប្រុសមិនដូចគ្នាគឺ………
- រកវិធីថ្មីដែលគួរឱ្យចាប់អារម្មណ៍ដើម្បីស្វែងយល់ពីសិស្សរបស់អ្នក៖ ជាពិសេសនៅពេលដែលអ្នកមានសិស្សច្រើន ហើយពិបាកចាំឈ្មោះ ឬតម្រូវការរបស់ពួកគេទាំងអស់គ្នា។ ធ្វើបែបនេះអាចជួយឱ្យសិស្សម្នាក់ៗមានអារម្មណ៍ថាទទួលបានការយកចិត្តទុកដាក់ និងឱ្យតម្លៃដូចៗគ្នា។
    - លេងល្បែងដាក់ឈ្មោះ៖ សិស្សទាំងអស់គ្នាឈរជារង្វង់ ហើយដាក់វេនគ្នានិយាយម្ដងម្នាក់នូវឈ្មោះរបស់គេ ភ្ជាប់ដោយគុណនាមមួយដែលបរិយាយពីលក្ខណ:សម្បត្តិរបស់គេផង។ ឧទាហរណ៍៖ សុភាពដ៏ខ្លាំងក្លា ឬពន្លកដែលសុភាពរាបសា ព្រមទាំងធ្វើកាយវិការដែលបញ្ជាក់ពីគុណនាមនោះផងដែរ។
    - ធ្វើយ៉ាងណាឱ្យសិស្សប្រាប់ឈ្មោះរបស់គេរាល់ពេលដែលគេនិយាយ ឬបញ្ចេញមតិយោបល់ផ្សេងៗ ពោលគឺឱ្យសិស្សប្រាប់ឈ្មោះរបស់គេឱ្យបានញឹកញាប់តាមដែលអាចធ្វើបាន។

**សកម្មភាពទី១៖ ការរៀបចំថ្នាក់រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ**

សូមសង្កេតមើលការរៀបចំថ្នាក់រៀនដោយពិនិត្យមើលធាតុផ្សំមួយចំនួនដូចខាងក្រោម៖

- ការរៀបចំទីតាំងតុ (កម្ពស់តុ និងកៅអី)
- ចំណុះថ្នាក់ សមាមាត្រនឹងចំនួនសិស្ស (១ម៉ែត្រការ៉េ/ម្នាក់)

- លំហា និងការតុបតែងលើជញ្ជាំង
- កម្ពស់ផ្ទើរ
- ទីតាំងអង្គុយសម្រាប់សិស្សស្រី និងសិស្សប្រុស
- កម្ពស់កៅអីអង្គុយនៅក្នុងបន្ទប់ពិសោធន៍។

តើចំណុចទាំងអស់ខាងលើនេះមានលក្ខណៈឆ្លើយតបនឹងសមភាពយេនឌ័រដែរឬទេ? បើមិនដូច្នោះទេ តើអ្នកអាចធ្វើអ្វីបានដើម្បីឱ្យមានការឆ្លើយតបនឹងសមភាពយេនឌ័រ?

**សកម្មភាពទី២៖ ការរៀបចំទីតាំងអង្គុយដែលឆ្លើយតបនឹងសមភាពយេនឌ័រ**
សូមស្វាគមន៍មកកាន់ថ្នាក់រៀនថ្មីរបស់អ្នក!




**រូបភាពទី១២៖ករណីសិក្សាអំពីការរៀបចំប្លង់អង្គុយ**

១) តើអ្នកអាចរៀបចំកន្លែងអង្គុយសម្រាប់សិស្សនៅក្នុងបញ្ជីខាងក្រោមបានដែរឬទេ? សូមកត់ចំណាំថាសិស្សមួយចំនួនមានកន្លែងអង្គុយរួចហើយ និងសូមព្យាយាមបំពេញតាមតម្រូវការរបស់ពួកគេ។
២) កំណត់តួនាទីប្រធានក្រុមដោយដាក់សញ្ញាខ្វែង (X) សម្គាល់
៣) ពិភាក្សាជាក្រុមថាមូលហេតុអ្វីបានជាអ្នកជ្រើសយកការរៀបចំបែបនេះ

| សិស្សនៅក្នុងថ្នាក់របស់អ្នក | |
|---|---|
| ♂ | ♀ |
| សិស្សប្រុសខាងក្រោមនេះមានកន្លែងអង្គុយរួចហើយ៖ | សិស្សស្រីខាងក្រោមនេះមានកន្លែងអង្គុយរួចហើយ៖ |
| 1. ចន្ទចងចាំមិនសូវបានល្អទេ<br>2. បូរាណជាសិស្សរៀនយឺត<br>3. សុភក្តិនិយាយច្រើន<br>4. ណោម៉ូឆ្លាត<br>5. ដារ៉ានីមិនចូលចិត្តសាលារៀនទេ។ | 13. បូផាជាមនុស្សអៀនប្រៀន<br>14. ចន្ទ្រាឧស្សាហ៍រៀនសូត្រ<br>15. បញ្ញាឆ្លាត<br>16. គង្គានិយាយច្រើន។ |
| សិស្សប្រុសខាងក្រោមត្រូវការរៀបចំកន្លែងអង្គុយ៖ | សិស្សស្រីខាងក្រោមត្រូវការរៀបចំកន្លែងអង្គុយ៖ |
| 6. គិរីមានបញ្ហាគំហើញ<br>7. លាភជាមនុស្សអៀនប្រៀន<br>8. និស្ស័យជាសិស្សពូកែ<br>9. ពេជ្រមិនទុកចិត្តខ្លួនឯង<br>10. ប្រាក់មិនអាចផ្តោតអារម្មណ៍បានល្អទេ<br>11. រិទ្ធីរៀនឆាប់ចេះ<br>12. សង្ហារមិនធ្វើតាមការណែនាំទេ។ | 17. ចិន្តារពឹសឃាត់មិនជាប់<br>18. សិលាតែងតែជជែកគ្នា<br>19. បុទុមជាសិស្សពូកែ<br>20. យ៉ូរ៉ានីជាមនុស្សរើរវាយ<br>21. កូឡាបមានបញ្ហាក្នុងការស្តាប់<br>22. ម៉ាលីមានរបៀប<br>23. នួនងាយនឹងថប់អារម្មណ៍។ |

## IV. សេចក្តីសន្និដ្ឋាន

ក្នុងមេរៀននេះ យើងបានពិភាក្សាគ្នាអំពីការរៀបចំថ្នាក់រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ។ របៀបរៀបចំទីតាំងអង្គុយរបស់សិស្ស និងការរៀបចំថ្នាក់រៀនរបស់អ្នកមានឥទ្ធិពលលើការចូលរួម និងការទទួលបានចំណេះដឹងរបស់សិស្ស ថែមទាំងបានចូលរួមកាត់បន្ថយ និងលុបបំបាត់វិសមភាពយេនឌ័រក្នុងការបង្រៀន និងរៀនទៀតផង។ ដើម្បីទទួលបានព័ត៌មានលម្អិតបន្ថែមទៀតពាក់ព័ន្ធនឹងការរៀបចំថ្នាក់រៀនដើម្បីសម្រួលដល់ដំណើរការបង្រៀន និងរៀន ព្រមទាំងឆ្លើយតបនឹងសមភាពយេនឌ័រ សូមមើលឯកសារ "ប្រសិទ្ធភាពនៃការគ្រប់គ្រងថ្នាក់រៀន" ដែលត្រូវបានសហការចងក្រងរួមគ្នាដោយក្រុមការងារបច្ចេកទេសរបស់ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការវីវីអូប៊ី។

# មេរៀនទី៥

## វិន័យបែបវិជ្ជមាន

### I. សេចក្តីផ្តើម

អ្នកគ្រូ លោកគ្រូ មាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍មានតួនាទីក្នុងការអប់រំ ទូន្មាន និងប្រៀនប្រដៅកុមារ ដើម្បីឱ្យក្លាយទៅជាកូនប្រុសកូនស្រីល្អ សិស្សល្អ និងពលរដ្ឋល្អ ដែលមានចំណេះដឹងជ្រៅជ្រះ និងមានទំនុកចិត្តខ្ពស់លើខ្លួនឯង។ ការប្រកាន់យកអាកប្បកិរិយាបែបអហិង្សា ផ្តល់គំរូល្អដល់កុមារក្នុងការរស់នៅ និងរៀនសូត្រ ធ្វើឱ្យកុមារមានការលូតលាស់បានពេញលេញទាំងបញ្ញា ស្មារតី និងរូបរាងកាយ។ ប៉ុន្តែគ្រូងាយនឹងមានអារម្មណ៍មិនសប្បាយចិត្តនៅពេលដែលសិស្សមិនព្រមស្តាប់បង្គាប់ ឬមិនអនុវត្តតាមការណែនាំរបស់គ្រូ។ មេរៀននេះ នឹងបង្ហាញអំពីវិធីសាស្ត្រក្នុងការអនុវត្តវិន័យបែបវិជ្ជមាន ដើម្បីឆ្លើយតបនឹងអាកប្បកិរិយាមិនសមរម្យរបស់កុមារទាំងនៅផ្ទះ សាលារៀន និងសហគមន៍ ដោយជៀសវាងការប្រើការដាក់ទណ្ឌកម្មលើរូបរាងកាយ ធ្វើយ៉ាងណាឱ្យសិស្សជៀសវាងសកម្មភាពមិនសមរម្យតាំងពីដំបូង និងចូលរួមសហការបានល្អក្នុងសកម្មភាពបង្រៀន និងរៀន។

### II. វត្ថុបំណង

- ពន្យល់បានពីភាពខុសគ្នារវាងការដាក់ទណ្ឌកម្ម និងវិន័យបែបវិជ្ជមាន
- ពន្យល់បានពីបញ្ញត្តិវិន័យបែបវិជ្ជមាន
- ពិភាក្សាពីរបៀបប្រើវិន័យបែបវិជ្ជមាន
- អនុវត្តបង្ហាញវិធីដើម្បីកាត់បន្ថយអាកប្បកិរិយាមិនសមរម្យរបស់សិស្ស។

### III. ខ្លឹមសារ

**១. តើអ្វីទៅជាការដាក់ទណ្ឌកម្ម?**

ទណ្ឌកម្មគឺជាសកម្មភាពដាក់ពិន័យទៅលើនរណាម្នាក់ដែលបានប្រព្រឹត្តល្មើសនឹងច្បាប់ ឬបានធ្វើសកម្មភាពដែលមិនសមរម្យ។ ទណ្ឌកម្មមានគោលបំណងគ្រប់គ្រងអាកប្បកិរិយា តាមរយៈវិធីបែបអវិជ្ជមាន។ មានទណ្ឌកម្ម ២ប្រភេទដែលតែងតែត្រូវបានប្រើទៅលើកុមារ៖

**ក.ទណ្ឌកម្មដោយប្រើពាក្យសម្តីបែបអវិជ្ជមាន៖** ទណ្ឌកម្មប្រភេទនេះត្រូវបានហៅថាជាវិន័យបែបអវិជ្ជមានដែលមានឧទាហរណ៍ដូចខាងក្រោម៖

- ការដាក់បញ្ជា៖ "អង្គុយចុះ ហើយស្ងៀមស្ងាត់!" "សរសេរ១០០ចប់!" "ខ្ញុំមិនបង្ហិនពេលវេលាជាមួយការងារអត់ប្រយោជន៍បែបនេះទេ!"

- ពាក្យសម្ដីហាមឃាត់៖ "កុំធ្វើ!"
- ពាក្យសម្ដីពោរពេញដោយកំហឹង៖ "ឯងមានបញ្ហាធំហើយ!"
- ពាក្យសម្ដីរិះគន់៖ "អូ! ឯងធ្វើអស់ល្អបានត្រឹមប៉ុណ្ណឹងហើយមែនទេ?"
- ពាក្យសម្ដីគំរាមកំហែង៖ "បើឯងមិនព្រមឈប់និយាយទេ ខ្ញុំបញ្ជូនឯងទៅជួបនាយកហើយ!"
- ពាក្យសម្ដីមាក់ងាយ៖ "តើអង្គាល់បានឯងចេះសរសេរបានត្រឹមត្រូវនឹងគេ?"

**ខ.ការដាក់ទណ្ឌកម្មដែលបង្កការឈឺចាប់លើរូបរាងកាយ ឬផ្លូវអារម្មណ៍** ដែលមានឧទាហរណ៍ដូចខាងក្រោម៖

- ការវាយដំកុមារដោយដៃ ជើង ឬប្រើវត្ថុផ្សេងៗ (ដូចជារំពាត់ ខ្សែក្រវ៉ាត់ ខ្សែតី ស្បែកជើង សៀវភៅ បន្ទាត់។ល។)
- ការទាត់ ធាក់ ឬចាប់អង្រួនកុមារ
- ការក្ដិច ឬបោចសក់
- បង្ខំឱ្យកុមារស្ថិតក្នុងកាយវិការដែលបង្កការលំបាក នឿយហត់ ឬឈឺចាប់ (ឧ.ឈរ ឈរជើងមួយ លត់ជង្គង់។ល។)
- បង្ខំឱ្យកុមារធ្វើលំហាត់ប្រាណ ឬធ្វើការហួសកម្លាំង
- អុជបណ្ដាលឱ្យរលាក ឬបំភ័យកុមារ។

ទម្រង់ទាំងពីរខាងលើនៃការដាក់ទណ្ឌកម្ម ចង់ឱ្យសិស្សជៀសវាងអាកប្បកិរិយាមិនសមរម្យ ប៉ុន្តែប្រហែលជាមិនសូវមានប្រសិទ្ធភាពទេ។ លើសពីនេះទៅទៀត កុមាររៀនសូត្របានថា មនុស្សពេញវ័យមានអំណាចធំជាងកូនក្មេង ហើយការប្រើអំណាចដោយពាក្យសម្ដី ដោយផ្លូវកាយ ឬផ្លូវអារម្មណ៍របស់មនុស្សធំទៅលើកូនក្មេង ឬមនុស្សដែលទន់ខ្សោយជាងគឺជារឿងដែលអាចទទួលយកបាន។ ជាលទ្ធផល កុមារនឹងប្រើអំណាចទាំងនោះដូចគ្នា ជាហេតុញ៉ាំងឱ្យកើតមានអំពើសំឡុតគំរាម ធ្វើទុក្ខបុកម្នេញ និងអំពើហិង្សាកាន់តែច្រើននៅក្នុងសាលារៀន ដែលកុមារដែលមានអាយុច្រើន ធ្វើបាបកុមារដែលមានអាយុតិច ដើម្បីជំរិតយកលុយ នំចំណី កិច្ចការផ្ទះ ឬវត្ថុមានតម្លៃផ្សេងៗទៀត។

ទណ្ឌកម្មធ្វើឱ្យកុមារកើតមានកំហឹង ឈឺចាប់ផ្លូវចិត្ត និងមានភាពភ័យខ្លាច។ ទណ្ឌកម្មក៏អាចបណ្ដាលឱ្យកុមារមានភាពខ្មាស់អៀន មានអារម្មណ៍ថាខុសឆ្គង និងអារម្មណ៍សោប់សេលផងដែរ។ ទណ្ឌកម្មមិនបានជួយឱ្យកុមារមានអារម្មណ៍ថាម្ចាស់ការលើខ្លួនឯងនោះទេ ប៉ុន្តែបែរជាបណ្ដាលឱ្យពួកគេកាន់តែពោរពេញដោយកំហឹង និងមិនខ្វល់ពីអ្នកដទៃ។ ដូច្នេះហើយ ឆ្លងកាត់រយៈពេលយូរ ទណ្ឌកម្មនឹងញ៉ាំងឱ្យកុមារមានបញ្ហាផ្នែកអាកប្បកិរិយារបស់ពួកគេ។

**២.តើអ្វីទៅជាវិន័យ?**

វិន័យតែងត្រូវបានប្រើដោយភាន់ច្រឡំថាជាបញ្ញត្តិ ដែលដូចគ្នាទៅនឹងទណ្ឌកម្ម។ គ្រូបង្រៀនភាគច្រើនយល់ថាវិន័យគឺជាការដាក់ទណ្ឌកម្ម។ ឧទាហរណ៍ ពេលដែលគ្រូម្នាក់និយាយថា៖ "កុមារម្នាក់នេះត្រូវការដាក់វិន័យហើយ" គឺគាត់មានន័យថា៖ "កុមារម្នាក់នេះគួរតែត្រូវវាយហើយ"។ នេះមិនមែនជាការយល់ឃើញដែលត្រឹមត្រូវនោះទេ។ វិន័យមិនមែនជាការដាក់ទណ្ឌកម្មនោះទេ។

*"វិន័យគឺជាការអនុវត្តដើម្បីបង្រៀនមនុស្សម្នាក់ឱ្យចេះគោរពច្បាប់ ឬអាកប្បកិរិយាប្រកបដោយក្រមសីលធម៌ទាំងក្នុងរយៈពេលខ្លី និងរយៈពេលវែង"។*

ខណៈដែលទណ្ឌកម្មមានគោលបំណងគ្រប់គ្រងអាកប្បកិរិយារបស់កុមារ វិន័យមានគោលបំណងតម្រង់ទិស ជាពិសេសដោយផ្តោតលើការប្រព្រឹត្តិ។ វិន័យបង្រៀនកុមារឱ្យចេះគ្រប់គ្រងខ្លួនឯង និងកសាងទំនុកចិត្តលើខ្លួនឯង ដោយផ្តោតលើអ្វីដែលយើងចង់ឱ្យកុមាររៀនចេះ និងផ្តោតលើសមត្ថភាពរៀនសូត្ររបស់គេ។ វិន័យជាមូលដ្ឋានដែលជួយឱ្យកុមារចេះចុះសម្រុងជាមួយខ្លួនឯង និងជាមួយអ្នកដទៃ។ គោលដៅនៃការប្រើប្រាស់វិន័យ គឺដើម្បីឱ្យកុមារយល់ពីអាកប្បកិរិយារបស់ខ្លួនឯង ហ៊ានសម្រេចចិត្ត ហ៊ានទទួលខុសត្រូវចំពោះការជ្រើសរើសរបស់ខ្លួន និងចេះគោរពខ្លួនឯង និងអ្នកដទៃ។

ជារួម យើងអាចប្រៀបធៀបទណ្ឌកម្ម និងវិន័យដូចខាងក្រោម៖

| **វិន័យគឺជា៖** | **ទណ្ឌកម្មគឺជា៖** |
|---|---|
| ការផ្តល់ជម្រើសវិជ្ជមានឱ្យកុមារ | ការប្រាប់ថាអ្វីដែលមិនគួរធ្វើ |
| ការទទួលស្គាល់ ឬផ្តល់រង្វាន់ចំពោះការប្រឹងប្រែង ឬអាកប្បកិរិយាល្អ | ការប្រតិកម្មដោយហិង្សាចំពោះការប្រព្រឹត្តមិនសមរម្យ |
| ការណែនាំដែលមានសង្គតភាព និងម៉ឺងម៉ាត់ | ការគ្រប់គ្រង ធ្វើឱ្យបាក់មុខ ការយកកុមារមកលេងសើច |
| ទង្វើអហិង្សាទាំងផ្លូវកាយ និងពាក្យសម្តី | ការមិនគោរពចំពោះកុមារ |
| លទ្ធផលសមហេតុផលដែលជាប់ទាក់ទងដោយផ្ទាល់ទៅនឹងការប្រព្រឹត្តមិនសមរម្យ | ជាលទ្ធផលដែលមិនសមហេតុផល និងមិនជាប់ទាក់ទងដោយផ្ទាល់ទៅនឹងការប្រព្រឹត្តិមិនសមរម្យនោះទេ |
| ការយកកំហុសធ្វើជាឱកាសរៀនសូត្រ។ | ការបង្ខំកុមារឱ្យអនុវត្តតាមច្បាប់ដែលមិនសមហេតុផល ដោយសារតែនោះជាសម្តីរបស់គ្រូ |

### ៣.តើអ្វីជាវិន័យបែបវិជ្ជមាន?

មានភស្តុតាងជាច្រើនបានបង្ហាញថាកុមារា និងកុមារី ឆ្លើយតបបានល្អចំពោះសកម្មភាពបែបវិជ្ជមានដូចជាការចរចា និងប្រព័ន្ធនៃការផ្តល់រង្វាន់ ជាជាងការដាក់ទណ្ឌកម្មតាមរយៈការរំលោភបំពានដោយប្រើពាក្យសម្តី ការរំលោភបំពានផ្លូវកាយ ឬផ្លូវអារម្មណ៍[23]។

វិន័យបែបវិជ្ជមានជាវិន័យបែបអហិង្សាមកលើរាងកាយ និងស្មារតី ចំពោះកុមារ ឬបុគ្គលណាម្នាក់ដែលប្រព្រឹត្តខុស។ យើងអាចបែងចែកវិន័យជាពីរផ្នែក គឺវិន័យបែបវិជ្ជមាន និងវិន័យបែបអវិជ្ជមាន៖

- វិន័យបែបវិជ្ជមានមានលក្ខណៈសេរីហើយទទួលយកឆន្ទៈចូលទៅក្នុងសតិសម្បជញ្ញៈរបស់សិស្ស។ វិន័យបែបវិជ្ជមានមានលក្ខណៈអហិង្សា។
- វិន័យបែបអវិជ្ជមានផ្អែកលើការដាក់ទណ្ឌកម្ម និងសម្ពាធបែបហិង្សាតាមគ្រប់រូបភាព។

វិន័យបែបវិជ្ជមានបង្រៀនសិស្សឱ្យយល់ និងគោរពតាមច្បាប់ ឬ បទបញ្ញត្តិ មានអាកប្បកិរិយាសមរម្យទាំងនៅក្នុង និងក្រៅថ្នាក់រៀន ដោយមិនប្រើអំពើហិង្សាលើរាងកាយ និងផ្នែកស្មារតីឡើយ។ វាជាវិធីមួយដែលធ្វើឱ្យសិស្សប្រព្រឹត្តត្រឹមត្រូវ ដោយមិនប្រើការដាក់ទណ្ឌកម្ម នៅពេលសិស្សប្រព្រឹត្តមិនសមរម្យតាមរយៈការបកស្រាយដោយភាពច្បាស់លាស់ ការយល់ស៊ីជម្រៅពីស្ថានភាព និងលទ្ធផលសមស្រប។ វាជំរុញ និងលើកកម្ពស់ភាពខ្លាំងរបស់សិស្ស ដោយមិនទិតៀនចំណុចខ្សោយរបស់គេទេ។ លើសពីនេះទៅទៀត វាជួយជំរុញការចូលរួមយ៉ាងសកម្ម និងពង្រឹងបំណិនដោះស្រាយបញ្ហា។ ជារួមវិន័យបែបវិជ្ជមានជួយឱ្យសិស្សទទួលបានលទ្ធផលល្អ និងមានអាកប្បកិរិយាសមរម្យ។ CJCP (2012), Nelsen J. (2013), Hattie (2009)

វិន័យបែបវិជ្ជមានលើកកម្ពស់***បំណិនសង្គម (social skills)*** របស់សិស្ស ដែលអាចជួយឱ្យពួកគាត់ទទួលបានជោគជ័យក្នុងសាលា និងជីវិត។

### ៤.របៀបអនុវត្តវិន័យបែបវិជ្ជមាន

ខណៈដែលទណ្ឌកម្មគឺជាទង្វើមួយ វិន័យបែបវិជ្ជមានជាលំនាំមួយមាន ៤ជំហាន ដែលទទួលស្គាល់ និងផ្តល់រង្វាន់ចំពោះអាកប្បកិរិយាដែលសមរម្យ តាមលំនាំដូចខាងក្រោម៖

ក.អាកប្បកិរិយាសមរម្យនោះត្រូវបានពណ៌នាថា៖ "ឥឡូវនេះ សូមកូនៗទាំងអស់គ្នាស្ងៀមស្ងាត់"។

ខ.គ្រូបញ្ជាក់ហេតុផលច្បាស់លាស់៖ "យើងនឹងចាប់ផ្តើមរៀនគណិតវិទ្យា ហើយកូនៗត្រូវស្តាប់ដោយយកចិត្តទុកដាក់"។ មានន័យថាកូនៗត្រូវស្ងៀមស្ងាត់ដើម្បីជាការគោរពដល់សិស្សផ្សេងៗទៀត។ នេះជាឧទាហរណ៍ល្អមួយអំពីការធ្វើចំពោះអ្នកដទៃ ដូចដែលអ្នកចង់ឱ្យគេធ្វើមកលើរូបអ្នកដែរ។

---

[23]Save the children. How to Research the Physical and Emotional Punishment of Children. Bangkok: Southeast, East Asia and Pacific Region, 2004.

គ.គ្រូស្នើសុំការទទួលស្គាល់របស់សិស្ស៖ "តើកូនៗឃើញទេ មូលហេតុអ្វីបានជាយើងចាំបាច់ត្រូវស្មៀមស្ងាត់?" ឬ "ពេលដែលយើងជជែកដោយមិនរំខានដល់អ្នកដទៃ អ្នកទាំងអស់គ្នាអាចផ្តោតអារម្មណ៍រៀនមេរៀននេះបានល្អ"។

ឃ.ពង្រឹងការអនុវត្តអាកប្បកិរិយាដែលត្រឹមត្រូវ តាមរយៈ៖ ការមើលចំភ្នែក ការងក់ក្បាល ស្នាមញញឹម ឬការថែមម៉ោងចេញលេង ៥នាទីនៅចុងម៉ោងសិក្សា ការថែមពិន្ទុ ការលើកសរសើរចំពោះមុខសិស្សផ្សេងទៀតក្នុងថ្នាក់ ឬក្នុងសាលារៀនទាំងមូល (ការទទួលស្គាល់ដោយសង្គមគឺជារង្វាន់មួយដ៏ធំ)។ គ្រូអាចផ្តល់រង្វាន់តូចៗ ភ្លាមៗ ប៉ុន្តែជារង្វាន់ដែលសិស្សពេញចិត្ត។

លំនាំនេះមានប្រសិទ្ធភាពចំពោះកុមារទាំងជាលក្ខណៈបុគ្គល និងជាក្រុម។ ធ្វើយ៉ាងណាឱ្យកុមារមានអារម្មណ៍ថាគេជាផ្នែកមួយនៃក្រុមដែលទទួលបានការកោតសរសើរ (គឺសិស្សទាំងអស់នៅក្នុងថ្នាក់រៀនទាំងមូល) និងលើកសរសើរពីការខិតខំប្រឹងប្រែងរបស់ពួកគេម្នាក់ៗក្នុងនាមជាសមាជិកក្រុមដ៏ល្អ។

ចំណាំ៖ ពេលឃើញកុមារមានអាកប្បកិរិយាដែលត្រឹមត្រូវ ត្រូវផ្តល់រង្វាន់ឱ្យគេភ្លាម។ នេះគឺជាចំណុចសំខាន់នៃវិន័យបែបវិជ្ជមាន។

## ៥.វិធីកាត់បន្ថយអាកប្បកិរិយាដែលមិនសមរម្យ

អាកប្បកិរិយាមិនសមរម្យគឺជាអាកប្បកិរិយាមិនគប្បីដែល ១) បណ្តាលឱ្យកុមារ ឬអ្នកដទៃមានគ្រោះថ្នាក់ ២) មិនគោរពតាមការរំពឹងទុករបស់សង្គម ឬវិន័យរបស់ថ្នាក់រៀន និង ៣) ជំទាស់ជាមួយអន្តរកម្មសង្គមបែបវិជ្ជមាន និងវិន័យផ្ទាល់ខ្លួនបែបវិជ្ជមាន។ ប្រសិនបើមានសិស្សប្រព្រឹត្តិ ឬមានអាកប្បកិរិយាមិនសមរម្យ វិធីល្អបំផុតដើម្បីកាត់បន្ថយ ឬជៀសវាងទង្វើបែបនេះគឺការប្រើវិធីដែលមានលក្ខណៈវិជ្ជមាន។

តើអ្នកអាចប្រើវិធីបែបវិជ្ជមានដើម្បីកាត់បន្ថយអាកប្បកិរិយាមិនសមរម្យដោយរបៀបណា? អ្នកអាចពិនិត្យមើលសិស្សរបស់អ្នកដោយប្រុងប្រយ័ត្ន និងជាប់ជាប្រចាំដើម្បីរកឱ្យឃើញអាកប្បកិរិយាទាំងនោះមុនពេលក្លាយជាបញ្ហាធំហើយប៉ះពាល់ដល់សិស្សផ្សេងៗទៀត។ ពេលដែលមានអាកប្បកិរិយាមិនសមរម្យកើតឡើង សូមជៀសវាងផ្អាកការបង្រៀន ឬធ្វើឱ្យសិស្សផ្សេងៗទៀតចាប់អារម្មណ៍លើសិស្សម្នាក់នោះខ្លាំងពេក។ ផ្ទុយទៅវិញ សូមសាកល្បងអនុវត្តតាមជំហានដូចខាងក្រោម៖

ក.ចូលទៅជិតសិស្ស ឬក្រុមសិស្សដែលបានបង្កអាកប្បកិរិយាមិនសមរម្យ សំឡឹងចំភ្នែករបស់គេ ហើយប្រើសញ្ញាឱ្យគេបញ្ឈប់អាកប្បកិរិយាមិនសមរម្យនោះ

ខ.ហៅឈ្មោះសិស្សម្នាក់នោះ ឬណែនាំខ្លីៗឱ្យគេបញ្ឈប់អាកប្បកិរិយាមិនសមរម្យ

គ.បង្វែរការចាប់អារម្មណ៍របស់សិស្សទៅរកអាកប្បកិរិយាបែបវិជ្ជមានវិញ ដោយចាប់ផ្តើមធ្វើសកម្មភាពដែលសិស្សគួរតែធ្វើ (ជៀសវាងការប្រើពាក្យថា "កុំ") ហើយរំឭកពីវិន័យដែលគេគួរតែអនុវត្តតាម។

យ៉ាងណាមិញ ទង្វើមិនសមរម្យទាំងនោះ មិនមែនសុទ្ធតែកើតឡើងដោយចេតនានោះទេ។ សិស្សអាចមិនទាន់ដឹងថាអាកប្បកិរិយាដែលគេបានប្រព្រឹត្តិនោះ ជាទង្វើដែលមិនសមរម្យនោះទេ។ អាកប្បកិរិយាមិនសមរម្យដ៏ពិតប្រាកដកើតមានឡើងនៅពេលដែលកុមារមានចេតនាប្រព្រឹត្តទង្វើនោះ។




រូបភាពទី១៣៖ វិធីដោះស្រាយចំពោះអាកប្បកិរិយាដែលមិនសមរម្យក្នុងថ្នាក់រៀន

តើអ្នកអាចមានវិធីដាក់ពិន័យផ្សេងទៀតដែលស័ក្តិសមចំពោះថ្នាក់រៀន និងសិស្សរបស់អ្នកដែរឬទេ? អ្នកមិនគប្បីប្រើវិធីដាក់ពិន័យដែលប៉ះពាល់ដល់រូបរាងកាយ ឬធ្វើឱ្យសិស្សបាក់មុខជាសាធារណៈនោះទេ។

**សកម្មភាព៖** ឆ្លុះបញ្ចាំងពីពេលវេលាដែលអ្នកត្រូវអនុវត្តវិន័យពេលនៅជាសិស្ស និងពេលដែលអ្នកដាក់ពិន័យលើសិស្សរបស់អ្នក

ក.សូមគិតដល់ពេលដែលអ្នកជាសិស្សនៅរៀនកម្រិតបឋម ឬមធ្យមសិក្សា។ ពេលដែលអ្នក ឬមិត្តរួមថ្នាក់ណាម្នាក់ប្រព្រឹត្តិខុស តើគ្រូរបស់អ្នកបានដាក់ពិន័យអ្នកដូចម្តេច? សូមសរសេរវិធីដាក់ពិន័យទាំងនោះនៅក្នុងតារាងខាងក្រោម (១)។ បន្ទាប់មក សូមសរសេរពីមូលហេតុដែលគ្រូអនុវត្តវិធីដាក់ពិន័យទាំងនោះ (២) និងអារម្មណ៍ដែលសិស្សទទួលបានពេលគ្រូដាក់ពិន័យតាមវិធីទាំងនោះ។

ខ.បន្ទាប់មក សូមចោទសួរខ្លួនឯងនូវសំណួរ៖ "បើខ្ញុំមានសិស្សដែលប្រព្រឹត្តិខុស តើខ្ញុំនឹងធ្វើដូចម្តេច? ហេតុអ្វី?

| | ១. វិធីដាក់ពិន័យ | ២.មូលហេតុដែលប្រើវិធីនេះ |
|---|---|---|
| ក.សកម្មភាពគ្រូរបស់អ្នក | | |
| ខ.សកម្មភាពរបស់អ្នក | | |

គ.សូមមើលតារាងខាងលើ ហើយប្រៀបធៀបសកម្មភាពរបស់អ្នក ជាមួយសកម្មភាពគ្រូរបស់អ្នក។ តើរវាងអ្នកទាំងពីរ សកម្មភាពណាដែលមានប្រសិទ្ធភាពជាង ក្នុងការទប់ស្កាត់ការប្រព្រឹត្តិកំហុសនាពេលអនាគត? ហេតុអ្វី?

**សកម្មភាព៖** វិន័យបែបវិជ្ជមាន ឬអវិជ្ជមាន

ក្នុងតារាងខាងក្រោម តើសកម្មភាពដាក់ពិន័យណាមួយដែលមានលក្ខណៈវិជ្ជមាន ណាមួយអវិជ្ជមាន? សូមគូសសញ្ញាធីគនៅក្នុងប្រអប់ដែលសមស្រប។ បន្ទាប់មក នៅក្នុងជួរឈរចុងក្រោយ សូមជ្រើសរើសសកម្មភាពដែលអ្នកធ្លាប់បានអនុវត្ត ឬអាចនឹងអនុវត្តដើម្បីកែតម្រូវអាកប្បកិរិយាមិនសមរម្យរបស់កុមារ។ សូមជ្រើសរើសចម្លើយដោយស្មោះត្រង់។

| **សកម្មភាព** | **វិជ្ជមាន** | **អវិជ្ជមាន** | **តើអ្នកធ្លាប់ប្រើវិធីនេះដែរឬទេ? បាទ/ចាស/ទេ** |
|---|---|---|---|
| ១.ប្រមូលការចាប់អារម្មណ៍របស់សិស្សមុននឹងចាប់ផ្តើមមេរៀន | | | |
| ២.ប្រើវិធីបង្រៀនផ្ទាល់ (ប្រាប់សិស្សច្បាស់ៗតែម្តងថានឹងមានអ្វីកើតឡើង) | | | |
| ៣.ធ្វើការសន្ទត់ | | | |
| ៤.ចោទប្រកាន់ដោយគ្មានអំណះអំណាង | | | |
| ៥.ក្រោកឡើង ហើយដើរពិនិត្យសិស្សនៅក្នុងថ្នាក់ | | | |
| ៦.ប្រើកម្លាំងបាយ | | | |
| ៧.បង្គាប់បញ្ជា | | | |
| ៨.ធ្វើបង្ហាញនូវអ្វីដែលអ្នកចង់ឱ្យសិស្សធ្វើតាម | | | |
| ៩.កំណត់ជាទូទៅនូវអាកប្បកិរិយារបស់សិស្ស | | | |
| ១០.ប្រៀបធៀបសិស្សម្នាក់ជាមួយសិស្សផ្សេងទៀតជាសាធារណៈ | | | |
| ១១.បង្កើតបរិយាកាសថ្នាក់រៀនដែលអំណោយផលដល់ការទទួលបានចំណេះដឹងរបស់សិស្ស | | | |
| ១២.ប៉ាន់ប្រមាណពីបញ្ហាជាមុន | | | |
| ១៣.ទទូចថាអ្នកត្រឹមត្រូវ ហើយបង្ហាញអាកប្បកិរិយាជាអ្នកដែលមានអំណាចជាង | | | |
| ១៤.បង្កើតវិន័យច្បាស់លាស់ មានសង្គតភាពនិងរឹងមាំ។ | | | |

**ចម្លើយ៖** សកម្មភាពលេខ ១,២,៥,៨,១១,១២, និង១៤គឺជាសកម្មភាពវិជ្ជមាន។ សកម្មភាពលេខ ៣,៤,៦,៧,៩,១០ និង ១៣ គឺជាសកម្មភាពអវិជ្ជមាន។

## IV. សេចក្តីសន្និដ្ឋាន

ការពិភាក្សា និងអនុវត្តវិន័យបែបវិជ្ជមាននៅតាមស្ថានភាពផ្សេងៗគ្នានៅក្នុងថ្នាក់រៀន ជាវិធីណែនាំដ៏ល្អមួយសម្រាប់ជួយលោកគ្រូ អ្នកគ្រូក្នុងការដោះស្រាយបញ្ហាទូទៅដោយមិនប្រើប្រាស់អំពើហិង្សានៅក្នុងថ្នាក់រៀន។ ការអនុវត្តវិន័យបែបវិជ្ជមានអាចមានការពិបាកសម្រាប់លោកគ្រូអ្នកគ្រូនៅពេលដំបូង តែនៅពេលដែលពួកគេរៀនអនុវត្តពីមួយថ្ងៃទៅមួយថ្ងៃ ពួកគេនឹងទទួលបានអត្ថប្រយោជន៍ពីការអនុវត្ត វិន័យនេះ ដោយធ្វើឱ្យការទំនាក់ទំនង ការគោរពចំពោះគ្នា ការមានវិន័យល្អ និងធ្វើឱ្យបរិស្ថានថ្នាក់រៀនកាន់តែប្រសើរឡើង។ ជារួមការអនុវត្តវិន័យបែបវិជ្ជមានពិតជារួមចំណែកក្នុងការជួយឱ្យសាលារៀន ឆ្លើយតបនឹងសមភាពយេនឌ័រទាំងពេលបច្ចុប្បន្ន និងពេលអនាគត។ ដើម្បីទទួលបានខ្លឹមសារលម្អិតពាក់ព័ន្ធនឹងវិន័យបែបវិជ្ជមាន សូមអានឯកសារបំប៉នរបស់ VVOB ស្តីពីការគ្រប់គ្រងថ្នាក់រៀន។

# មេរៀនទី៦

## ការវាយតម្លៃអន្តរកម្ម និងផ្នត់គំនិតយេនឌ័រនៅក្នុងថ្នាក់រៀន

### I. សេចក្តីផ្តើម

គេអាចប្រើការវាយតម្លៃដើម្បីប្រមូល និងចែករំលែកជាមួយគ្រូបង្រៀន មាតាបិតា និងគ្រួសារសិស្សនូវព័ត៌មានសំខាន់ៗអំពីការរីកចម្រើន និងលូតលាស់របស់សិស្ស។ គេក៏អាចប្រើព័ត៌មានដែលទទួលបានពីការវាយតម្លៃដើម្បីកែសម្រួលការបង្រៀនឱ្យស្របទៅនឹងតម្រូវការជាក់លាក់របស់សិស្សផងដែរ។ ការធ្វើបែបនេះអាចញុំាងឱ្យការបង្រៀនកាន់តែមានប្រសិទ្ធភាព និងជួយឱ្យទទួលបានលទ្ធផលសិក្សាកាន់តែល្អប្រសើរ។ ដូចគ្នានេះដែរ ការវាយតម្លៃអន្តរកម្មយេនឌ័រ និងការប្រើប្រាស់ភាសាជួយឱ្យគ្រូយល់ពីជំនឿ និងការរំពឹងទុករបស់សិស្សអំពីយេនឌ័រ។ តាមរយៈព័ត៌មានទាំងនេះ គ្រូអាចដឹងពីវិធីបង្កើនភាពឆ្លើយតបនឹងសមភាពយេនឌ័រនៅក្នុងថ្នាក់រៀនរបស់គាត់បាន។ ពេលធ្វើការវាយតម្លៃ អ្នកក៏អាចលើកសរសើរអំពីឥរិយាបថដែលស្របតាមការរំពឹងទុករបស់អ្នកផងដែរ ឧទាហរណ៍៖ អាកប្បកិរិយាលេងសើចដែលឆ្លើយតបនឹងសមភាពយេនឌ័រ។ ការលើកសរសើរបែបនេះអាចជួយជំរុញទឹកចិត្តសិស្សកាន់តែខ្លាំងឡើងថែមទៀត។

គេអាចញែកភាពខុសគ្នារវាងការវាយតម្លៃក្នុងដំណើរការសិក្សា និងការវាយតម្លៃសរុប។ ការវាយតម្លៃសរុបមានគោលបំណងវាយតម្លៃលទ្ធផលសិក្សារបស់សិស្សធៀបនឹងស្តង់ដាណាមួយ នៅចុងបញ្ចប់នៃដំណាក់កាលសិក្សាមួយ (ប្រចាំខែ ប្រចាំឆមាស ប្រចាំឆ្នាំ)។ ផ្ទុយទៅវិញ គ្រូប្រើការវាយតម្លៃក្នុងដំណើរការសិក្សាដើម្បីត្រួតពិនិត្យកម្រិតយល់ដឹងរបស់សិស្ស ក្នុងគោលបំណងផ្តល់ព័ត៌មានត្រឡប់ ដើម្បីឱ្យការបង្រៀនរបស់គាត់ និងលទ្ធផលសិក្សារបស់សិស្សកាន់តែប្រសើរឡើង[24]។ ការត្រួតពិនិត្យជាប់ជាប្រចាំនូវជំនឿ និងការរំពឹងទុករបស់សិស្សអំពីយេនឌ័រ ជារឿងសំខាន់។ ហេតុនេះ ក្នុងមេរៀននេះ យើងនឹងផ្តោតសំខាន់លើការវាយតម្លៃក្នុងដំណើរការសិក្សា។

### II. វត្ថុបំណង

- ស្វែងយល់ពីភាពចាំបាច់នៃការវាយតម្លៃអន្តរកម្មយេនឌ័រ
- ចាត់វិធានការដើម្បីសង្កេតសិស្ស និងកំណត់ផ្នត់គំនិតនៅក្នុងថ្នាក់រៀន។

[24] VVOB (2007). Learner-centered methodology. Training manual for pre-service and in-service training of primary school teachers. Cambodia.

## III. ខ្លឹមសារ

ការវាយតម្លៃក្នុងដំណើរការសិក្សាអំពីយេនឌ័រត្រួតពិនិត្យអាកប្បកិរិយាឆ្លើយតបនឹងយេនឌ័ររបស់សិស្ស។ គ្រូអាចប្រើព័ត៌មាននោះដើម្បីកែលម្អសកម្មភាពបង្រៀន និងរៀនឱ្យឆ្លើយតបនឹងសមភាពយេនឌ័រ (សូមមើលផ្នែកទី១)។ បន្ទាប់មក ផ្អែកលើការវាយតម្លៃនេះសិស្សរបស់អ្នកអាចរីកចម្រើន និងកាន់តែមានការយល់ដឹង នឹងឆ្លើយតបកាន់តែប្រសើរចំពោះសមភាពយេនឌ័រ (ផ្នែកទី២)។

### ១.ការសង្កេតរបស់គ្រូ

ការសង្កេតអន្តរកម្មរវាងសិស្សប្រុស និងសិស្សស្រីក្នុងថ្នាក់រៀនជួយឱ្យអ្នកអាចវាយតម្លៃបានពីកម្រិតឆ្លើយតបនឹងសមភាពយេនឌ័រនៃថ្នាក់រៀនរបស់អ្នក។ សូមប្រើប្រាស់ព័ត៌មានដែលអ្នកប្រមូលបានដើម្បីបង្កើនភាពឆ្លើយតបនឹងសមភាពយេនឌ័រ។

វិធីល្អបំផុតដើម្បីវាយតម្លៃសិស្សគឺតាមរយៈ**ការសង្កេតជាប្រចាំ**។ តាមរយៈការសង្កេត អ្នកអាចសម្គាល់ឃើញថាផ្នត់គំនិតណាខ្លះដែលកើតមានញឹកញាប់នៅក្នុងថ្នាក់រៀនរបស់អ្នក ហើយក៏អាចដឹងផងដែរថាតើផ្នត់គំនិតទាំងនេះបានរាំងស្ទះដល់ដំណើរការរៀនសូត្ររបស់សិស្សដែរឬទេះ

- ឆ្លុះបញ្ចាំងពីអាកប្បកិរិយាមួយចំនួនរបស់សិស្សប្រុសក្នុងថ្នាក់រៀន (និងក្នុងសាលារៀនជាទូទៅ) ដែលអ្នកសង្កេតឃើញ ដែលអាចរំខានដល់ការរៀនសូត្ររបស់សិស្សស្រី និងផ្ទុយមកវិញ សង្កេតមើលអាកប្បកិរិយារបស់សិស្សស្រី ដែលអាចរំខានដល់ការរៀនសូត្ររបស់សិស្សប្រុស។

  ឧទាហរណ៍ៈ

  - នៅទីធ្លាសម្រាប់លេងកំសាន្ត ក្មេងប្រុសអាចនឹងប្រើបាល់ដែលមានទាំងអស់សម្រាប់លេងកីឡាបាល់ទាត់ ធ្វើឱ្យក្មេងស្រីមិនមានបាល់សម្រាប់លេងល្បែងផ្សេងៗទៀតបាន។
  - ពេលរៀបចំកិច្ចការក្រុម អ្នកសង្កេតឃើញថាមានសិស្សស្រី ៣នាក់នៅក្នុងថ្នាក់តែងតែចង់នៅក្នុងក្រុមជាមួយគ្នាជានិច្ច។ នេះបណ្តាលមកពីសិស្សស្រីចង់មានមិត្តភក្តិជិតស្និទ្ធម្នាក់ឬ២នាក់ ហើយអាចចែករំលែកមនោសញ្ចេតនា និងអារម្មណ៍ជាមួយគ្នាបាន។
  - ពេលសិស្សធ្វើការជាក្រុមចម្រុះភេទលើកិច្ចការមួយនៅក្នុងថ្នាក់រៀន អ្នកបានសង្កេតឃើញថាសិស្សប្រុសមានទំនោរមិនស្តាប់យោបល់ និងការចូលរួមរបស់សិស្សស្រីក្នុងការងារក្រុមនោះទេ។

- អ្នកសង្កេតឃើញថា ជាមធ្យម សិស្សប្រុសនៅក្នុងថ្នាក់រៀនរបស់អ្នកហ៊ានបញ្ចេញមតិនៅក្នុងការពិភាក្សាក្នុងថ្នាក់រៀនទាំងមូល។

ការឆ្លើយតបរបស់អ្នកទៅនឹងអាកប្បកិរិយាទាំងនេះអាចបង្កើតបរិស្ថានសិក្សាដែលឆ្លើយតបនឹងសមភាពយេនឌ័រ និងមានភាពស្មើគ្នាប្រសើរជាងមុន។ ខ្លឹមសារនៅក្នុងផ្នែកមុននៃមេរៀននេះអាចជាជំនួយដល់អ្នកក្នុងការឆ្លើយតបទៅនឹងឥរិយាបថទាំងនេះបាន។

- ក្នុងអំឡុងពេលសង្កេត (ទោះជាបានត្រៀមទុក ឬមិនបានត្រៀមទុកជាមុនក្តី) សូមផ្តោតលើទឹកមុខរបស់សិស្ស កាយវិការ ពាក្យសម្តី សកម្មភាព ចម្រៀង របាំ រូបភាព និងសំណេររបស់សិស្សផង ដែរ។ នៅក្នុងការវាយតម្លៃដែលបានត្រៀមទុកជាមុន សូមធ្វើការកត់ត្រាខ្លីៗអំពីអន្តរកម្មយេនឌ័រ និងអាកប្បកិរិយារបស់សិស្សនៅក្នុងកំណត់ត្រារបស់ពួកគេរៀងៗខ្លួន។ សូមសរសេរព័ត៌មានដែលពាក់ព័ន្ធចូលទាំងអស់។ ព័ត៌មានទាំងនេះអាចជួយអ្នកដើម្បីរៀបចំផែនការ និងចាត់វិធានការសមស្របបាន។
- អ្នកអាចសួរសិស្សជាបុគ្គលនូវសំណួរដែលអាចជួយឱ្យអ្នកវាស់វែងបានពីកម្រិតយល់ដឹង និងផ្នត់គំនិតរបស់ពួកគេពាក់ព័ន្ធនឹងយេនឌ័រ។ ខាងក្រោមនេះគឺជាសំណួរមួយចំនួនដែលអ្នកអាចកែសម្រួលប្រើប្រាស់បានឱ្យស្របទៅតាមស្ថានភាពរបស់អ្នក៖
    - តើប្អូនចង់ធ្វើការងារអ្វីពេលប្អូនធំឡើង? ហេតុអ្វី?
    - តើប្អូនចូលចិត្តកីឡាអ្វីខ្លះ? ហេតុអ្វី?
    - តើប្អូនគិតថាអ្នកណាគួរលាងចាននៅផ្ទះ? ហេតុអ្វី? តើអ្នកណាគួរបោសសម្អាតផ្ទះ? ហេតុអ្វី? តើអ្នកណាគួរលេងប្អូនប្រុសរបស់ប្អូនឱ្យដេក? ហេតុអ្វី? (អ្នកអាចបន្ថែមសំណួរបានដោយផ្អែកលើកិច្ចការផ្ទះផ្សេងៗទៀតដែលអ្នកគិតថាអាចប្រើប្រាស់បាន)
    - តើប្អូនទទួលបានរបស់លេងអ្វីជាកាដូ? តើរបស់លេងទាំងនេះមានពណ៌អ្វី? តើពណ៌ទាំងនេះសំខាន់ទេ?
- សូមបង្កើតឧបករណ៍សង្កេតដែលទាក់ទងនឹងយេនឌ័រដោយខ្លួនឯង ដែលអាចប្រើប្រាស់បាននៅក្នុងបរិបទរបស់អ្នកផ្ទាល់។ ខាងក្រោមនេះគឺជាគំរូឧបករណ៍សង្កេតមួយ។

## គំរូឧបករណ៍សង្កេត

គំរូបញ្ជីផ្ទៀងផ្ទាត់ខាងក្រោមនេះអាចប្រើបានសម្រាប់សង្កេតអាកប្បកិរិយារបស់សិស្សនៅក្នុងថ្នាក់បាន។ អ្នកអាចកែសម្រួល និងបន្ថែមខ្លឹមសារទៅក្នុងបញ្ជីផ្ទៀងផ្ទាត់នេះ ដើម្បីឱ្យស្របតាមតម្រូវការថ្នាក់រៀនរបស់អ្នក។

| **ឈ្មោះសិស្ស** ....................................... | **សូមគូសសញ្ញា ត្រង់ចម្លើយដែលត្រឹមត្រូវ** | **ព័ត៌មានបន្ថែម** |
|---|---|---|
| មានអន្តរកម្មជាមួយមិត្តរួមថ្នាក់ដែលមានភេទផ្ទុយគ្នា | | ជាមួយអ្នកណា? |
| មិនមានភាពខុសប្លែកគ្នានៅក្នុងភាសាកាយវិការពេលជជែកជាមួយមិត្តរួមថ្នាក់ដែលមានភេទផ្ទុយគ្នា | | សេចក្តីពណ៌នា |
| មានទំនាក់ទំនងជាមួយមិត្តរួមថ្នាក់ដែលមានភេទផ្ទុយគ្នាក្នុងអំឡុងសកម្មភាពសិក្សា | | ប៉ុន្មានលើក? ជាសកម្មភាពប្រភេទណា? |
| មានប្រតិកម្មវិជ្ជមានចំពោះសម្ភារឧបទេសដែលឆ្លើយតបនឹងសមភាពយេនឌ័រ ឧទាហរណ៍៖ មិនសើចចំអក ឬនិយាយថាស្ត្រីមិនអាចធ្វើជាវេជ្ជបណ្ឌិតបាន | | យ៉ាងដូចម្តេច? |
| អន្តរាគមន៍ (ឧទាហរណ៍៖ ការឆ្លើយតប កិច្ចការផ្ទះ) មិនមាន | | សេចក្តីពណ៌នា |

| | | |
|---|---|---|
| បង្កប់ផ្នត់គំនិត | | |
| រឿងនិទានដែលមិនបង្កើនផ្នត់គំនិតយេនឌ័រ | | សេចក្តីពណ៌នា |
| នៅទីធ្លាសម្រាប់លេងកំសាន្ត សិស្សលេងជាមួយសិស្សផ្សេងទៀតដែលមានភេទផ្ទុយគ្នា។ | | ជាមួយអ្នកណា? |

## ២.ការឆ្លុះបញ្ចាំងរបស់សិស្សអំពីយេនឌ័រ[25]

នៅក្នុងថ្នាក់រៀនមួយដែលមានលក្ខណៈសិស្សមជ្ឈមណ្ឌល ហើយឆ្លើយតបនឹងសមភាពយេនឌ័រ សិស្សត្រូវបានលើកទឹកចិត្តឱ្យម្ចាស់ការលើការសិក្សារៀនសូត្ររបស់ខ្លួន។ ដូចគ្នានេះដែរ គ្រូគប្បីលើកទឹកចិត្តសិស្សឱ្យឆ្លុះបញ្ចាំងអំពីយេនឌ័រ ថាតើនៅមានចំណុចណាខ្លះដែលគួរកែលំអ ឱ្យថ្នាក់រៀនរបស់ពួកគេកាន់តែមានភាពឆ្លើយតបនឹងសមភាពយេនឌ័រ។ ខាងក្រោមនេះគឺជាឧទាហរណ៍មួយចំនួនៈ

- រួមគ្នាវិភាគបញ្ហាប្រឈម និងកំណត់សញ្ញានៃថ្នាក់រៀនដែលមិនទាន់ឆ្លើយតបនឹងសមភាពយេនឌ័រ និងពិភាក្សាគ្នារកដំណោះស្រាយៈ សិស្សអាចយល់ពីមូលហេតុដែលញ៉ាំងឱ្យថ្នាក់រៀនមួយមិនទាន់ឆ្លើយតបនឹងសមភាពយេនឌ័រ និងជួយរកដំណោះស្រាយដោយប្រើវិធីពិភាក្សាមួយចំនួនដូចជាការធ្វើផែនទីគំនិត ការបង្កើតដើមឈើបញ្ហា។ល។ ពេញមួយឆ្នាំសិក្សា គ្រូអាចលើកយកបញ្ហាបញ្ហានេះ និងដំណោះស្រាយដែលបានរកឃើញមកពិភាក្សាដើម្បីពិនិត្យមើលវឌ្ឍនភាពនៃការដោះស្រាយបញ្ហាទាំងនេះ។ គ្រូ និងសិស្សអាចរួមគ្នាកំណត់បទដ្ឋានរួមសម្រាប់ថ្នាក់រៀនដែលគាំទ្រវិធីបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រៈ ពេលដែលសិស្សចូលរួម និងមានភាពម្ចាស់ការលើដំណើរការបង្កើតបទដ្ឋានថ្នាក់រៀន បទដ្ឋានដែលបង្កើតបាន បានឆ្លុះបញ្ចាំងពីគុណតម្លៃរបស់សិស្ស និងបញ្ហាដែលពួកគេមើលឃើញ។ បន្ទាប់មក សិស្សមានទំនោរនឹងអនុវត្តឱ្យស្របតាមបទដ្ឋាននោះ។ ឧទាហរណ៍ៈ ដោយផ្តោតទៅលើសិទ្ធិ អ្នកអាចសួរសិស្សឱ្យរកអាកប្បកិរិយាណាខ្លះដែលអាចទទួលយកបាន អាកប្បកិរិយាណាខ្លះដែលមិនអាចទទួលយកបានដោយសារប៉ះពាល់ដល់សិទ្ធិរបស់អ្នកដទៃ។

[25] FAWE. (2020). Gender Responsive Pedagogy Toolkit for Teachers and Schools 2nd Edition. Nairobi: FAWE.

- ពិនិត្យមើលគោលការណ៍ថ្នាក់រៀនជាប្រចាំ ថាតើមានចំណុចណាមួយដែលលែងចាំបាច់ អាចលុបចេញបានដែរឬទេ។ បើមានចំណុចដែលលែងចាំបាច់ហើយ អ្នកអាចលើកសរសើរសិស្សរបស់អ្នក ហើយសួរពួកគេថាតើមានគោលការណ៍ណាមួយផ្សេងទៀតដែលគេចង់បន្ថែមចូលដែរឬទេ។
- សិស្សអាចធ្វើស្វ័យវាយតម្លៃអាកប្បកិរិយារបស់ខ្លួន៖ ពេលដែលគ្រូអាចកែលំអការបង្រៀនរបស់គាត់តាមរយៈការឆ្លុះបញ្ចាំង និងស្វ័យវាយតម្លៃ (សូមមើលមេរៀនទី៧ នៅទំព័រទី១០៦) សិស្សអាចឆ្លុះបញ្ចាំងពីអាកប្បកិរិយារបស់ខ្លួនឯងតាមការស្វ័យវាយតម្លៃដែរ ដោយគ្រូជាអ្នកសម្របសម្រួល។

## IV. សេចក្តីសន្និដ្ឋាន

ការវាយតម្លៃកម្រិតនៃភាពឆ្លើយតបនឹងសមភាពយេនឌ័រនៅក្នុងថ្នាក់រៀនជួយឱ្យគ្រូកាន់តែយល់ច្បាស់ពីអាកប្បកិរិយារបស់សិស្ស ការប្រើប្រាស់ភាសា និងការចូលរួមក្នុងសកម្មភាពសិក្សា។ ការឆាប់រកឃើញផ្នត់គំនិតយេនឌ័រនៅក្នុងថ្នាក់រៀនជួយឱ្យគ្រូអាចដោះស្រាយបញ្ហាបានដោយខ្លួនឯង ឬតាមរយៈការស្នើសុំជំនួយទាន់ពេលវេលាពីភាគីពាក់ព័ន្ធដើម្បីបង្កើតបរិយាកាសរៀនសូត្រមួយដែលឆ្លើយតបនឹងសមភាពយេនឌ័រ។

# មេរៀនទី៧

## ការឆ្លុះបញ្ចាំងពីគ្រូបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ

### I. សេចក្តីផ្តើម

មានពាក្យស្លោកមួយបានលើកឡើងថា ប្រសិនបើយើងមិនដឹងពីគោលដៅដែលយើងត្រូវទៅទេនោះ យើងនឹងមិនដឹងថាយើងបានទៅដល់ហើយ ឬនៅនោះទេ ហើយផ្លូវណាក៏អាចនាំយើងទៅដល់ទីនោះដែរ។ ក្របខ័ណ្ឌត្រួតពិនិត្យ តាមដាន និងវាយតម្លៃមួយដ៏រឹងមាំ នឹងបង្ហាញគោលដៅយ៉ាងច្បាស់ដែលក្នុងករណីនេះគឺជាភាពឆ្លើយតបនឹងសមភាពយេនឌ័រ ហើយក្របខ័ណ្ឌត្រួតពិនិត្យ និងវាយតម្លៃនេះនឹងក្លាយជាផែនទីបង្ហាញផ្លូវសម្រាប់តាមដាន និងវាយតម្លៃវឌ្ឍនភាពឆ្ពោះទៅរកគោលដៅ។ ក្របខ័ណ្ឌនេះនឹងជួយឱ្យអ្នកបន្តដើរលើផ្លូវមួយដែលត្រឹមត្រូវ និងផ្តល់ស្លាកសញ្ញាចង្អុលផ្លូវឱ្យអ្នកដឹងថាកំពុងធ្វើដំណើរលើផ្លូវមួយដែលត្រឹមត្រូវហើយ។ មិនតែប៉ុណ្ណោះ ក្របខណ្ឌមួយនេះនឹងជួយឱ្យអ្នកអាចកំណត់បានថាបានដើរដល់គោលដៅដែលចង់ទៅដែរឬទេ។

### II. វត្ថុបំណង

- ប្រាប់បានពីតួនាទីដែលគ្រូបង្រៀនម្នាក់អាចធ្វើបាននៅក្នុងដំណើរការពិនិត្យតាមដាន និងវាយតម្លៃការឆ្លើយតបនឹងសមភាពយេនឌ័រ
- ពន្យល់បានពីវិធីដែលគ្រូបង្រៀនអាចកំណត់កម្រិតឆ្លើយតបនឹងសមភាពយេនឌ័រ។

### III. ខ្លឹមសារ

#### ១.ការចូលរួមក្នុងការពិនិត្យតាមដាន និងវាយតម្លៃ

ការប្រែក្លាយសាលារៀនមួយទៅជាបរិស្ថានដែលឆ្លើយតបនឹងសមភាពយេនឌ័រគឺជាបញ្ហាធំមួយដែលត្រូវការការចូលរួមរបស់ដៃគូពាក់ព័ន្ធទាំងអស់រួមមានមាតាបិតា អាណាព្យាបាល សិស្ស គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនជាដើម។ ក្នុងនាមជាគ្រូបង្រៀនម្នាក់ អ្នកមានតួនាទីនៅក្នុងដំណើរការនេះ ដោយផ្តើមចេញពីស្ថានភាពដែលកើតឡើងនៅក្នុងថ្នាក់រៀនរបស់អ្នក។

អ្នកអាចចូលរួមក្នុងការត្រួតពិនិត្យតាមដាន និងវាយតម្លៃតាមរយៈ៖

- ការកំណត់គោលដៅ និងវត្ថុបំណងសម្រាប់ការផ្លាស់ប្តូរឥរិយាបទរបស់ពួកគេ និងស្ថានភាពនៅក្នុងថ្នាក់រៀន

- ប្រជុំទៀងទាត់ជាមួយគ្រូផ្សេងទៀត និងសិស្សដើម្បីពិភាក្សាអំពីការផ្លាស់ប្ដូរវិធីបង្រៀនឱ្យឆ្លើយតបនឹងសមភាពយេនឌ័រ

- សរសេរ និងបង្ហាញរបាយការណ៍យ៉ាងទៀងទាត់ទៅគណៈគ្រប់គ្រងសាលារៀន

- រក្សាទុកជាឯកសារនូវកត្តាផ្សេងៗដែលបានជួយឱ្យលំនាំបង្រៀន និងរៀនឆ្លើយតបនឹងសមភាពយេនឌ័រ

- ចែករំលែកលទ្ធផល និងបទពិសោធន៍ជាមួយគ្រូបង្រៀនផ្សេងទៀត ជាមួយសិស្ស ជាមួយថ្នាក់ដឹកនាំសាលារៀន និងដៃគូពាក់ព័ន្ធផ្សេងៗទៀតដែលរួមមានអ្នកបង្កើតគោលនយោបាយ និងអ្នកអនុវត្តផ្សេងៗទៀតពាក់ព័ន្ធនឹងសាលារៀន និងការងារអប់រំ។

## ២.ឧបករណ៍សម្រាប់ឆ្លុះបញ្ចាំង

អ្នកអាចប្រើបញ្ជីផ្ទៀងផ្ទាត់ខាងក្រោមជាឧបករណ៍ឆ្លុះបញ្ចាំងដើម្បីវាស់ថាក្នុងនាមជាគ្រូបង្រៀនម្នាក់ តើអ្នកមានលក្ខណៈឆ្លើយតបនឹងយេនឌ័រដល់កម្រិតណា។ ការរកឃើញនេះអាចជួយឱ្យអ្នកសម្រេចចិត្តបានថាផ្នែកណាខ្លះដែលអ្នកត្រូវកែលម្អ និងផ្នែកណាមួយនៅក្នុងសៀវភៅណែនាំដែលអ្នកអាចរកបានព័ត៌មានពាក់ព័ន្ធដើម្បីជួយអ្នកបាន។

អ្នកក៏អាចប្រើឧបករណ៍ឆ្លុះបញ្ចាំងនេះជាក្រុមជាមួយគ្រូផ្សេងៗទៀតដែរ។ ដំបូង អ្នកបំពេញព័ត៌មានក្នុងឧបករណ៍ឆ្លុះបញ្ចាំងនេះរៀងៗខ្លួនជាមុនសិន បន្ទាប់មកយកពិន្ទុដែលទទួលបានមកពិភាក្សាគ្នាជាក្រុម។ អ្នកអាចជួយគ្នាគិតអំពីកម្រិតឆ្លើយតបនឹងសមភាពយេនឌ័រ បន្ទាប់មកស្វែងរកគំនិតពាក់ព័ន្ធនឹងវិធីបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ និងអន្តរាគមន៍ផ្សេងៗក្នុងទម្រង់ជាសហគមន៍សិក្សាអាជីពមួយ។ អ្នកអាចសួរសំណួរ និងផ្ដល់ព័ត៌មានត្រឡប់ឱ្យគ្នាទៅវិញទៅមកបាន។ ឧទាហរណ៍៖

- តើអ្នកយល់យ៉ាងដូចម្ដេចចំពោះពិន្ទុរបស់ខ្ញុំ? តើអ្នកគិតថាខ្ញុំដាក់ពិន្ទុឱ្យខ្លួនឯងបានត្រឹមត្រូវដែរឬទេ? តើអ្នកគិតថាខ្ញុំអាចកែលម្អចំណុចណាខ្លះ?

- ហេតុអ្វីបានជាត្រង់ចំណុចមួយនេះអ្នកដាក់ពិន្ទុឱ្យខ្លួនឯងទាប/ខ្ពស់ម្ល៉េះ?

- ត្រង់ចំណុចមួយនេះអ្នកធ្វើបានល្អណាស់។ តើអ្នកអាចប្រាប់ខ្ញុំបានទេថាអ្នកធ្វើអ្វីខ្លះបានជាអាចញ៉ាំងឱ្យចំណុចមួយនេះល្អប្រសើរយ៉ាងនេះ?

- គ្នាយើងមួយចំនួន នៅធ្វើចំណុចមួយនេះមិនទាន់បានល្អទេ។ តើយើងគួរធ្វើអ្វីខ្លះដើម្បីកែលម្អចំណុចនេះបាន?

ជួនកាល អ្នកពិបាកនឹងឆ្លុះបញ្ចាំងអំពីអន្តរកម្ម ពេលដែលអ្នកកំពុងបង្រៀន។ ហេតុនេះ ជាការប្រសើរ អ្នកគប្បីស្វែងរកជំនួយពីបុគ្គលផ្សេងទៀត។ ប្រហែលជាមិត្តរួមការងារដែលយកចិត្តទុកដាក់លើ

វិធីបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ ឬគណៈគ្រប់គ្រងសាលារៀនអាចជួយសង្កេតការបង្រៀនរបស់អ្នកបាន។ អ្នកសង្កេតអាចប្រើឧបករណ៍ឆ្លុះបញ្ចាំងជាបញ្ជីផ្ទៀងផ្ទាត់ក្នុងអំឡុងពេលសង្កេតបាន។

## ទម្រង់វាយតម្លៃគ្រូបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ

| | មិនធ្លាប់ | ម្ដងម្កាល | ញឹកញាប់ | គ្រប់ពេល | ឧទាហរណ៍ អាកប្បកិរិយារបស់ខ្ញុំ |
|---|---|---|---|---|---|
| **ភាពលម្អៀងយេនឌ័រ (ជំពូកទី១ មេរៀនទី៣ ទំព័រទី៣២)** | | | | | |
| ខ្ញុំគិតអំពីភាពលម្អៀងយេនឌ័ររបស់ខ្ញុំ និងផលប៉ះពាល់របស់វាចំពោះសិស្សរបស់ខ្ញុំ ។ | | | | | |
| ខ្ញុំដឹងថាខ្ញុំអាចមានភាពលម្អៀងយេនឌ័រដោយមិនដឹងខ្លួន ។ | | | | | |
| ខ្ញុំពិភាក្សាអំពីភាពលម្អៀងយេនឌ័ររបស់ខ្ញុំជាមួយគ្រូបង្រៀនផ្សេងទៀត ។ | | | | | |
| **ផ្អែកលើការឆ្លុះបញ្ចាំងរបស់ខ្ញុំ ខ្ញុំចាត់វិធានការដូចខាងក្រោម៖** | | | | | |
| **ការរៀបចំកិច្ចតែងការ (ជំពូកទី២ មេរៀនទី១ ទំព័រទី៦២)** | | | | | |
| ខ្ញុំរៀបចំផែនការសកម្មភាពមួយចំនួនដើម្បីផ្តល់ឱកាសរៀនសូត្រដល់សិស្សគ្រប់ៗគ្នា ។ | | | | | |
| ខ្ញុំរៀបចំសកម្មភាពឱ្យមានអន្តរកម្មទាំងសិស្សប្រុស និងសិស្សស្រី ។ | | | | | |
| ខ្ញុំត្រៀមសំណួរសម្រាប់សួរសិស្សដែលជួយបញ្ចៀសការបង្កើតផ្នត់គំនិតយេនឌ័រ ។ | | | | | |
| **ផ្អែកលើការឆ្លុះបញ្ចាំងរបស់ខ្ញុំ ខ្ញុំចាត់វិធានការដូចខាងក្រោម៖** | | | | | |
| **ការបង្រៀនខ្លឹមសារមេរៀន (ជំពូកទី២ មេរៀនទី៣ ទំព័រទី៧៤)** | | | | | |
| ខ្ញុំលើកទឹកចិត្ត និងតាមដានការចូលរួមរបស់សិស្សគ្រប់ៗគ្នា ។ | | | | | |

| | មិនធ្លាប់ | ម្តងម្កាល | ញឹកញាប់ | គ្រប់ពេល | ឧទាហរណ៍ អាកប្បកិរិយារបស់ខ្ញុំ |
|---|---|---|---|---|---|
| ខ្ញុំដាក់កិច្ចការដូចគ្នាឱ្យសិស្សប្រុស និងសិស្សស្រីធ្វើ ។ | | | | | |
| ខ្ញុំលើកទឹកចិត្តសិស្សឱ្យចូលរួមក្នុងការសន្ទនាដែលជួយឱ្យពួកគេគិតអំពីតួនាទីយេនឌ័រ ។ | | | | | |
| ខ្ញុំអន្តរាគមន៍ពេលដែលសម្ពាធពីមិត្តរួមថ្នាក់ធ្វើឱ្យសិស្សមិនហ៊ានចូលរួមស្វែងយល់ពីតួនាទីយេនឌ័រផ្សេងៗគ្នា ។ | | | | | |
| **ផ្អែកលើការឆ្លុះបញ្ចាំងរបស់ខ្ញុំ ខ្ញុំចាត់វិធានការដូចខាងក្រោម៖** | | | | | |
| **សម្ភារបង្រៀន និងរៀន (ជំពូកទី២ មេរៀនទី២ ទំព័រទី៦៧)** | | | | | |
| ខ្ញុំពិនិត្យមើលសម្ភារបង្រៀន និងរៀនដើម្បីរកផ្នត់គំនិតយេនឌ័រ ។ | | | | | |
| ខ្ញុំលើកទឹកចិត្តឱ្យសិស្សពិភាក្សាគ្នាអំពីផ្នត់គំនិតយេនឌ័រដែលយើងជួបប្រទះ នៅក្នុងសៀវភៅសិក្សា និងនៅក្នុងសម្ភារបង្រៀន និងរៀនផ្សេងៗទៀត ។ | | | | | |
| ខ្ញុំកែសម្រួលពាក្យពេចន៍ និងរូបភាពនៅក្នុងសម្ភារបង្រៀននិងរៀនឱ្យកាន់តែមានលក្ខណៈឆ្លើយតបនឹងសមភាពយេនឌ័រ ។ | | | | | |
| ខ្ញុំផលិតសម្ភារបង្រៀន និងរៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ ។ | | | | | |
| **ផ្អែកលើការឆ្លុះបញ្ចាំងរបស់ខ្ញុំ ខ្ញុំចាត់វិធានការដូចខាងក្រោម៖** | | | | | |
| **ភាសា និងអន្តរកម្មនៅក្នុងថ្នាក់រៀន (ជំពូកទី២ មេរៀនទី៣ ទំព័រទី៧៤)** | | | | | |
| ខ្ញុំប្រើពាក្យពេចន៍សុភាពរាបសា សម្លឹងមើលចំភ្នែក និងបង្ហាញភាពទន់ភ្លន់ចំពោះសិស្សគ្រប់ៗគ្នា ។ | | | | | |
| ខ្ញុំប្រើភាសា និងសម្លេងដូចគ្នាចំពោះទាំងសិស្សប្រុស និងសិស្សស្រី ។ | | | | | |
| ខ្ញុំប្រុងប្រយ័ត្នដើម្បីចៀសវាងការប្រើពាក្យពេចន៍មួយចំនួនដែលប៉ះ | | | | | |

| | មិនធ្លាប់ | ម្ដងម្កាល | ញឹកញាប់ | គ្រប់ពេល | ឧទាហរណ៍ អាកប្បកិរិយារបស់ខ្ញុំ |
|---|---|---|---|---|---|
| ពាល់យេនឌ័រ ឧទាហរណ៍ ខ្ញុំហៅឈ្មោះពួកគេ ជាជាងការហៅគេថា ក្មេងប្រុស ឬក្មេងស្រី ។ | | | | | |
| ខ្ញុំលើកសរសើរឥរិយាបថល្អរបស់សិស្សគ្រប់គ្នាតាមរបៀបដែលមិន បង្កើតផ្នត់គំនិតយេនឌ័រ ។ | | | | | |
| វិន័យក្នុងថ្នាក់រៀនរបស់ខ្ញុំផ្ដោតលើការគោរពចំពោះមនុស្សគ្រប់គ្នា ។ | | | | | |
| ខ្ញុំផ្ដល់ឱកាសស្មើៗគ្នាឱ្យសិស្សប្រុស និងសិស្សស្រីឆ្លើយសំណួរ ឡើង បង្ហាញលទ្ធផល ឬធ្វើសកម្មភាពផ្សេងៗទៀត ។ | | | | | |
| ខ្ញុំធ្វើជាបុគ្គលគំរូដែលមានភាពវិជ្ជមានសម្រាប់ក្មេងប្រុស និងក្មេងស្រី ហើយខ្ញុំលុបបំបាត់តួនាទីយេនឌ័រដែលបង្កប់ផ្នត់គំនិតយេនឌ័រនៅក្នុង សកម្មភាពរបស់ខ្ញុំ ។ | | | | | |
| ខ្ញុំលើកឧទាហរណ៍អំពីបុគ្គលគំរូដែលលុបបំបាត់តួនាទីយេនឌ័រដែល មានបង្កប់ផ្នត់គំនិតយេនឌ័រ ។ | | | | | |
| ខ្ញុំយល់ដឹងច្រើនអំពីសកម្មភាពវប្បធម៌ បទដ្ឋាន និងជំនឿក្នុងមូលដ្ឋាន ដែលបញ្ជាក់ពីផ្នត់គំនិតយេនឌ័រ ។ | | | | | |
| **ផ្អែកលើការឆ្លុះបញ្ចាំងរបស់ខ្ញុំ ខ្ញុំចាត់វិធានការដូចខាងក្រោម៖** | | | | | |
| **ការរៀបចំថ្នាក់រៀន (ជំពូកទី២ មេរៀនទី៤ ទំព័រទី៨៣)** | | | | | |
| ការរៀបចំកន្លែងអង្គុយក្នុងថ្នាក់រៀនរបស់ខ្ញុំជួយឱ្យសិស្សអាចចូលរួម បានគ្រប់ៗគ្នា ។ | | | | | |
| ខ្ញុំប្រើវិធីផ្សេងៗគ្នាដើម្បីចែកសិស្សជាក្រុមដើម្បីឱ្យពួកគេអាចសហការ និងបង្កើតទំនាក់ទំនងជាមួយសិស្សស្រី និងសិស្សប្រុសជាច្រើននាក់ ទៀត និងទទួលតួនាទីផ្សេងៗគ្នានៅក្នុងកិច្ចការក្រុម ។ | | | | | |
| ខ្ញុំលើកទឹកចិត្តសិស្សឱ្យចូលរួមក្នុងសកម្មភាពផ្សេងៗគ្នាដោយមិន | | | | | |

| | មិនធ្លាប់ | ម្តងម្កាល | ញឹកញាប់ | គ្រប់ពេល | ឧទាហរណ៍ អាកប្បកិរិយារបស់ខ្ញុំ |
|---|---|---|---|---|---|
| ប្រកាន់ភេទ ។ | | | | | |
| **ផ្អែកលើការឆ្លុះបញ្ចាំងរបស់ខ្ញុំ ខ្ញុំចាត់វិធានការដូចខាងក្រោម៖** | | | | | |
| **វិន័យបែបវិជ្ជមាន (ជំពូកទី២ មេរៀនទី៥ ទំព័រទី៩១)** | | | | | |
| ខ្ញុំតែងពន្យល់ហេតុផលនៃការប្រើប្រាស់វិន័យ និងហេតុផលនៃការសម្រេចចិត្តរបស់ខ្ញុំជានិច្ច ។ | | | | | |
| ខ្ញុំត្រួតពិនិត្យសកម្មភាពថ្នាក់រៀន និងផ្តល់ព័ត៌មានត្រឡប់ឱ្យសិស្សពាក់ព័ន្ធនឹងអាកប្បកិរិយារបស់ពួកគេ ។ | | | | | |
| ពេលដែលមានសិស្សម្នាក់ប្រព្រឹត្តិមិនគប្បី ខ្ញុំស្តីបន្ទោសឱ្យពួកគេតាមបែបម៉ឹងម៉ាត់ តែសុភាពរាបសា។ ប្រសិនបើត្រូវការដាក់ពិន័យ ខ្ញុំគិតដល់ស្ថានភាពនេះដោយប្រយ័ត្នប្រយែង។ | | | | | |
| **ផ្អែកលើការឆ្លុះបញ្ចាំងរបស់ខ្ញុំ ខ្ញុំចាត់វិធានការដូចខាងក្រោម៖** | | | | | |
| **ការវាយតម្លៃអន្តរកម្ម និងផ្នត់គំនិតយេនឌ័រក្នុងថ្នាក់រៀន (ជំពូកទី២ មេរៀនទី៦ ទំព័រទី១០០)** | | | | | |
| ក្នុងអំឡុងពេលសង្កេត និងវាយតម្លៃដែលបានត្រៀមទុកជាមុន ខ្ញុំកត់ត្រាអន្តរកម្មយេនឌ័រ និងឥរិយាបថយេនឌ័ររបស់សិស្ស។ | | | | | |
| ខ្ញុំប្រើប្រាស់កំណត់ត្រាវាយតម្លៃទាំងនេះដើម្បីរៀបចំផែនការមេរៀនក្រោយ និងអន្តរាគមន៍របស់ខ្ញុំនាពេលអនាគត ។ | | | | | |
| **ផ្អែកលើការឆ្លុះបញ្ចាំងរបស់ខ្ញុំ ខ្ញុំចាត់វិធានការដូចខាងក្រោម៖** | | | | | |

## IV. សន្និដ្ឋាន

ក្នុងមេរៀននេះ យើងបានបង្ហាញពីតួនាទីរបស់គ្រូបង្រៀននៅក្នុងដំណើរការត្រួតពិនិត្យតាមដាន និងវាយតម្លៃកម្រិតឆ្លើយតបនឹងសមភាពយេនឌ័រនៅក្នុងថ្នាក់រៀនរបស់គាត់។ គ្រូអាចប្រើឧបករណ៍ឆ្លុះបញ្ចាំងដើម្បីកំណត់កម្រិតឆ្លើយតបនឹងសមភាពយេនឌ័ររបស់ខ្លួន។ ធ្វើបែបនេះអាចជួយឱ្យគ្រូដឹងថាផ្នែកណាដែលគាត់គួរកែលម្អ និងព័ត៌មានចាំបាច់ដែលគាត់អាចរកបាននៅក្នុងសៀវភៅណែនាំនេះ។

**ឧបសម្ព័ន្ធ ក**

ចម្លើយសម្រាប់សកម្មភាព ក ក្នុងមេរៀន "ភាពខុសគ្នារវាងភេទ និងយេនឌ័រ"៖ សកម្មភាព ភេទ ឬយេនឌ័រ?

| ល.រ | ខ្លឹមសារ | យេនឌ័រ | ភេទ |
|---|---|---|---|
| ១ | បុរសចូលចិត្តលេងបាល់ទាត់ | ✓ | |
| ២ | ស្ត្រីបំបៅដោះកូនដោយទឹកដោះម្តាយ | | ✓ |
| ៣ | ស្ត្រីមានស្បូន មានគភ៌ និងបង្កើតកូនបាន បុរសមិនអាច | | ✓ |
| ៤ | ស្ត្រីទន់ភ្លន់ បុរសគំរោះគំរើយ | ✓ | |
| ៥ | ការបង្រៀននៅសាលាមត្តេយ្យជាមុខរបររបស់ស្ត្រី | ✓ | |
| ៦ | នៅក្នុងប្រទេសខ្លះ ស្ត្រីមិនអនុញ្ញាតឱ្យបើកបររថយន្តបានទេ | ✓ | |
| ៧ | សំឡេងរបស់បុរសអាចផ្លាស់ប្តូរបាន ចំណែកមនុស្សស្រីមិនប្តូរសំឡេងទេ | ✓ | |
| ៨ | ស្ត្រីប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ ដោយសារតែស្វាមីមានដៃគូរួមភេទច្រើន | ✓ | |
| ៩ | នៅប្រទេសប្រទេសកម្ពុជា បុរសត្រូវចូលទៅស្តីដណ្តឹងស្ត្រីដើម្បីរៀបអាពាហ៍ពិពាហ៍ | ✓ | |
| ១០ | នៅកម្ពុជា កម្មករសំណង់ភាគច្រើនជាបុរស | ✓ | |
| ១១ | កាលពីសម័យមុន ឪពុកម្តាយមិនសូវឱ្យកូនស្រី រៀនសូត្របានខ្ពង់ខ្ពស់ទេ | ✓ | |
| ១២ | បុរសមានសមត្ថភាពបន្តពូជផ្តល់មេជីវិតឈ្មោល (ស្ពែមម៉ាតូសូអ៊ីត) | | ✓ |
| ១៣ | បុរសភាគច្រើនគិតថាមានកូនគឺបញ្ជាក់ថាគេជាបុរសពិត និងមានមោទកភាពចំពោះខ្លួនឯង | ✓ | |
| ១៤ | អ្នកវិទ្យាសាស្ត្រភាគច្រើនជាបុរស | ✓ | |
| ១៥ | ក្មេងប្រុសតែងតែខ្លាំង និងរឹងមាំ ចំណែកក្មេងស្រីតែងតែមានភាពទន់ខ្សោយ | ✓ | |
| ១៦ | ក្មេងស្រីចូលចិត្តពណ៌ផ្កាឈូក ក្មេងប្រុសចូលចិត្តពណ៌ខៀវ | ✓ | |
| ១៧ | ដងខ្លួនស្ត្រីស្រឡូន ចំណែកបុរសមានសាច់ដុំ។ | ✓ | |

**ឧបសម្ព័ន្ធ ខ៖ កិច្ចតែងការដែលឆ្លើយតបនឹងសមភាពយេនឌ័រ**

ផ្នែកដែលមានគូសបន្ទាត់ពីក្រោមជាផ្នែកដែលជួយឱ្យកិច្ចតែងការនេះឆ្លើយតបនឹងសមភាពយេនឌ័រ

**ឧទាហរណ៍កិច្ចតែងការដែលឆ្លើយតបនឹងសមភាពយេនឌ័រ**

**ថ្នាក់ទី៖** ១
**មុខវិជ្ជា៖** គណិតវិទ្យាអំពីចំនួន
**មេរៀន៖** ប្រមាណវិធីបូក និងដកចំនួនពី០ ដល់២០
**ពេលវេលា៖** ៤៥នាទី
**សិស្ស៖** ៤០នាក់ ស្រី ១៨នាក់ ប្រុស ២២នាក់

**ឯកសារយោង៖**

- សៀវភៅគោលគណិតវិទ្យាថ្នាក់ទី១ ជំពូកទី១១ ទំព័រទី៥៦

**ក. វត្ថុបំណង**

- វិជ្ជាសម្បទា៖
    - សិស្សប្រាប់បានពីលំនាំនៃការធ្វើប្រមាណវិធីបូក និងដកចំនួន
- បំណិនសម្បទា៖
    - សិស្សបូក និងដកចំនួនត្រឹម២០ បានត្រឹមត្រូវ
    - សិស្សប្រើវត្ថុនៅក្នុងថ្នាក់រៀនដើម្បីបង្ហាញប្រមាណវិធីបូក និងដកត្រឹម២០
- ចរិយាសម្បទា៖
    - សិស្សប្រើចំណេះដឹងអំពីប្រមាណវិធីបូក និងដកត្រឹម២០ ក្នុងជីវភាពរស់នៅប្រចាំថ្ងៃនៅផ្សារ និងនៅផ្ទះ

**ខ. សម្ភារឧបទេស**

- ស្នាព្យួរខោអាវ
- ឈ្មោះនៅលើម្ជុលដេរខោអាវ
- សម្ភារជាក់ស្តែងក្នុងថ្នាក់រៀន
- បណ្ណភ្លើងសញ្ញាចរាចរ ឬកៃរជ័រពណ៌ក្រហម និងពណ៌បៃតង

### គ. លំនាំបង្រៀន និងរៀន

| ជំហាន | សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពសិស្ស |
|---|---|---|---|
| សេចក្តីផ្តើម<br>១០នាទី | គ្រូស្វាគមន៍សិស្ស និងណែនាំពួកគេពីវិធីប្តូរស្នាព្យួរខោអាវ។ លើកទឹកចិត្តសិស្សឱ្យជួយគ្នាទៅវិញទៅមក បើចាំបាច់។<br>គ្រូសួរប្រធានថ្នាក់ពីឈ្មោះសិស្សដែលអវត្តមាន។<br>គ្រូចែកសិស្សជាក្រុមចម្រុះភេទដែលមានសមាជិក ពី ៥ ទៅ៦នាក់។<br>គ្រូប្រាប់វត្ថុបំណង មេរៀន។ ថ្ងៃនេះយើងនឹងរៀនបន្តទៀតអំពីប្រមាណវិធីបូក និងដកត្រឹម២០។ | ស្នាព្យួរខោអាវចំនួន២ (១ ពណ៌ក្រហម និង ១ ពណ៌បៃតង) ដោយមានម្ជុលខ្ទាស់ឈ្មោះដើម្បីបញ្ជាក់ពីវត្តមានរបស់ពួកគេ។<br>សំណួរសម្រាប់សិស្ស៖<br>1. តើកូនៗណាដឹងថាអ្វីជាប្រមាណវិធីបូក?<br>2. តើកូនៗណាដឹងថាអ្វីជាប្រមាណវិធីដក?<br>3. ជ្រើសរើសតំណាងក្រុម (ទាំងសិស្សប្រុស និងសិស្សស្រី) ឡើងមកខាងមុខដើម្បីរាប់ត្រឹម២០ | សិស្សជួយគ្នាទៅវិញទៅមកដើម្បីពិនិត្យវត្តមានសិស្ស<br>ប្រធានថ្នាក់អានឈ្មោះសិស្សដែលអវត្តមានដើម្បីឱ្យគ្រូកត់ត្រា<br>ទាំងសិស្សប្រុស និងសិស្សស្រីឆ្លើយសំណួរម្តងមួយ |
| មេរៀនថ្មី<br>២៥នាទី | គ្រូសរសេរលំហាត់ប្រមាណវិធី៣ នៅលើក្តារខៀន៖<br>១២+៤=<br>៨+៥=<br>១៧-៦= | សួរសិស្សពីភាពខុសគ្នារវាងប្រមាណវិធីទាំង៣។ ផ្តល់ឱកាសឱ្យសិស្សផ្សេងៗគ្នាឆ្លើយ។ | សិស្សដែលចង់ឆ្លើយសំណួរលើកដៃសុំឆ្លើយ និងរង់ចាំដល់វេនរបស់ពួកគេ |

| | | | |
|---|---|---|---|
| | គ្រូបង្ហាញចង្កឹះនៅលើតុខាងមុខ<br><br>សួរសិស្សថាតើគេយល់ពីភាពខុសគ្នាដែរឬទេ<br><br>គ្រូចែកសន្លឹកកិច្ចការប្រមាណវិធី និងធុងទឹកឱ្យក្រុមនីមួយៗ<br><br>គ្រូជួយសិស្សបែងចែកតួនាទីក្នុងក្រុមនីមួយៗ<br><br>គ្រូជួយ និងសង្កេតក្រុមនីមួយៗក្នុងបរិវេណសាលារៀន<br><br>គ្រូលើកទឹកចិត្តសិស្សឱ្យចូលរួមសកម្មភាពក្នុងក្រុមនីមួយៗ | ហៅសិស្សប្រុស ២នាក់ និងសិស្សស្រីម្នាក់ឡើងបង្ហាញពីវិធីធ្វើប្រមាណវិធីទាំង៣ ដោយប្រើសម្ភារបង្ហាញនៅតុខាងមុខ<br><br>បង្ហាញភាពខុសគ្នាដោយប្រើពាក្យយកចេញ បូកបន្ថែម ដក បូក បញ្ចូលគ្នា។ល។<br><br>ពន្យល់ថា សិស្សធ្វើការជាក្រុម និងជ្រើសរើសប្រធានក្រុមម្នាក់ អ្នកកត់ត្រាម្នាក់ និងអ្នកប្រមូលសម្ភារម្នាក់។ អ្នកផ្សេងទៀតជាសមាជិក។<br><br>ក្រុមនីមួយៗដើរក្នុងបរិវេណសាលា និងប្រមូលសម្ភារ។ សម្រាប់សម្ភារនីមួយៗ ពួកគេត្រូវសរសេរប្រមាណវិធីមួយ | សិស្សស្តាប់មិត្តរួមថ្នាក់ និងមើលក្តារខៀន<br><br>សិស្សលើកបណ្តាភ្លើងសញ្ញាចរាចរដើម្បីបញ្ជាក់ពីការយល់ដឹងរបស់ពួកគេ<br><br>ក្រុមនីមួយៗបែងចែកតួនាទីប្រកបដោយសមភាពយេនឌ័រ<br><br>ក្រុមនីមួយៗសហការ ប្រើបំណិនស្តាប់ និងប្រមូលសម្ភារផ្សេងៗសម្រាប់ប្រើក្នុងការបង្ហាញរបស់ពួកគេ |
| ការវាយតម្លៃ | គ្រូបង្ហាញទីតាំងមួយនៅ | ក្រុមនីមួយៗបង្ហាញសម្ភារ | ក្រុមនីមួយៗសហការគ្នា |

| | | | |
|---|---|---|---|
| ១០នាទី | ក្នុងថ្នាក់ដែលសិស្សអាចបង្ហាញលទ្ធផលរបស់ពួកគេបាន<br><br>គ្រូណែនាំបន្ថែមពេលស្ដាប់លទ្ធផលរបស់ក្រុមនីមួយៗ | និងប្រមាណវិធីទៅកាន់សិស្សផ្សេងៗទៀតក្នុងថ្នាក់<br><br>តំណាងក្រុមនីមួយៗបង្ហាញដំណើរការ និងលទ្ធផលរបស់គេ | ដើម្បីបង្ហាញលទ្ធផលក្រុមដោយផ្អែកលើបំណិនរបស់សមាជិកក្រុមម្នាក់ៗ<br><br>តំណាងក្រុមនីមួយៗបង្ហាញលទ្ធផលរបស់គេ។ ក្រុមផ្សេងទៀតស្ដាប់ និងសង្កេត។ |

## ឧបសម្ព័ន្ធ គ៖ ឯកសារយោង


Bosow, S.A. (1992). *Gender: Stereotypes and roles* (3rd ed.). Belmont: Thomson Brooks/Cole Publishing Co.

Cabus, S., Sok, S., Rutkowska, K., Van Horen, K., & Nicaise, I. (2019). *The role of gender-responsive pedagogy to tackle violence against and between children in Cambodian schools*. Retrieved from https://cambodia.vvob.org/sites/cambodja/files/the_role_of_genderresponsive_pedagogy_to_0.pdf

Chetty, R., Hendren, N., & Katz, L. F. (2016). *The effects of exposure to better neighborhoods on children: New evidence from the Moving to Opportunity experiment*. American Economic Review, 106(4), 855-902.

Cho, H., Hallfors, D. D., Mbai, I. I., Itindi, J., Milimo, B. W., Halpern, C. T., & Iritani, B. J. (2011). *Keeping adolescent orphans in school to prevent human immunodeficiency virus infection: evidence from a randomized controlled trial in Kenya.* Journal of Adolescent Health, *48*(5), *523-526*.

Currie, J., & Spatz Widom, C. (2010). *Long-term consequences of child abuse and neglect on adult economic well-being. Child maltreatment*, *15*(2), *111-120*.

Edström, J., Long, S. & Roelen, K. (2012). *Pathways to protection – referral mechanisms and case management for vulnerable children in Eastern and Southern Africa. Brighton: Centre for Social Protection, Institute of Development Studies.* Retrieved from www.ids.ac.uk/files/dmfile/Pathwaystoprotection_finalreport_Jun12.pdfGender

Eliot, M., Cornell, D., Gregory, A., & Fan, X. (2010). *Supportive school climate and student willingness to seek help for bullying and threats of violence.* Journal of school psychology, *48*(6), *533-553*.

Fabes, R. A., & Hanish, L. D. (2014). *Peer socialisation of gender in young boys and girls*. In R. E. Tremblay, M. Boivin & R. de V. Peters (Eds.), C. L. Martin (Topic ed.). Encyclopedia on Early Childhood Development. Retrieved from http://www.child-encyclopedia.com/sites/default/files/textes-experts/en/2492/peer-socialisation-of-gender-in-young-boys-and-girls.pdf

FAWE. (2005). *Gender Responsive Pedagogy (A Teacher's Handbook).* Nairobi: FAWE.

FAWE. (2005). *FAWE Centre of Excellence Model: The Gender Responsive School - Handbook for Education Practitioners.* Nairobi: FAWE.

FAWE. (2020). *Gender Responsive Pedagogy Toolkit for Teachers and Schools 2nd Edition.* Nairobi: FAWE.

Gershoff, E. T. (2002). *Corporal punishment by parents and associated child behaviors and experiences: a meta-analytic and theoretical review*. Psychological bulletin, *128*(4), *539*.

Glaser, D. (2002). *Emotional abuse and neglect (psychological maltreatment): A conceptual framework*. Child abuse & neglect, *26*(6-7), *697-714*.

Huang, Y., Espelage, D. L., Polanin, J. R., & Hong, J. S. (2019). *A Meta-analytic Review of School-Based Anti-bullying Programs with a Parent Component.* International Journal of Bullying Prevention, *1-13*.

IREX (Ed.). (2014). *Developing Gender Responsive Learning Environments.* An IREX Toolkit for Teachers. Retrieved from http://rtglobaltigers.weebly.com/uploads/4/4/9/7/44979895/gender_and_educationtoolkit_jan_2014.pdf

Little, W. (2014). *Introduction to Sociology – 1st Canadian Edition.* (W. Little, Ed.) (1st ed.). Retrieved from https://opentextbc.ca/introductiontosociology/

Martin, C.L., Wood, C., & Little, J.K. (1990). *The Development of gender stereotype components.* Child development, 61/6, 1891–1904.

Parkes, J., Heslop, J., Ross, F. J., Westerveld, R., & Unterhalter, E. (2016). *A Rigorous Review of Global Research Evidence on Policy and Practice on School-Related Gender-Based Violence.* UNICEF.

PREEEP, & GIZ. (2011). *Training Manual on Gender Mainstreaming.* Retrieved from https://www.energia.org/cm2/wp-content/uploads/2015/04/04.-1319143629-Gendertrainingmanual.pdf

Rae Lesser Blumberg, R. L. (2015), *Eliminating gender bias in textbooks: Pushing for policy reforms that promote gender equity in education.* Paper commissioned for the EFA Global Monitoring Report 2015, Education for All 2000–2015: achievements and challenges. Retrieved on 11 December 2018 from http://unesdoc.unesco.org/images/0023/002324/232452e.pdf

Save the Children. *How To Research the Physical and Emotional Punishment of Children*. Bangkok: Southeast, East Asia and Pacific Region, 2004.

Schweinhart, L. J., & Weikart, D. P. (1980). *Young Children Grow Up: The Effects of the Perry Preschool Program on Youths Through Age 15*. High/Scope Press, 600 North River Street, Ypsilanti, MI 48197.

Stoltenborgh, M., Bakermans-Kranenburg, M. J., Alink, L. R., & van Ijzendoorn, M. H. (2015). *The prevalence of child maltreatment across the globe: Review of a series of meta‐analyses*. Child Abuse Review, *24*(1), *37-50*.

UN. (2015). *Sustainable Development Goals*. Retrieved from https://sustainabledevelopment.un.org/sdgs

UN Women. (1979). *Convention on the Elimination of All Forms of Discrimination against Women*. Retrieved from http://www.un.org/womenwatch/daw/cedaw/

UNESCO. (1960). *Convention against Discrimination in Education.* Retrieved from http://www.unesco.org/education/pdf/DISCRI_E.PD

UNECSO, & UNESCO Bangkok office. (2015). *Embracing Diversity: Toolkit for Creating Inclusive, Learning-Friendly Environments. Specialized Booklet Positive Discipline in the Inclusive, Learning-Friendly Classroom. A Guide for Teachers and Teacher Educators.* (5th ed.). Paris, France: UNESCO.

UNESCO, & UN Women (Eds.). (2016). *Global guidance: school-related gender-based violence* (1st ed.). France: UNESCO.

VVOB (2007). *Learner-centered methodology. Training manual for pre-service and in-service training of primary school teachers*. Cambodia.

VVOB vzw (Ed.). (2019). *Putting SDG4 into practice: Enhancing adolescent wellbeing, learning and opportunities* (1st ed.). Brussels: VVOB vzw.

VVOB, & FAWE. (2019). *Gender-Responsive Pedagogy in Early Childhood Education. A toolkit for teachers and school leaders.* Brussels: VVOB.